**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ទំនាក់ទំនងនៃការទទួលខុសត្រូវរវាង អំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញា (ករណីសិក្សាប្រទេសកម្ពុជា និងជប៉ុន)

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ **កញ្ញា សារិទ្ធ លីហ្សា** | **សាស្ត្រាចារ្យជំនួយ សុខ ចិន្តា** |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០២០ |
| ជំនាន់ទី២៤ | ឆ្នាំសរសេរសារណា ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ទំនាក់ទំនងនៃការទទួលខុសត្រូវរវាង អំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញា (ករណីសិក្សាប្រទេសកម្ពុជា និងជប៉ុន)

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ៖ **កញ្ញា សារិទ្ធ លីហ្សា** | **សាស្ត្រាចារ្យជំនួយ សុខ ចិន្តា** |
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០២០ |
| ជំនាន់ទី២៤ | ឆ្នាំសរសេរសារណា ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សារិទ្ធ លីហ្សា** ជានិស្សិតផ្នែកនីតិសាស្ត្រ ជំនាន់ទី២៤ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជានិស្សិតជំនាន់ទី១២ នៃមជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវច្បាប់ជាភាសាជប៉ុន(CJL)។ ឆ្លៀតក្នុងឱកាសដ៏មានតម្លៃនេះ នាងខ្ញុំសូមធ្វើការគោរពថ្លែងអំណរគុណចំពោះអ្នកមានគុណទាំងអស់ដែលជាចំណែកមួយយ៉ាងធំធេងក្នុងការជួយជ្រោមជ្រែងរហូតដល់សមិទ្ធផលមួយនេះចេញជារូបរាងឡើងដោយជោគជ័យ។

ជាបឋម នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **អ្នកមានគុណទាំងពីរ** ដែលលោកបានជួយជម្រុយលើកទឹកចិត្ត និងផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ និងផ្នែកស្មារតី។ អ្នកមានគុណទាំងពីរបានលះបង់ទាំងកម្លាំងកាយ ដោយមិនខ្លាចនឿយហត់ ចិញ្ចឹមបីបាច់ ប្រៀនប្រដៅអប់រំកូន ជាពិសេសផ្តល់ឱកាសឱ្យកូនអាចទទួលបាននូវការអប់រំយ៉ាងជ្រៅជ្រះរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

ស្របពេលជាមួយគ្នានេះដែរ នាងខ្ញុំសូមធ្វើការថ្លែងអំណរគុណដល់ ឯកឧត្តមបណ្ឌិតសកលវិទ្យាធិការ **លុយ ចន្ណា** ចំពោះការដឹកនាំសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលជាប្រភពមួយនៃការបណ្តុះបណ្តាលចំណេះដឹងផ្នែកច្បាប់ដល់និស្សិតប្រកបដោយប្រសិទ្ធិភាព។ ជាពិសេស នាងខ្ញុំសូមគោរពអរគុណចំពោះ លោកស្រីសាស្ត្រាចារ្យ **សុខ ចិន្តា** ដែលលោកស្រីបានចំណាយពេលវេលាដ៏មានតម្លៃ និងផ្តល់ជាមតិយោបល់លើកិច្ចការស្រាវជ្រាវមួយនេះតាំងពីដើមរហូតដល់បានបញ្ចប់ដោយជោគជ័យ។ បើគ្មានការជួយណែនាំ និងបណ្តុះបណ្តាលពីសំណាក់លោកស្រីសាស្ត្រាចារ្យទេនោះ ស្នាដៃមួយនេះនឹងមិនអាចលេចចេញជារូបរាងឡើយ នាងខ្ញុំសូមគោរពដឹងគុណ និងចងចាំទុកជារៀងរហូតតទៅ។

ទន្ទឹមនឹងនេះដែរ នាងខ្ញុំក៏សូមអរគុណដល់ **មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុន** ដែលបានបណ្តុះបណ្តាលទាំងចំណេះដឹងផ្នែកច្បាប់ និងជំនាញភាសាជប៉ុនរយៈពេល៤ឆ្នាំកន្លងមកនេះ។ សូមគោរពដឹងគុណយ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យនៃមជ្ឈមណ្ឌលដែលលោកបានបណ្តុះបណ្តាលឱ្យនាងខ្ញុំទទួលបានចំណេះដឹងយ៉ាងស៊ីជម្រៅលើប្រព័ន្ធច្បាប់នៃប្រទេសជប៉ុន ទើបអាចឱ្យការសិក្សាច្បាប់ប្រទេសកម្ពុជាកាន់តែមានប្រសិទ្ធិភាព ដោយធ្វើការវិភាគ និងប្រៀបធៀបប្រព័ន្ធច្បាប់នៃប្រទេសទាំងពីរ។

ជាកិច្ចបញ្ចប់ នាងខ្ញុំសូមគោរពជូនពរដល់អ្នកមានគុណ និងសាស្ត្រាចារ្យទាំងអស់គ្នាជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ នាងខ្ញុំនឹងចងចាំនូវរាល់ការប្រៀនប្រដៅ និងការណែនាំទាំងអស់របស់សាស្ត្រាចារ្យ ហើយខិតខំអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាធនធានមនុស្សរបស់ប្រទេសជាតិ និងជាគម្រូមួយសម្រាប់ដល់សិស្សប្អូនជំនាន់ក្រោយទាំងអស់គ្នា។

# អារម្ភកថា

ក្នុងនាមជានិស្សិតផ្នែកនីតិសាស្ត្រមួយរូបដែលមានចំណេះដឹងផ្នែកច្បាប់ និងបានសិក្សាស្រាវជ្រាវលើប្រធានបទជាច្រើនកន្លងមក នាងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ "**ទំនាក់ទំនងនៃការទទួលខុសត្រូវរវាងអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញា**" នេះមកធ្វើការស្រាវជ្រាវ និងចងក្រងជាសារណានាឱកាសនេះ។ ការស្រាវជ្រាវកើតចេញពីចំណេះដឹងដែលបានសិក្សាកន្លងមក ព្រមទាំងការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់នាងខ្ញុំ។ ជាពិសេស ស្នាដៃនេះទទួលបានជោគជ័យដោយមានការដឹកនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់សាស្ត្រាចារ្យ **សុខ ចិន្តា** ។

កិច្ចការស្រាវជ្រាវនេះមិនត្រឹមតែចងក្រងឡើងដោយផ្អែកលើឯកសារគតិយុត្តិរបស់កម្ពុជាប៉ុណ្ណោះទេ នាងខ្ញុំបានខិតខំស្រាវជ្រាវឯកសារបរទេសបន្ថែមទៀតមកធ្វើជាឯកសារយោង ដើម្បីឱ្យស្នាដៃនេះកាន់តែមានភាពក្បោះក្បាយ និងអាចផ្តល់ដល់អ្នកអាននូវចំណេះដឹងថ្មីៗបន្ថែមទៀត។ កិច្ចការស្រាវជ្រាវនេះចង់ឆ្លុះបញ្ចាំងនូវកង្វះខាតផ្នែកច្បាប់ ក៏ដូចជាបញ្ហាចោទដែលគួរតែទទួលបានការយកចិត្តទុកដាក់បន្ថែមទៀត។ ទោះបីជាយ៉ាងនេះក្តី កិច្ចការស្រាវជ្រាវនេះមិនមានបំណងអ្វីក្រៅពីលើកឡើងពីភាពខ្វះខាតនៃច្បាប់ និងផ្តល់ជាដំណោះស្រាយ ក៏ដូចជាផ្តល់ជាអនុសាសន៍សម្រាប់បំពេញបន្ថែមឱ្យការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធិភាព។

ក្នុងចំណោមវិស័យទាំងអស់ ក្រមរដ្ឋប្បវេណីជានីតិមួយដែលមានទំនាក់ទំនងយ៉ាងជិតស្និតបំផុតនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ហេតុនេះហើយក្រមរដ្ឋប្បវេណីគប្បីត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងសមស្របទៅនឹងសង្គមកម្ពុជាជាក់ស្តែង។ គួរកត់សម្គាល់ផងដែរថា ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាបានទទួលនូវជំនួយផ្នែកច្បាប់ពីប្រទេសជប៉ុន ជាហេតុធ្វើឱ្យក្រមរដ្ឋប្បវេណីកម្ពុជា និងក្រមរដ្ឋប្បវេណីជប៉ុនមានចំណុចដូចគ្នាច្រើន។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលកម្ពុជាបានព្យាយាមសិក្សាស្វែងយល់ និងរៀបចំនូវប្រព័ន្ធច្បាប់មួយដែលអាចអនុវត្តបានយ៉ាងសមស្របនៅក្នុងសង្គមកម្ពុជា។ ដូចនេះក្នុងនាមជានិស្សិតដែលបានសិក្សាស្រាវជ្រាវ និងមានចំណេះដឹងផ្នែកច្បាប់ជប៉ុនផងនោះ នាងខ្ញុំយល់ឃើញថា កិច្ចការស្រាវជ្រាវមួយនេះនឹងក្លាយជាផ្លូវមួយសម្រាប់សិស្សប្អូនជំនាន់ក្រោយបានយល់ដឹង និងចាប់អារម្មណ៍ពីទំនាក់ទំនងរវាងច្បាប់ប្រទេសកម្ពុជា និងប្រទេសជប៉ុន។

កិច្ចការស្រាវជ្រាវនេះ ជាស្នាដៃមួយដែលថ្មី និងបានចងក្រងឡើងដោយឆ្លងកាត់ការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់។ ប៉ុន្តែទោះបីជាយ៉ាងណា នាងខ្ញុំជឿថាភាពខ្វះខាត និងកំហុសខុសឆ្គងប្រាកដជាមានដោយសារការស្រាវជ្រាវ និងចំណេះដឹងនៅមានកម្រិត។ ទោះបីជាយ៉ាងនេះក្តី នាងខ្ញុំសង្ឃឹមថាកិច្ចការស្រាវជ្រាវនេះអាចចូលរួមចំណែកផ្តល់ជាចំណេះដឹង ព្រមទាំងបណ្តុះស្មារតីដល់សិស្សប្អូនជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្ត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១. លំនាំបញ្ហា ........ ១

២.ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. វិសាលភាពនៃការស្រាវជ្រាវ ........ ៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃអំពើអនីត្យានុកូល**

**១.១ អ្វីទៅជាអំពើអនីត្យានុកូល**? ........ ៥

១.១.១ និយមន័យ ........ ៥

១.១.២ មុខងារ និងតួនាទីនៃអំពើអនីត្យានុកូល ........ ៦

**១.២ លក្ខខណ្ឌនៃអំពើអនីត្យានុកូល** ........ ៧

១.២.១ កំហុសចេតនា ឬអចេតនា ........ ៧

១.២.២ ភាពផ្ទុយច្បាប់ ........ ៩

១.២.៣ ការខូចខាត ........ ៩

១.២.៤ ទំនាក់ទំនងហេតុ និងផល ........ ១០

**១.៣ អានុភាពនៃអំពើអនីត្យានុកូល** ........ ១២

១.៣.១ សំណងការខូចខាត ........ ១២

១.៣.២ ទំហំនៃសំណងការខូចខាត ........ ១២

១.៣.៣ ការទូទាត់កំហុស ........ ១៣

១.៣.៤ មូលដ្ឋាននៃការគណនាសំណងការខូចខាត ........ ១៣

១.៣.៤.១ ការខូចខាតទ្រព្យសម្បត្តិ ........ ១៤

១.៣.៤.២ ការខូចខាតក្រៅពីទ្រព្យសម្បត្តិ ........ ១៥

## ជំពូកទី២
## ទិដ្ឋភាពទូទៅនៃកម្មសិទ្ធិបញ្ញា

**២.១ ប្រវត្តិនៃកម្មសិទ្ធិបញ្ញា**..........១៧
២.១.១ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល..........១៨
២.១.២ ការគ្រប់គ្រង និងស្ថាប័នមានសមត្ថកិច្ច..........២០
**២.២ ស្ថានភាពជាក់ស្តែងនៃកម្មសិទ្ធិបញ្ញា**..........២១

## ជំពូកទី៣
## ទំនាក់ទំនងរវាងអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញា

**៣.១ បញ្ហាប្រឈមនៃអំពើអនីត្យានុកូល និងអំពើរំលោភកម្មសិទ្ធិបញ្ញា**..........២៣
៣.១.១ អំពើរំលោភសិទ្ធិអ្នកនិពន្ធ និងលក្ខខណ្ឌនៃអំពើអនីត្យានុកូល..........២៥
៣.១.២ មូលដ្ឋានក្នុងការទាមទារសំណងការខូចខាតចំពោះការបំពានកម្មសិទ្ធិបញ្ញា..........២៦
៣.១.២.១ ទ្រឹស្តីច្បាប់សិទ្ធិអ្នកនិពន្ធជាមូលដ្ឋាន..........២៧
៣.១.២.២ ទ្រឹស្តីនៃក្រមរដ្ឋប្បវេណីជាមូលដ្ឋាន..........២៨
**៣.២ ករណីប្រៀបធៀបប្រទេសជប៉ុន**..........២៩
៣.២.១ ការបកស្រាយអំពីការបំពានសិទ្ធិ និងលក្ខខណ្ឌនៃអំពើអនីត្យានុកូល..........២៩
៣.២.២ មូលដ្ឋានក្នុងការទាមទារសំណងការខូចខាត..........៣១
**៣.៣ ដំណោះស្រាយ**..........៣៤
**សេចក្តីសន្និដ្ឋាន**..........៣៦
**អនុសាសន៍**..........៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

កិច្ចការស្រាវជ្រាវនេះផ្តើមចេញពីចម្ងល់ដែលកើតចេញពីការសិក្សាស្រាវជ្រាវក្នុងអំឡុងពេលសិក្សាពីវិស័យទាំងពីរនេះ។ ប្រព័ន្ធអំពើអនីត្យានុកូលជាប្រព័ន្ធមួយដ៏សំខាន់ដោយវាមានទំនាក់ទំនងដោយផ្ទាល់នឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង។ ការទទួលបាននូវសំណង ក៏ដូចជាការទទួលខុសត្រូវរបស់បុគ្គលដែលបង្កនូវការខូចខាតដល់អ្នកដទៃគួរតែមានភាពសមរម្យ និងត្រឹមត្រូវតាមច្បាប់។ ជាក់ស្តែង នៅក្នុងក្រមរដ្ឋប្បវេណីដែលបានកំណត់យ៉ាងច្បាស់អំពីការទទួលខុសត្រូវរបស់បុគ្គល។ ប្រសិនបើការបំពាននោះជាការបំពានទៅលើទ្រព្យសម្បត្តិរូបី ពោលគឺការធ្វើឱ្យបែកបាក់ ឬខូចខាតទ្រព្យសម្បត្តិ ឬជាការបង្កឱ្យមានរបួសស្នាមជាដើមនោះ អ្នកដែលបានប្រព្រឹត្តអំពើបំពាននោះ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។ ដោយជនរងគ្រោះអាចទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលដូចមានចែងក្នុងក្រមរដ្ឋប្បវេណី។ ប៉ុន្តែប្រសិនបើក្នុងករណីដែលការបំពាននោះជាការបំពានទៅលើទ្រព្យអរូបីវិញនោះ តើជននោះអាចត្រូវទទួលខុសត្រូវយ៉ាងដូចម្តេច?

កម្មសិទ្ធិបញ្ញាត្រូវបានចាត់ទុកជាកត្តាចម្បងមួយផងដែរក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ នៅពេលដែលសន្ទុះនៃការបង្កើតថ្មីមិនថាទាំងផ្នែកឧស្សាហកម្មដូចជា ម៉ាក តក្កកម្ម និងផ្នែកអក្សរសាស្ត្ររួមមានចម្រៀង សៀវភៅ នោះទេ សុទ្ធតែអាចរួមជាចំណែកមួយក្នុងការទាក់ទាញអ្នកវិយោគក្នុង និងក្រៅស្រុកឱ្យមកវិនិយោគនៅប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះការលើកស្ទួយវិស័យអក្សរសាស្ត្រនៅកម្ពុជាក៏ជាផ្លូវមួយក្នុងការណែនាំពីវប្បធម៌របស់ប្រទេសកម្ពុជាទៅកាន់ឆាកអន្តរជាតិថែមទៀតផង។ ប៉ុន្តែបើយើងក្រឡេកមកមើលពីស្ថានភាពជាក់ស្តែងនៃកម្មសិទ្ធិបញ្ញានៅប្រទេសកម្ពុជាវិញយើងឃើញថា ការការពារ និងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានៅមានកម្រិតនៅឡើយ ជាពិសេសគឺសិទ្ធិអ្នកនិពន្ធ។ សិទ្ធិអ្នកនិពន្ធ ឬដែលភាគច្រើនត្រូវបានគេស្គាល់ថា Copyright គឺ ជាសិទ្ធិមួយក្នុងចំណោមកម្មសិទ្ធិបញ្ញាដែលត្រូវបានការពារដោយច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល (តទៅនេះហៅថា ច្បាប់សិទ្ធិអ្នកនិពន្ធ )។ សិទ្ធិអ្នកនិពន្ធនេះអាចត្រូវគេស្គាល់ច្រើនជាងកម្មសិទ្ធិបញ្ញាដទៃទៀតដោយវាហាក់នៅជុំវិញខ្លួន និងជួបប្រទះច្រើនក្នុងជីវភាពប្រចាំថ្ងៃរបស់យើង។ សិទ្ធិអ្នកនិពន្ធមានដូចជា សៀវភៅ ចម្រៀង បទភ្លេង គំនូរ ចម្លាក់។ល។

ប៉ុន្តែទោះបីជាសិទ្ធិអ្នកនិពន្ធត្រូវបានគេស្គាល់ច្រើនជាងកម្មសិទ្ធិបញ្ញាដទៃទៀតក៏ដោយ វាហាក់ដូចជាមិនសូវទទួលបានការការពារ និងយកចិត្តទុកដាក់ដូចកម្មសិទ្ធិបញ្ញាដទៃទៀតឡើយ។ ជាក់ស្តែង សព្វថ្ងៃនេះយើងឃើញថា ការដាក់លក់សៀវភៅដែលថតចម្លងដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធនៅតាមបណ្តាតូបលក់សៀវភៅនៅតែបន្តមាន។ លើសពីនេះទៅទៀតដោយសារបច្ចេកវិទ្យាក៏កាន់តែទំនើបថែមទៀតនោះ យើងឃើញ

ថាការលួចចម្លងស្នាដៃក៏កាន់តែមានភាពងាយស្រួលជាងមុនផងដែរ ដូចជាយើងបានឃើញញឹកញាប់ផងដែរ នោះគឺ ការលួចចម្លងទំនុកភ្លេងរបស់អ្នកដទៃ ឬយកចម្រៀង ឬភាពយន្តរបស់អ្នកដទៃដោយគ្មានការអនុញ្ញាត ទៅផ្សព្វផ្សាយក្នុងបណ្តាយសង្គមនានារួមមាន Facebook YouTube ជាដើម។

តាមរយៈការមើលឃើញពីស្ថានភាពទាំងអស់នេះហើយ ទើបជម្រុយឱ្យមានការចង់សិក្សាស្រាវជ្រាវបន្ថែមជុំវិញបញ្ហាសិទ្ធិអ្នកនិពន្ធនេះ។ ប្រសិនបើយើងនៅតែបន្តមិនអើពើជាមួយបញ្ហាដែលកំពុងកើតមាន នោះវានឹងកាន់តែមានភាពលំបាកក្នុងការដោះស្រាយនាពេលខាងមុខ។ ហេតុនេះហើយដើម្បីជាការចង្អុលផ្លូវមួយសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាការជួយជម្រុយបន្ថែមការសិក្សាស្រាវជ្រាវអំពីផ្នែកកម្មសិទ្ធិបញ្ញានេះបន្ថែមទៀត ទើបការចាប់ផ្តើមស្រាវជ្រាវពីប្រធានបទនេះជារឿងដែលចាំបាច់។

## ២.ចំណោទបញ្ហា

ដូចដែលយើងធ្លាប់សិក្សាកន្លងមក ប្រសិនបើបុគ្គលណាម្នាក់ប្រព្រឹត្តអំពើណាមួយដែលបានបង្កជាព្យសនៈកម្មដល់អ្នកដទៃ នោះបុគ្គលនោះគប្បីត្រូវតែទទួលខុសត្រូវសងការខូចខាតនានាចំពោះជនរងគ្រោះនោះ ដោយផ្អែកលើអំពើអនីត្យានុកូល។ ចំណែកការរំលោភបំពានណាមួយលើសិទ្ធិអ្នកនិពន្ធវិញ ម្ចាស់នៃស្នាដៃនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការដោយផ្អែកលើបណ្តឹងអំពើរំលោភសិទ្ធិអ្នកនិពន្ធ។ ប៉ុន្តែក្រៅពីនីតិវិធីតុលាការ ច្បាប់ក៏អនុញ្ញាតឱ្យភាគីអាចចរចារលើការបញ្ឈប់អំពើរំលោភតាមរយៈការជូនដំណឹងទៅអ្នករំលោភសិទ្ធិនោះ ព្រមទាំងអាចទាមទារនូវសំណងការខូចខាតដើម្បីជួសជុលនូវព្យសនកម្មដែលខ្លួនបានទទួល។ ត្រង់ចំណុចនេះ បញ្ហាចោទគឺនៅត្រង់ថា តើម្ចាស់សិទ្ធិអាចទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលបាន ដែរ ឬទេ? តើការរំលោភកម្មសិទ្ធិបញ្ញាអាចចាត់ទុកជាអំពើអនីត្យានុកូលបានដែរ ឬទេ? ហើយក្នុងករណីដែល ការរំលោភកម្មសិទ្ធិបញ្ញាអាចចាត់ទុកជាអំពើអនីត្យានុកូលនោះ តើវិធាននៃអំពើអនីត្យានុកូលពិតជាអាចយក មកអនុវត្តចំពោះការបំពានកម្មសិទ្ធិបញ្ញាបានដែរ ឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងកិច្ចការស្រាវជ្រាវនេះ មានគោលបំណងចម្បងមួយគឺ យល់ដឹងអំពីទំនាក់ទំនងរវាងអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញានៅកម្ពុជាឱ្យកាន់តែស៊ីជម្រៅ។ តាមរយៈកិច្ចការស្រាវជ្រាវនេះ ខ្ញុំសង្ឃឹមថាជាផ្នែកមួយដែលអាចជួយជម្រុយឱ្យមានការចាប់អារម្មណ៍បន្ថែមលើវិស័យកម្មសិទ្ធិបញ្ញា ហើយពង្រឹងបន្ថែមការអនុវត្តកម្មសិទ្ធិបញ្ញានៅកម្ពុជា ដើម្បីឱ្យអ្នកនិពន្ធនៅកម្ពុជាទទួលបាននូវការការពារសិទ្ធិរបស់ខ្លួន និងមានកម្លាំងចិត្តក្នុងការបង្កើតនូវស្នាដៃថ្មីៗបន្ថែមទៀត។

## ៤. វិសាលភាពនៃការស្រាវជ្រាវ

ចំពោះកិច្ចការស្រាវជ្រាវនេះ នាងខ្ញុំនឹងធ្វើការសិក្សាអំពីប្រព័ន្ធនៃអំពើអនីត្យានុកូលជាពិសេសគឺផ្តោតសំខានតែអំពើអនីត្យានុកូលទូទៅប៉ុណ្ណោះ។ លើសពីនេះទៅទៀត ដោយយើងនឹងធ្វើការលើកឡើងអំពីបញ្ហាមួយចំនួនដែលមានទំនាក់ទំនងគ្នារវាងអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញានោះ យើងនឹងធ្វើការសិក្សាផងដែរនូវចំណេះដឹងមួយចំនួនទាក់ទងនឹងកម្មសិទ្ធិបញ្ញា។ ប៉ុន្តែវិស័យកម្មសិទ្ធិបញ្ញាជាវិស័យមួយដែលទូលំទូលាយដោយមានទាំងផ្នែកឧស្សាហកម្មរួមមាន៖ ប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម ជាអាទិ៍ និងអក្សរសាស្ត្រសំដៅដល់សិទ្ធិដែលផ្តល់ដល់អ្នកនិពន្ធចំពោះការបង្កើតស្នាដៃអក្សរសិល្ប៍ និងស្នាដៃសិល្បៈនានា។ ហេតុនេះហើយនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ យើងមិនអាចធ្វើការសិក្សាលើវិស័យកម្មសិទ្ធិបញ្ញាទាំងមូលបានឡើយ។ ដូចនេះវិសាលភាពនៃកិច្ចការស្រាវជ្រាវនេះ គឺគ្របដណ្តប់ត្រឹមតែសិទ្ធិអ្នកនិពន្ធប៉ុណ្ណោះ ដែលជាសិទ្ធិមួយដែលមហាជនភាគច្រើនបានស្គាល់។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះគឺ ផ្អែកទាំងស្រុងលើបទដ្ឋានគតិយុត្តិទាំងឡាយរបស់កម្ពុជា និងជប៉ុនដោយយើងយកមកធ្វើការសិក្សា និងធ្វើការប្រៀបធៀប។ម្យ៉ាងវិញទៀត ដោយសារតែនៅប្រទេសកម្ពុជា ការស្វែងរកឯកសារនៅមានការលំបាកដោយសារការផ្សព្វផ្សាយជាសាធារណៈមិនទាន់មានភាពទូលំទូលាយនៅឡើយ។ ជាពិសេសនៅប្រទេសកម្ពុជាការបើកបង្ហាញសេចក្តីសម្រេចរបស់តុលាការនៅមានកម្រិតនៅឡើយដែលខុសពីប្រទេសជប៉ុនដែលសេចក្តីសម្រេចរបស់តុលាការត្រូវបានបង្ហាញជាសាធារណៈ ហេតុនេះហើយកិច្ចការស្រាវជ្រាវនេះអាចមានភាពខ្វះចន្លោះច្រើន។ ប៉ុន្តែយើងនឹងធ្វើការសិក្សាស្រាវជ្រាវឱ្យអស់លទ្ធភាពផ្អែកតាមឯកសារ ច្បាប់ ប្រកាស ឯកសារស្រាវជ្រាវនានា ព្រមទាំងបទដ្ឋានគតិយុត្តិទាំងឡាយដែលយើងមាន។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងកិច្ចការស្រាវជ្រាវនេះ ផ្តោតសំខាន់លើទំនាក់រវាងអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញា។ ហេតុនេះហើយ យើងគប្បីយល់ច្បាស់អំពីប្រព័ន្ធនីមួយៗឱ្យបានច្បាស់ជាមុនសិន។ ហេតុនេះហើយ នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ខ្ញុំធ្វើការបែងចែកជា ៣ជំពូក ។ ជាដំបូង យើងនឹងធ្វើការសិក្សាស៊ីជម្រៅអំពីប្រព័ន្ធនៃអំពើអនីត្យានុកូលជាមុនសិន ដោយចាប់ផ្តើមពីការសិក្សាពីសញ្ញាណទូទៅនៃអំពើអនីត្យានុកូល (ជំពូក១) បន្ទាប់ពីដឹងថាអំពើអនីត្យានុកូលជាអ្វីហើយនោះ យើងក៏ត្រូវឈ្វេងយល់ពីចំណេះដឹងជាមូលដ្ឋានខ្លះៗទាក់ទងនឹងកម្មសិទ្ធិបញ្ញា (ជំពូក២)។ ជាការកត់សម្គាល់ រាល់ការសិក្សាចំណុចខ្លះយើងនឹងធ្វើការលើកឡើងផងដែរនូវភាពខុសគ្នារវាងប្រព័ន្ធរបស់កម្ពុជា និងប្រព័ន្ធរបស់ប្រទេសជប៉ុន។ ក្រោយពីយល់ដឹងអំពីមូលដ្ឋានខ្លះៗនៃប្រព័ន្ធ

ទាំងពីរនេះហើយ យើងនឹងពិចារណាលើបញ្ហាដែលអាចកើតមានឡើងទាក់ទងនឹងការរំលោភកម្មសិទ្ធិបញ្ញា និងទំនាក់ទំនងរវាងអំពើអនីត្យានុកូល ព្រមទាំងផ្តល់នូវដំណោះស្រាយខ្លះៗ ចំពោះបញ្ហាប្រឈមទាំងអស់នោះ (ជំពូក៣)។

# ជំពូកទី១
# សញ្ញាណទូទៅនៃ
# អំពើអនីត្យានុកូល

# ជំពូកទី១
# សញ្ញាណទូទៅនៃអំពើអនីត្យានុកូល

## ១.១ អ្វីទៅជាអំពើអនីត្យានុកូល?

### ១.១.១ និយមន័យ

នៅក្នុងក្រមរដ្ឋប្បវេណីបានកំណត់អំពីមូលហេតុ ៤ ធំៗដែលបណ្តាលឱ្យកើតមានសិទ្ធិលើបំណុល ដែលក្នុងនោះរួមមាន (១)កិច្ចសន្យា (២)អំពើអនីត្យានុកូល (៣)សេចក្តីចម្រើនឥតហេតុ (៤)ការគ្រប់គ្រងដោយឈឺឆ្អាល។ កិច្ចសន្យាត្រូវបានគេទទួលស្គាល់ថាជាប្រភពចម្បងមួយនៃការទទួលខុសត្រូវ ដែលត្រូវគេស្គាល់ថាជា "**ការទទួលខុសត្រូវក្នុងកិច្ចសន្យា**"។ ក្រៅពីនេះ អំពើអនីត្យានូលជាមូលហេតុសំខាន់មួយក្នុងចំណោម មូលហេតុក្រៅកិច្ចសន្យាដទៃទៀត ដែលត្រូវបានគេចាត់ទុកថាជា "**ការទទួលខុសត្រូវក្រៅកិច្ចសន្យា**"។[១]

និយមន័យនៃអំពើអនីត្យានុកូលត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា៧៤២ ថាជាអំពើទាំងឡាយណាដែលបំពានដោយចេតនា ឬអចេតនាលើសិទ្ធិ ឬផលប្រយោជន៍អ្នកដទៃ ដែលបណ្តាលឱ្យមានការខូចខាត ឬបាត់បង់ប្រយោជន៍ណាមួយ។ តាមរយៈនិយមន័យនេះយើងអាចសន្និដ្ឋានបានថា រាល់អំពើទាំងឡាយណាដែលបំពានដល់សិទ្ធិ ឬផលប្រយោជន៍ពោលគឺ បំពានដោយខុសច្បាប់ទៅលើអ្នកដទៃទោះជាមានចេតនាក្តី អចេតនាក្តី ជននោះត្រូវទទួលខុសត្រូវសងសំណងការខូចខាតដល់ជនរងគ្រោះនោះ។

ប៉ុន្តែនិយមន័យនៃអំពើអនីត្យានុកូលនេះផងដែរ ក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនមាត្រា៧០៩ មុនវិសោធនកម្មឆ្នាំ២០០៤ បានកំណត់និយមន័យថា "បុគ្គលដែលបានបំពានដល់សិទ្ធិរបស់បុគ្គលដទៃដោយចេតនា ឬកំហុសត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ" ដែលការកំណត់និយមន័យនេះបានធ្វើឱ្យមានការពិភាក្សាវែកញែកយ៉ាងច្រើនលើពាក្យថា "**បំពានដល់សិទ្ធិ**" ដោយគេបានលើកឡើងថា ប្រសិនបើការបំពាននោះមិនបានប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃទេនោះនឹងមិនចាត់ទុកជាអំពើអនីត្យានុកូលទេឬ?[២] ក្រោយពីមានការវិភាគវែកញែកខ្លួនមក តាមរយៈវិសោធនកម្មច្បាប់ឆ្នាំ២០០៤ ការប្រើពាក្យពេចន៍ត្រូវបានផ្លាស់ប្តូរពី "**ការបំពានដល់សិទ្ធិ**" ទៅជា "**ការបំពានដល់សិទ្ធិ និងផលប្រយោជន៍**" វិញដូចមានចែងក្នុងក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាដែរ។

---

[១] ក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, ២៨ តុលា ឆ្នាំ១៩៨៨, មាត្រា១២១

[២] ទ្រឹស្តីសិទ្ធិ និងអំពើអនីត្យានុកូល, យ៉ាសឹហ៊ីរ៉ុ, ចុះផ្សាយឆ្នាំ២០០៨ (藤岡康宏、「不法行為と権利論」（២០០៥ 年）), លក្ខខណ្ឌនៃអ្នកបំពានសិទ្ធិរបស់អ្នកព្រាងក្រមរដ្ឋប្បវេណី៖ ទ្រឹស្តីនៃការណែនាំសិទ្ធិដោយផ្អែកលើនីតិអំពើអនីត្យានុកូល,ស៊ូមីតា ម៉ូរីមីឈី, ចុះផ្សាយឆ្នាំ២០២៣ (住田・守道、「日本民法起草者における権利侵害要件 :不法行為法における権利論の地位・序説」、（២០២៣ 年）)

ការទទួលខុសត្រូវអំពើអនីត្យានុកូលអាចត្រូវបានបែងចែក ២ ប្រភេទគឺ អំពើអនីត្យានុកូលទូទៅ និង អំពើអនីត្យានុកូលពិសេស។ អំពើអនីត្យានុកូលទូទៅជាការទទួលខុសត្រូវចំពោះកំហុសផ្ទាល់ខ្លួនពោលគឺ តាមរយៈអំពើរបស់ខ្លួនវាបានបណ្តាលឱ្យមានព្យសនកម្មលើអ្នកដទៃ។ ចំណែកអំពើអនីត្យានុកូលពិសេសវិញ ក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងច្បាស់អំពីអ្នកដែលមានកាតព្វកិច្ច និងលក្ខខណ្ឌពិសេសក្នុងការទទួលខុសត្រូវ ទោះបីជាព្យសនកម្មនោះមិនបានបង្កឡើងដោយអំពើរបស់ខ្លួនក៏ដោយ ឬហៅម៉្យាងទៀតថាជាការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់អ្នកដទៃ។[៣]

ប៉ុន្តែនៅក្នុងទំហំនៃកិច្ចការស្រាវជ្រាវនេះ យើងនឹងធ្វើការសិក្សាផ្តោតសំខាន់លើតែអំពើអនីត្យានុកូលទូទៅតែប៉ុណ្ណោះ។ ដោយសិក្សាស៊ីជម្រៅទៅលើមុខងារ និងតួនាទីនៃការទទួលខុសត្រូវអំពើអនីត្យានុកូល និងលក្ខខណ្ឌនានារបស់វា។

### ១.១.២ មុខងារ និងតួនាទីនៃអំពើអនីត្យានុកូល

តើប្រព័ន្ធអំពើអនីត្យានុកូលមានមុខងារ និងតួនាទីយ៉ាងដូចម្តេច? ខុសពីក្រមព្រហ្មទណ្ឌដែលមានគោលបំណងដាក់ទោសទណ្ឌចំពោះជនដែលប្រព្រឹត្តខុស ប្រព័ន្ធនៃអំពើអនីត្យានុកូលមានគោលបំណងក្នុងការជួយសង្គ្រោះជនរងគ្រោះឱ្យទទួលបានសំណងមួយដែលសមស្រប ដើម្បីប៉ះប៉ូវចំពោះព្យសនកម្មដែលខ្លួនបានទទួលរងដោយសារតែការធ្វេសប្រហែស ឬដោយចេតនារបស់អ្នកដទៃ។ ដោយពិចារណាលើការខូចខាតទាំងផ្នែកសេដ្ឋកិច្ច ក៏ដូចជាផ្នែកស្មារតីរបស់ជនរងគ្រោះ។ លើសពីនេះទៅទៀតនោះ វាក៏មានមុខងារក្នុងការបង្ការមិនឱ្យមានអំពើអនីត្យានុកូលកើតឡើង ដោយបុគ្គលគ្រប់រូបនឹងមានការប្រុងប្រយ័ត្នជាងមុនព្រោះខ្លួនដឹងថាការធ្វេសប្រហែស ឬមិនបំពេញកាតព្វកិច្ចណាមួយនោះនឹងនាំឱ្យខ្លួនត្រូវទទួលខុសត្រូវសងសំណងការខូចខាតជាមិនខាន។ ប៉ុន្តែនៅក្នុងប្រទេសជប៉ុន ដោយសារតែវិស័យនៃការធានារ៉ាប់រងមានការរីកចម្រើនខ្លាំងជាហេតុធ្វើឱ្យលេចឡើងនូវបញ្ហាថា ប្រព័ន្ធនៃការធានារ៉ាប់រងធ្វើឱ្យការបំពេញមុខងាររបស់អំពើអនីត្យានុកូលមានការចុះខ្សោយ។ ឧទាហរណ៍៖ ប្រសិនបើអ្នកបើកបររថយន្តដោយគ្មានការប្រុងប្រយ័ត្ន ឬធ្វេសប្រហែសនោះវានឹងបង្កគ្រោះថ្នាក់ដល់អ្នកដទៃ ហើយត្រូវទទួលខុសត្រូវសងការខូចខាតចំពោះជនរងគ្រោះនោះ។ ហេតុនេះហើយ ដើម្បីជៀសវាងពីកាតព្វកិច្ចក្នុងការសងការខូចខាតនេះ អ្នកបើកបររថយន្តគ្រប់រូបនឹងបង្កើនការយកចិត្តទុកដាក់ជាងមុនក្នុងអំឡុងពេលបើកបរ ដែលអាចជួយកាត់បន្ថយចំនួននៃគ្រោះថ្នាក់ចរាចរណ៍។ ប៉ុន្តែដោយសារតែការកើតឡើងនៃប្រព័ន្ធធានារ៉ាប់រង វាបែរជាធ្វើឱ្យអ្នកបើកបរមានការធ្វេសប្រហែសជាងមុន ដោយហេតុថាទោះបីជា

[៣] ការទទួលខុសត្រូវដែលបានចាត់ទុកថាជាអំពើអនីត្យានុកូលពិសេសមានចែងនៅក្នុងក្រមរដ្ឋប្បវេណីចាប់ពីមាត្រា៧៤៦ ដល់ មាត្រា ៧៥៣

ខ្លួនបានបង្កគ្រោះថ្នាក់ដល់អ្នកដទៃក៏ដោយ ក៏ខ្លួនមិនមែនជាអ្នកទទួលខុសត្រូវឡើយ ដោយសំអាងថាខ្លួនមានក្រុមហ៊ុនធានារ៉ាប់រងជាអ្នកទទួលខុសត្រូវជំនួស។ ហេតុនេះហើយទើបគេលើកឡើងថាប្រព័ន្ធធានារ៉ាប់រងអាចបង្អាក់មុខងារបង្ការអំពើអនីត្យានុកូលនៃប្រព័ន្ធអំពើអនីត្យានុកូល។[៤] ទោះបីជានៅប្រទេសកម្ពុជាបញ្ហានេះមិនត្រូវបានលើកឡើងក៏ដោយ យើងក៏គួរពិចារណាលើចំណុចនេះផងដែរ ដើម្បីជាការបង្ការការកើតជាបញ្ហានាពេលអនាគត។

## ១.២ លក្ខខណ្ឌនៃអំពើអនីត្យានុកូល

ជនរងគ្រោះអាចទាមទារសំណងដោយផ្អែកលើអំពើអនីត្យានុកូលបានលុះត្រាតែអាចអះអាងអំពីលក្ខខណ្ឌ ៤ គឺ (១)កំហុសចេតនា ឬអចេតនា (២)ភាពផ្ទុយច្បាប់ (៣)ការខូចខាត (៤)ទំនាក់ទំនងហេតុ និងផល ប្រសិនបើខ្វះនូវលក្ខខណ្ឌណាមួយនោះអំពើអនីត្យានុកូលនឹងមិនកើតឡើងឡើយ (ក្រមរដ្ឋប្បវេណីមាត្រា ៧៤៣)។ ហេតុនេះ ប្រសិនបើមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំង៤ខាងលើនេះមិនត្រូវបានបំពេញទេនោះ ក៏មិនត្រូវបានគេចាត់ទុកថាជាអំពើអនីត្យានុកូលដែរ។

### ១.២.១ កំហុសចេតនា ឬអចេតនា

ជាគោលការណ៍កំហុសត្រូវបានបែងចែកជា ២ គឺ កំហុសចេតនា (មាត្រា៧៤២ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី) និងកំហុសអចេតនា (មាត្រា៧៤២ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី)។

**កំហុសចេតនា** គឺសំដៅលើជនដែលប្រព្រឹត្តអំពើនោះអាចដឹង ឬអាចព្យាករទុកជាមុនថាអំពើនោះអាចបង្កអន្តរាយដល់អ្នកដទៃក៏ដោយក៏ខ្លួនព្រមទទួលយកការកើតឡើងនូវលទ្ធផលនោះ។ ឧទាហរណ៍(១)៖ លោក ក និង លោក ខ ដែលជាអ្នកជិតខាងគ្នាតែងតែមានជម្លោះជាមួយគ្នាជាញឹកញាប់ ដោយគំនុំគុំគួនថ្ងៃមួយលោក ក បានយកដុំថ្មគប់ទៅលើលោក ខ ដែលជាហេតុធ្វើឱ្យលោក ខ រងរបួសធ្ងន់ធ្ងរ។ នៅក្នុងអង្គហេតុនេះយើងឃើញថា លោក ក បានព្យាករទុកជាមុនរួចហើយថា ប្រសិនបើខ្លួនគប់ដុំថ្មទៅលើលោក ខ នោះនឹងធ្វើឱ្យរងរបួសជាមិនខាន ប៉ុន្តែលោក ក នៅតែប្រព្រឹត្តទង្វើនោះដោយព្រមទទួលយកនូវលទ្ធផលនោះ។ នេះបង្ហាញយ៉ាងច្បាស់អំពីចេតនារបស់លោក ក ដោយមិនមានការលំបាកក្នុងការពិចារណានោះទេ។

ចំណែក **កំហុសអចេតនា** គឺសំដៅដល់ជនដែលប្រព្រឹត្តអំពើនោះអាចព្យាករទុកជាមុនពីលទ្ធផលនៃអំពើនោះ ប៉ុន្តែនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែសហើយមានករណីយកិច្ចជៀសវាងនូវលទ្ធផលប៉ុន្តែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ។ ឧទាហរណ៍(២)៖ នារី

[៤] សៀវភៅសេចក្តីផ្តើមនៃនីតិរដ្ឋប្បវេណី, តុយុហ៊ីរុ ណុមឹរ៉ាក់, បោះពុម្ពលើកទី៨, ឆ្នាំ២០២៣, ទំព័រ១២៧ (野村豊弘『民事法入門』（有斐閣アルマ、第 8 版補訂版、២០២៣ 年）、១២៧ 項)

កំពុងបើកបររថយន្តបណ្តើរមើលទូរស័ព្ទបណ្តើរ ហើយមិនបានចាប់អារម្មណ៍ភ្លើងស្តុបក្រហម នាងក៏បានជ្រុលទៅបុកនឹងរថយន្តមួយទៀតដែលឈប់នៅខាងមុខ។ នៅក្នុងករណីនេះ នារី មិនមានបំណងចង់ទៅបុកនឹងរថយន្តមួយទៀតឡើយ ប៉ុន្តែដោយសារការធ្វេសប្រហែលរបស់នាងទើបធ្វើឱ្យនាងប្រព្រឹត្តកំហុសនេះឡើងដោយអចេតនា។

នៅក្នុងឧទាហរណ៍(១) យើងឃើញថាជនបង្កមានចេតនាចង់ឱ្យជនរងគ្រោះរងរបួស ហើយជាលទ្ធផលជនរងគ្រោះពិតរងរបួសដូចការគិតទុករបស់ជនបង្កមែន ដូចនេះប្រាកដណាស់ថាជនបង្កនោះត្រូវទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ ផ្ទុយទៅវិញបើយើងក្រឡេកទៅមើលឧទាហរណ៍(២) ខាងលើវិញយើងឃើញថាជនបង្កមិនមានបំណងចង់បើកឡានទៅបុកឡានជនរងគ្រោះឡើយពោលគឺ ដោយសារការធ្វេសប្រហែស ទើបបង្កឱ្យជនរងគ្រោះទទួលរងនូវការខូចខាតដោយអចេតនា។ ទោះបីជាជនបង្កនោះមិនមានបំណងបង្កការខូចខាត ឬវាបង្កឡើងដោយអចេតនាក៏ដោយ ក៏វាមិនបានធ្វើឱ្យជនបង្កនោះរួចផុតពីការទទួលខុសត្រូវឡើយ។ ទោះបីក្នុងករណីឧទាហរណ៍(១) ដែលបង្កឡើងដោយចេតនា និងឧទាហរណ៍(២)ដែលបង្កឡើងដោយអចេនាក៏ដោយ យើងឃើញថាជនរងគ្រោះសុទ្ធតែទទួលរងនូវការខូចខាត (ផ្នែកទ្រព្យសម្បត្តិ និងមិនមែនជាទ្រព្យសម្បត្តិ)។[៥] ហេតុនេះហើយទើបប្រព័ន្ធសំណងដោយផ្អែកលើអំពើអនីត្យានុកូលបានទទួលស្គាល់ទាំងកំហុសចេតនា និងកំហុសអចេតនា។

ខុសពីប្រទេសកម្ពុជាដែលកំណត់យក "កំហុសចេតនា ឬកំហុសអចេតនា" ធ្វើជាលក្ខខណ្ឌនៃអំពើអនីត្យានុកូល ក្រមរដ្ឋប្បវេណីប្រទេសជប៉ុនបានកំណត់យក "ចេតនា ឬកំហុស"[៦] ជាលក្ខខណ្ឌនៃអំពើអនីត្យានុកូល ដែលត្រង់ចំណុចនេះយើងអាចមើលឃើញពីភាពខុសគ្នាក្នុងការប្រើប្រាស់ពាក្យពេចន៍របស់ប្រទេសទាំងពីរ។ ការកំណត់និយមន័យកំហុសយ៉ាងច្បាស់លាស់ជាលក្ខណៈពិសេសរបស់ក្រមរដ្ឋប្បវេណីកម្ពុជា ដោយហេតុថាកំហុសអចេតនាមិនត្រូវបានគេកំណត់និយមន័យទេនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន។[៧] ទ្រឹស្តីនៃកំហុស ត្រូវបានគេពិចារណាលើការមិនប្រុងប្រយ័ត្នរបស់អ្នកធ្វើអំពើនោះ ប៉ុន្តែក្នុងពេលបច្ចុប្បន្ន គេប្តូរមកពិចារណាលើការមិនបំពេញករណីកិច្ចក្នុងការជៀសវាងនូវលទ្ធផលដែលអាចសម្រេចបាន ប្រសិនបើចារីបានព្យាករ និងប្រុងប្រយ័ត្នជាមុន។[៨]

---

[៥] ពន្យល់លម្អិតនៅក្នុងចំណុច១.៣

[៦] មានចែងក្នុងមាត្រា៧០៩ នៃក្រមរដ្ឋប្បវេណីជប៉ុនដែលចេតនាជាភាសាជប៉ុនហៅថា "故意" និងកំហុសជាភាសាជប៉ុនហៅថា "過失"

[៧] ប៉ុន្តែកំហុសចេតនាត្រូវបានកំណត់នៅក្នុងយុត្តិសាស្ត្រ ដែលនិយមន័យដូចប្រទេសកម្ពុជាដែរ

[៨] សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី៦, ទំព័រ ១០៣

### ១.២.២ ភាពផ្ទុយច្បាប់

នៅក្នុងលក្ខខណ្ឌនេះសំដៅដល់ ការបំពានករណីយកិច្ច ឬកាតព្វកិច្ចដែលច្បាប់ ឬបទដ្ឋានគតិយុត្ត បានកំណត់។ ក្នុងការពិចារណាពីភាពមាន ឬគ្មានកំហុស មានទ្រឹស្តីជាច្រើនបានលើកឡើងអំពីការពិចារណា លើប្រភេទសិទ្ធិ និងផលប្រយោជន៍ ដែលត្រូវបានបំពាននោះ។ ក្នុងនោះប្រភេទសិទ្ធិ និងផលប្រយោជន៍អាចត្រូវ បានបែងចែកជា ២ គឺ សិទ្ធិ/ផលប្រយោជន៍ជាទ្រព្យសម្បត្តិ និងមិនមែនជាទ្រព្យសម្បត្តិ។

សិទ្ធិ និងផលប្រយោជន៍ជាទ្រព្យសម្បត្តិត្រូវបានកំណត់នៅក្នុងមាត្រា៧៥៩ នៃក្រមរដ្ឋប្បវេណី និងក្រៅ ពីនេះមានសិទ្ធិដែលប៉ះពាល់ដល់ជីវិត រូបរាងកាយ និងសុខភាពជាដើមផងដែរ(មាត្រា៧៦០, មាត្រា៧៦១ នៃក្រមរដ្ឋប្បវេណី)។ មានន័យថាប្រសិនបើបុគ្គលនោះបានប៉ះពាល់ទៅលើសិទ្ធិអ្នកដទៃដែលត្រូវបានការពារ ដោយច្បាប់ដូចជា ការបង្ករបួសស្នាមទៅលើអ្នកដទៃជាដើមនោះនឹងត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើដោយខុស ច្បាប់។

សិទ្ធិ និងផលប្រយោជន៍មិនមែនជាទ្រព្យសម្បត្តិរាប់បញ្ចូលរាល់ការប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ និងព័ត៌មានឯកជន (មាត្រា៧៦២ នៃក្រមរដ្ឋប្បវេណី) ព្រមទាំងផលប្រយោជន៍ខាងកម្មសិទ្ធិបញ្ញាជាអាទិ៍។ ដូចនេះរាល់អំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃដូចជាការបរិហាកេរ្តិ៍ ឬបង្ខាច់បង្ខូច ឈ្មោះអ្នកដទៃត្រូវចាត់ទុកជាអំពើផ្ទុយច្បាប់។

ឧទាហរណ៍(១)៖ រោងចក្រផលិតស្រាបៀរមួយកន្លែងបានបង្ហូរកាកសំណល់កង្វក់ចូលទៅក្នុងទឹកស្ទឹង ដែលជាហេតុបង្កឱ្យទឹកស្ទឹងរងការបំពុល។ ប្រជាជនរស់នៅជិតនោះដែលតែងប្រើប្រាស់ទឹកស្ទឹងជាប្រចាំត្រូវ បានធ្លាក់ខ្លួនឈឺដោយសារតែកង្វក់ទឹក។ រោងចក្រនោះបានប្រព្រឹត្តអំពើដែលធ្វើឱ្យប៉ះពាល់ដល់សុខភាព ប្រជាជនដែលដែលជាសិទ្ធិខាងរូបរាងកាយ និងសុខភាពជាដើម។ ហេតុនេះហើយលក្ខខណ្ឌនៃភាពខុសច្បាប់ នឹងត្រូវបានបំពេញ។

ឧទាហរណ៍(២)៖ កីឡាករប្រដាល់បានបង្ករបួសស្នាមដល់ដៃគូប្រកួតនៅក្នុងអំឡុងពេលប្រកួត មិនត្រូវ បានគេចាត់ទុកជាអំពើអនីត្យានុកូលទេ ព្រោះកីឡាករអនុវត្តតាមវិធានកំណត់នៅក្នុងការប្រកួត វាមិនមានភាព ខុសច្បាប់ឡើយ។

### ១.២.៣ ការខូចខាត

មិនមែនរាល់ការបំពានសិទ្ធិទាំងអស់សុទ្ធតែអាចទាមទារសំណងបាននោះទេ។ មានន័យថា ទោះបីជា ជននោះបានប្រព្រឹត្តអំពើខុសច្បាប់ក៏ដោយ ប្រសិនបើអំពើនោះមិនបានបង្កឱ្យមានការខូចខាតទេនោះមិនត្រូវ បានគេចាត់ទុកថាអំពើអនីត្យានុកូលឡើយ។

ការខូចខាតត្រូវបានបែងចែកចេញជា ការខូចខាតទ្រព្យសម្បត្តិ និងការខូចខាតសតិអារម្មណ៍។ ការខូចខាតទ្រព្យសម្បត្តិគិតបញ្ចូលទាំង ការខូចខាតសកម្ម (ថ្លៃព្យាបាល ថ្លៃជួសជុល) និងការខូចខាតអកម្ម (បាត់បង់ប្រាក់ចំណូលអំឡុងសម្រាកនៅមន្ទីរពេទ្យ) ។

ឧទាហរណ៍(១)៖ ក បានលួចថតចម្លងសៀវភៅរបស់ ខ ដោយគ្មានការអនុញ្ញាត ហើយបានដាក់លក់សៀវភៅនោះក្រោមតម្លៃទីផ្សារ ជាហេតុធ្វើឱ្យ ខ បាត់បង់ប្រាក់ចំណូល។ នៅក្នុងករណីនេះយើងឃើញថា ក បានរំលោភលើសិទ្ធិអ្នកនិពន្ធដោយខុសច្បាប់[៩] និងបានបង្កការខូចខាតដល់ ខ។ នេះត្រូវចាត់ទុកថាជាអំពើអនីត្យានុកូល។

ឧទាហរណ៍(២)៖ លោក សម្បត្តិ បានយកឡានរបស់ខ្លួនទៅចតទុកនៅលើដីទុកចោលរបស់លោក សាន ដើម្បីរួមផុតពីការចំណាយសម្រាប់ចំណតឡាន។ ក្រោយមកដោយឃើញដូចនេះលោក សាន ក៏មានគំនិតចង់បានប្រាក់ថ្លៃចំណតឡានលើដីរបស់ខ្លួនពីលោក សម្បត្តិ។ ប៉ុន្តែដោយសារចរចារគ្នាមិនត្រូវលោក សាន បែរជាទាមទារសំណងពីលោក សម្បត្តិដោយផ្អែកលើអំពើអនីត្យានុកូលទៅវិញ។

ប្រសិនបើយើងធ្វើការពិចារណាលើឧទាហរណ៍ទី(១) យើងឃើញថាអំពើបំពានរបស់ ក បានធ្វើឱ្យសៀវភៅរបស់ ខ បាត់បង់ទីផ្សារ ដែលធ្វើឱ្យបាត់បង់ប្រាក់ចំណូលដែលជាផលប្រយោជន៍ដែល ខ ត្រូវទទួលបានបើគ្មានអំពើបំពានទេនោះ។ ចំពោះករណីនេះយើងសន្និដ្ឋានបានយ៉ាងងាយថា លក្ខខណ្ឌនៃការខូចខាតត្រូវបានបំពេញ។ ហេតុនេះហើយវាជារឿងត្រឹមត្រូវដែល ខ គួរតែទទួលបានសំណងជួសជុលការខាតបង់ប្រយោជន៍របស់ខ្លួន។ ចំណែកឧទាហរណ៍ទី(២)វិញ យើងឃើញថា ដោយសារតែដីរបស់លោកសានជាដីទុកចោល ដូចនេះទោះបីជាលោក សម្បត្តិ យកឡានរបស់គាត់ទៅចតនៅទីនោះក៏ដោយក៏គ្មានការខូចខាតអ្វីឡើយ ទើបលោក សាន មិនអាចទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលបានឡើយដោយសារខ្វះខាតលក្ខខណ្ឌនៃការខូចខាត។ ប៉ុន្តែប្រសិនបើលោក សាន អាចធ្វើការបញ្ជាក់បានពីការខូចខាតរបស់ខ្លួននោះ វាគ្មានបញ្ហាអ្វីនោះឡើយ។ ហេតុនេះយើងគួរកត់សម្គាល់ចំណុចនេះឱ្យបានច្បាស់មុននឹងធ្វើការទាមទារ ឬសម្រេចអំពីការទទួលស្គាល់ ឬមិនទទួលស្គាល់អំពើអនីត្យានុកូល។

### ១.២.៤ ទំនាក់ទំនងហេតុ និងផល

ជាចុងក្រោយ ការកើតឡើងនៃការខូចខាតដោយអំពើអនីត្យានុកូលនោះ គប្បីត្រូវតែមានទំនាក់ទំនងហេតុ និងផល។ មានន័យថា ប្រសិនបើមិនមានអំពើអនីត្យានុកូលទេ នោះការខូចខាតក៏មិនកើតឡើងដែរ។

[៩] ត្រូវបានចាត់ទុកជាអំពើបំពានលើសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធដែលមានកំណត់នៅក្នុងមាត្រា ២១ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

នៅក្នុងការកំណត់ពីទំនាក់ទំនងហេតុ និងផលនេះអាចមានការលំបាកខ្លាំងចំពោះជនរងគ្រោះក្នុងការបញ្ជាក់។ ការបញ្ជាក់អំពីទំនាក់ទំនងហេតុ និងផលនេះមានការលំបាកខ្លាំង ជាពិសេសក្នុងករណីដែលការបំពាននោះជាការបំពានខាងទ្រព្យអរូបី។ ប៉ុន្តែវាក៏មិនបានន័យថាការបំពានទ្រព្យរូបីមិនមានការលំបាកក្នុងការបញ្ជាក់ឡើយ។ ឧទាហរណ៍៖ លោក ក បានជូនដំណើរកូនស្រីរបស់ខ្លួនដែលត្រូវទៅបន្តការសិក្សានៅក្រៅប្រទេស ហើយអំឡុងពេលលោកត្រឡប់មកផ្ទះវិញលោកក៏បានជួបបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលបានបង្កឡើងដោយលោក ខ ។ ដោយសារតែលោក ក មិនមានសាច់ញាត្តិណាក្រៅពីកូនស្រីឡើយ ទើបតម្រូវឱ្យកូនស្រីរបស់ខ្លួនត្រូវត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីមើលថែឪពុក។ ក្នុងករណីនេះ តើលោក ក អាចទាមទារលោក ខ នូវថ្លៃសំបុត្រយន្តហោះ ព្រមទាំងការខាតបង់ពេលវេលានៃការរៀនសូត្រដែលកូនស្រីរបស់ខ្លួនបានខាតបង់ដោយសារត្រូវមកមើលថែខ្លួនដែរ ឬទេ? តើការទាមទារនេះត្រូវបានទទួលស្គាល់ថាស្ថិតនៅក្នុងទំហំនៃទំនាក់ទំនងហេតុ និងផលរវាងអំពើបំពាន និងការខូចខាតដែរ ឬទេ? ប្រសិនបើមានករណីនេះមែនគឺមានតែរង់ចាំមើលការបកស្រាយរបស់ចៅក្រមប៉ុណ្ណោះ ប៉ុន្តែដោយសារការដាក់បង្ហាញសេចក្តីសម្រេចជាសាធារណៈនៅប្រទេសកម្ពុជាមិនទាន់មានការបើកទូលំទូលាយនៅឡើយទេនោះ វាក៏មានការលំបាកផងដែរសម្រាប់ការកំណត់ឱ្យបានច្បាស់លាស់ពីយុត្តិសាស្ត្រដោះស្រាយចំពោះបញ្ហានេះ។ នេះគ្រាន់តែជាការលើកជាឧទាហរណ៍បង្ហាញពីផលវិបាកក្នុងការបញ្ជាក់អំពីទំនាក់ទំនងហេតុ និងផលចំពោះអំពើបំពានដែលយើងអាចមើលឃើញជាក់ស្តែងនូវការខូចខាតតែប៉ុណ្ណោះ។ ប្រសិនបើការបំពានដែលយើងអាចមើលឃើញជាក់ស្តែងវាពិបាកក្នុងការបញ្ជាក់ហើយ នោះការបំពានអរូបីដូចជា ការបាត់បង់ទីផ្សារ ឬអតិថិជន វានឹងមិនមានការលំបាកក្នុងការបង្ហាញទេឬ? ឧទាហរណ៍៖ នៅពេលដែលស្នាដៃប្រលោមលោករបស់អ្នកនិពន្ធម្នាក់ត្រូវបានគេចតចម្លង និងបោះពុម្ពផ្សាយដោយគ្មានការអនុញ្ញាត នោះវាជាការបំពានដល់សិទ្ធិកម្មសិទ្ធិបញ្ញា (សិទ្ធិអ្នកនិពន្ធ[១០]) ដែលជាហេតុនាំឱ្យស្នាដៃដើមបាត់បង់ទីផ្សារ ហេតុនេះហើយអ្នកនិពន្ធអាចមានសិទ្ធិទាមទារសំណងការខូចខាតបានដោយផ្អែកលើអំពើអនីត្យានុកូល។ ប៉ុន្តែអ្នកនិពន្ធត្រូវធ្វើយ៉ាងណាបញ្ជាក់ឱ្យបានថា ដោយសារតែមានអំពើរំលោភសិទ្ធិរបស់ខ្លួនទើបធ្វើឱ្យខ្លួនបាត់បង់ទីផ្សារ និងខាតចំណូល។ មិនត្រឹមតែសិទ្ធិ កម្មសិទ្ធិបញ្ញាប៉ុណ្ណោះទេ ដែលមានការលំបាកក្នុងការអះអាងនោះ ហេតុនេះហើយទើបយុត្តិសាស្ត្រតុលាការជប៉ុនមួយចំនួនបកស្រាយអនុគ្រោះចំពោះលក្ខខណ្ឌនេះ។[១១] ប៉ុន្តែថាការបកស្រាយដោយអនុគ្រោះនោះ ឈរលើគោលការណ៍ ឬពិចារណាលើអ្វីខ្លះនោះគឺមានតែរង់ចាំមើលសេចក្តីសម្រេចរបស់តុលាការតែប៉ុណ្ណោះ។

---

[១០] ច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣, មាត្រា២១

[១១] អ៊ីកិដា ម៉ាសាអុ, សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី៦, ទំព័រ ១០៥

## ១.៣ អានុភាពនៃអំពើអនីត្យានុកូល

ក្នុងជំពូកទី១ យើងបានយល់ច្បាស់អំពីអនីត្យានុកូល និងលក្ខខណ្ឌរបស់វារួចមកហើយ បន្ទាប់ពីនេះ យើងនឹងសិក្សាលើអានុភាពរបស់វា។ ប្រសិនបើលក្ខខណ្ឌទាំង ៤ ដូចបានរៀបរាប់ខាងលើនេះត្រូវបាន បំពេញ នោះអំពើអនីត្យានុកូលត្រូវបានសន្និដ្ឋានថាកើតឡើង ហើយនឹងនាំឱ្យកើតមាននូវអនុភាពពោលគឺ ការសងសំណងការខូចខាត។ ដើម្បីជាជំនួយក្នុងការបកស្រាយនៅបញ្ហាប្រឈមដែលនឹងត្រូវលើកឡើងនៅ ពេលក្រោយ ក្នុងជំពូកនេះយើងនឹងធ្វើការសិក្សាខ្លះៗអំពីការទទួលបានសំណងនៃការខូចខាត (ចំណុច១.៣.១) និងមូលដ្ឋានខ្លះៗក្នុងការគណនាសំណងការខូចខាត (ចំណុច១.៣.២) ។

### ១.៣.១ សំណងការខូចខាត

ដូចមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៧៥៧ កថាខណ្ឌ១ ជាគោលការណ៍សំណងដោយផ្អែក លើអំពើអនីត្យានុកូលត្រូវគិតជាប្រាក់។ កម្មវត្ថុនៃការសងការខូចខាតមានការខូចខាតទ្រព្យសម្បត្តិ ក៏ដូចជាការ ខូចខាតផ្នែកសតិអារម្មណ៍ផងដែរ។ ក្នុងការគណនាចំនួនទឹកប្រាក់ផ្អែកលើការខូចខាតផ្នែកសតិអារម្មណ៍មាន ការលំបាកខ្លាំង ព្រោះថាមនុស្សម្នាក់ៗមានមនោសញ្ចេតនាមិនដូចគ្នាទេ ដែលជាហេតុធ្វើឱ្យរឿងខ្លះដែល មនុស្សមួយចំនួនឈឺចាប់ បែរជាមានមនុស្សមួយចំនួនទៀតគិតថាវាជារឿងតូចតាចទៅវិញ។ ទោះបីជាការ សម្រេចពីសំណងមានការលំបាកយ៉ាងណាក៏ដោយ ក៏ចៅក្រមអាចធ្វើការសម្រេចដោយពិចារណាទៅលើ កត្តាមួយចំនួនដូចជា ឋានៈក្នុងសង្គម សីលធម៌ ទំនៀមទម្លាប់ក្នុងសង្គម គោលការណ៍សមធម៌។ល។ ប៉ុន្តែ ចំពោះករណីដែលសំណងមិនអាចគិតជាប្រាក់បាននោះជនរងគ្រោះអាចទទួលបានការសង្គ្រោះតាមរយៈ ការធ្វើបដិទាន ឬអាចទាមទារមិនឱ្យធ្វើសកម្មភាពណាមួយបាន។

ក្រៅពីសំណងនៃការខូចខាត ប្រសិនបើអំពើបំពាននោះនាំឱ្យមានការប៉ះពាល់ដល់កិត្តិយស កេរ្តិ៍ឈ្មោះ របស់បុគ្គល គេអាចអនុវត្តវិធានការស្តារកិត្តិយសឡើងវិញបានដោយជនរងគ្រោះអាចទាមទារឱ្យជនបង្កសុំ ទោសជាសាធារណៈចំពោះការបរិហារកេរ្តិ៍នោះ។ ក្នុងករណីប្រទេសជប៉ុនតុលាការអាចចេញសេចក្តីបង្គាប់ជន ដែលប្រព្រឹត្តនោះចុះផ្សាយនៅលើទំព័រសារព័ត៌មាន ដើម្បីកែតម្រូវ និងស្តារកិត្តិយសរបស់ជនរងគ្រោះឡើងវិញ (មាត្រា៧២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន)។

### ១.៣.២ ទំហំនៃសំណងការខូចខាត

នៅក្នុងក្រមរដ្ឋប្បវេណីមិនមានបញ្ញត្តិណាមួយដែលបានកំណត់ពីវិសាលភាពនៃសំណងការខូចខាត នោះទេ ហេតុនេះហើយជាគោលការណ៍កម្មវត្ថុនៃការខូចខាតត្រូវបានគេចាត់ទុកជាសំណងការខូចខាត។ ការកំណត់ទំហំនៃសំណងការខូចខាតនេះ ចាំបាច់ត្រូវតែពិចារណាពីទំហំសមស្របមួយដែលជនរងគ្រោះគប្បី

ទទួលបាន ព្រមជាមួយគ្នានឹងទំហំដែលសាកសមនឹងអំពើល្មើស។ ពោលគឺ ទោះបីជាអំពើអនីត្យានុកូលមានគោលដៅក្នុងការជួយសង្គ្រោះជនរងគ្រោះក៏ដោយ ប៉ុន្តែប្រព័ន្ធនេះក៏មិនគាំទ្រការទាមទារលើសប្រមាណរបស់ជនរងគ្រោះនោះដែរដូចជា ការដកចេញនូវការទាមទារក្រៅច្បាប់ ការទូទាត់កំហុស ជាដើម។ ហេតុនេះហើយទើបលក្ខខណ្ឌនៃអំពើអនីត្យានុកូលតម្រូវឱ្យបញ្ជាក់អំពីទំនាក់ទំនងហេតុ និងផលរវាងអំពើល្មើស និងការខូចខាត។ ការកំណត់ពីទំហំនៃសំណងការខូចខាតនេះ អាចនឹងមិនចោទជាបញ្ហាប៉ុន្មាននោះទេ ប្រសិនបើការខូចខាតនោះជាការខូចខាតជាក់ស្តែង ឬការខូចខាតជាទ្រព្យសម្បត្តិ ព្រោះការខូចខាតខាងទ្រព្យរូបីវាមានភាពងាយស្រួលក្នុងការកំណត់អំពីតម្លៃនៃទ្រព្យនោះ។ ប៉ុន្តែប្រសិនបើក្នុងករណីដែលការខូចខាតនោះ ជាការខូចខាតខាងផ្នែកស្មារតី ឬការខូចខាតទ្រព្យអរូបីវិញដូចជា ការប៉ះពាល់កេរ្តិ៍ឈ្មោះ ឬកម្មសិទ្ធិបញ្ញាជាដើម វានឹងមានការលំបាកខ្លាំងក្នុងការកំណត់។

### ១.៣.៣ ការទូទាត់កំហុស

នៅពេលសម្រេចពីចំនួនទឹកប្រាក់នៃការខូចខាតចៅក្រមក៏ត្រូវពិចារណាផងដែរអំពីកំហុសរបស់ជនរងគ្រោះ ព្រោះថាក្នុងករណីខ្លះការខូចខាតកើតមានឡើងដោយសារសកម្មភាពរបស់ជនរងគ្រោះផងដែរ។ ហេតុនេះហើយ ប្រសិនបើយើងឱ្យជនបង្កទទួលខុសត្រូវលើការខូចខាតនោះទាំងស្រុងវាហាក់ដូចជាមិនស្មើភាពគ្នាឡើយ។ ដើម្បីឱ្យមានភាពស្មើគ្នាក្នុងការទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន នោះក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីការកាត់កងគ្នានៃកំហុសរបស់ជនរងគ្រោះផងដែរ ហៅថា "**ការទូទាត់កំហុស**"។

ឧទាហរណ៍៖ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍មួយ ដែលឡានបានបើកលើសល្បឿនកំណត់ហើយក៏បានជ្រុលទៅបុកនឹងម៉ូតូដែលជិះបត់ភ្លាមៗដោយមិនបានស៊ីញ៉ូ។ នៅក្នុងករណីនេះ ប្រាកដណាស់ថាម្ចាស់ឡានត្រូវទទួលខុសត្រូវសងការខូចខាតចំពោះម្ចាស់ម៉ូតូ។ ប៉ុន្តែក្នុងរឿងនេះ ម្ចាស់ម៉ូតូក៏បានចូលរួមចំណែកខុសផងដែរ ដោយបានបត់ម៉ូតូភ្លាមៗដោយមិនបានផ្តល់សញ្ញាជាមុន។ ប្រសិនបើតុលាការទទួលស្គាល់ថាក្នុងករណីនេះ ម្ចាស់ឡានមានកំហុស ៨០% ហើយម្ចាស់ម៉ូតូមានកំហុស ២០% នោះសំណងការខូចខាតដែលម្ចាស់ឡានត្រូវសងក៏ត្រូវកាត់កងតាមនោះដែរ។ ដូចនេះប្រសិនបើសន្មតថា សំណងការខូចខាតសរុបមានចំនួន ១០០០ ដុល្លារ នោះម្ចាស់ឡានត្រូវសងតែ ៨០០ ដុល្លារប៉ុណ្ណោះទៅម្ចាស់ម៉ូតូ។

### ១.៣.៤ មូលដ្ឋាននៃការគណនាសំណងការខូចខាត

នៅក្នុងការសម្រេចពីចំនួននៃប្រាក់សំណងមានការលំបាកខ្លាំងសម្រាប់ចៅក្រម ហេតុនេះហើយក្រមរដ្ឋប្បវេណីបានកំណត់នូវមូលដ្ឋានមួយចំនួនដើម្បីជាជំនួយដល់ចៅក្រមក្នុងការគណនាសំណងការខូចខាត

នេះ។ ជាក់ស្តែងយើងឃើញមានបញ្ញត្តិនៃមាត្រា៧៥៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា ដែលបញ្ញត្តិអំពីការគណនាចំនួនទឹកប្រាក់នៃការខូចខាត៖

*១-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតលើទ្រព្យសម្បត្តិដោយសារអំពើអនីត្យានុកូល ភាពខុសគ្នារវាងស្ថានភាពនៃទ្រព្យសម្បត្តិដែលត្រូវ បានសន្មតថា នឹងមានប្រសិនបើគ្មានអំពើអនីត្យានុកូល និងស្ថានភាពនៃទ្រព្យសម្បត្តិជាក់ស្តែងក្រោយពេល ដែលអំពើអនីត្យានុកូលបានកើតឡើង ត្រូវបានវាយតម្លៃដោយប្រើប្រាស់នូវស្ថិតិ និងឯកសារផ្សេងទៀត ។*

*២-ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាត សតិអារម្មណ៍ដោយសារអំពើអនីត្យានុកូលចំនួនទឹកប្រាក់នៃជម្ងឺចិត្ត ត្រូវបានវាយតម្លៃដោយគិតពិចារណានូវស្ថានភាពផ្សេងៗដូចជាកម្រិតនៃកំហុសចេតនា ឬអចេតនារបស់អ្នកប្រព្រឹត្តអំពើបំពានប្រភេទ និងកម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបង្កឱ្យមានការរងគ្រោះនោះ។*

ដូចមានចែងក្នុងបញ្ញត្តិខាងលើនេះ ជនរងគ្រោះអាចទទួលបាននូវសំណងការខូចខាតទ្រព្យសម្បត្តិ និងការខូចខាតដែលមិនមែនជាទ្រព្យសម្បត្តិ (សំណងជម្ងឺចិត្ត) ។ ដែលក្នុងនោះផងដែរសំណងការខូចខាតទ្រព្យសម្បត្តិត្រូវបានបែងចែកជាការខូចខាតសកម្ម និងការខូចខាតអកម្ម។

### ១.៣.៤.១ ការខូចខាតទ្រព្យសម្បត្តិ

យោងតាមមាត្រា៧៥៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ទ្រឹស្តីនៃការប្រៀបធៀបស្ថានភាពទ្រព្យសម្បត្តិត្រូវបានយកមកអនុវត្ត។ ហេតុនេះហើយគេនឹងធ្វើការពិចារណាលើស្ថានភាពនៃទ្រព្យសម្បត្តិប្រសិនបើគ្មានអំពើអនីត្យានុកូល និងស្ថានភាពនៃទ្រព្យសម្បត្តិក្រោយពេលមានអំពើអនីត្យានុកូល។ ដូចបានបញ្ជាក់ខាងលើនេះផងដែរ ការខូចខាតសកម្ម ដែលក្នុងនោះរួមមាន ការបាត់បង់វត្ថុ ការបាក់បែកវត្ថុ ការបង្ករបួសស្នាម ឬការប៉ះពាល់ដល់អាយុជីវិតជាដើម ដោយបន្ថែមលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ នឹងក្លាយជាមូលដ្ឋានមួយក្នុងការគណនាសំណងខូចខាតផងដែរ។

ឧទាហរណ៍៖ ប្រសិនបើជនបង្កបានធ្វើឱ្យទូរស័ព្ទរបស់ជនរងគ្រោះខូចហើយមិនអាចជួសជុលបាននោះ ជនរងគ្រោះត្រូវសងប្រាក់ដែលស្មើនឹងតម្លៃនៃទូរស័ព្ទដែលមានប្រភេទដូចគ្នា គុណភាពដូចគ្នាទៅឱ្យជនរងគ្រោះ ប៉ុន្តែប្រសិនបើការធ្វើឱ្យខូចខាតនោះអាចជួសជុលបាន ចំនួនទឹកប្រាក់ដែលជាសាហ៊ុយជួសជុលនោះនឹងក្លាយទៅជាចំនួននៃសំណងការខូចខាតសកម្ម។[១២]

[១២] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៧៥៩

ចំពោះការខូចខាតអកម្មដែលបង្កឡើងពីការបំពានលើរូបរាងកាយ ឬអាយុជីវិតវិញនោះ សោហ៊ុយពេទ្យ ឬសោហ៊ុយធ្វើបុណ្យសពនឹងក្លាយជាមូលដ្ឋានក្នុងការគណនាសំណង។ ឧទាហរណ៍៖ ដោយសារតែអំពីរបស់ជនបង្កបានធ្វើឱ្យជនរងគ្រោះរងរបួសត្រូវសម្រាកនៅមន្ទីរពេទ្យ ហេតុនេះហើយជនបង្កនោះត្រូវរ៉ាប់រងនូវរាល់សោហ៊ុយពេទ្យទាំងថ្លៃព្យាបាល និងរាល់ចំណាយសម្រាកនៅមន្ទីរពេទ្យ។[១៣] លើសពីនេះការបាត់បង់ប្រាក់ចំណូល ឬប្រយោជន៍ដែលបាត់បង់ដោយសារមរណភាព ក៏នឹងត្រូវបានគេលើកយកមកពិចារណាផងដែរ ព្រោះថាប្រសិនបើមិនមានអំពើអនីត្យានុកូលទេនោះ ជនរងគ្រោះនឹងទទួលបាននូវអត្ថប្រយោជន៍ទាំងអស់នោះ។

បើប្រៀបធៀបជាមួយការគណនាការខូចខាតសកម្ម ការគណនាលើការខូចខាតអកម្មវាមានភាពលំបាកក្នុងការកំណត់អំពីចំនួនជាក់លាក់មួយ ព្រោះតុលាការត្រូវធ្វើការពិចារណាទៅលើកត្តាផ្សេងៗជាច្រើន។ ឧទាហរណ៍៖ ក្នុងករណីដែលជនរងគ្រោះខកខានមិនអាចបំពេញការងាររបស់ខ្លួនបានដោយសារត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬដោយសារតែមរណភាពនោះ ចំណូលមូលដ្ឋាននៅមុនអំពើអនីត្យានុកូលនឹងក្លាយជាមូលដ្ឋានក្នុងការគណនាសំណង។ ក្រៅពីនេះតុលាការអាចធ្វើការពិចារណាលើស្ថានភាពជាក់ស្តែងមួយចំនួនទៀតហើយអាចអនុវត្តតាមរូបមន្តនេះ៖ ប្រាក់ចំណូលមូលដ្ឋានគុណម្រិតនៃការបាត់បង់សមត្ថភាពការងារគុណនឹងអំឡុងពេលដែលជនរងគ្រោះអាចធ្វើការរហូតដល់ពេលចូលនិវត្តន៍។[១៤]

### ១.៣.៤.២ ការខូចខាតក្រៅពីទ្រព្យសម្បត្តិ

ក្រៅពីសំណងដែលជនបង្កបានធ្វើឱ្យខូចខាតលើទ្រព្យសម្បត្តិ ជនរងគ្រោះអាចទាមទារសំណងជម្ងឺចិត្តបន្ថែមពីលើនេះបានដោយហេតុថាការជួសជុលនូវការខូចខាតលើទ្រព្យសម្បត្តិតែមួយមុខមិនទាន់គ្រប់គ្រាន់ឡើយចំពោះលទ្ធផលដែលខ្លួនបានទទួលដោយសារតែអំពើអនីត្យានុកូលនោះ។ ឧទាហរណ៍៖ លោក ក បានធ្វើឱ្យទូរស័ព្ទរបស់កញ្ញា ខ ខូចហើយគ្មានលទ្ធភាពក្នុងការជួសជុលឡើងវិញឡើយ។ ហេតុនេះហើយលោក ក ត្រូវសងសំណងដែលជាទឹកប្រាក់ស្មើនឹងតម្លៃទូរស័ព្ទនៅលើទីផ្សារដែលមានម៉ូដែល និងគុណភាពដូចគ្នាទៅនឹងទូរស័ព្ទរបស់កញ្ញា ក ។ ប៉ុន្តែនៅក្នុងទូរស័ព្ទរបស់កញ្ញា ក មានផ្ទុកនូវឯកសារសំខាន់ៗជាច្រើន ជាពិសេសនោះគឺ រូបថតអនុស្សាវរីយ៍រវាងនាង និងគ្រួសារនាងជាច្រើនដែលជាហេតុធ្វើឱ្យកញ្ញា ក មានការសោកស្តាយយ៉ាងខ្លាំង។ ហេតុនេះហើយ គ្រាន់តែការសងសំណងជាទឹកប្រាក់ដែលស្មើនឹងតម្លៃទូរស័ព្ទរបស់នាងមិនគ្រប់គ្រាន់នោះទេ ទើបបញ្ញត្តិច្បាប់បានកំណត់បន្ថែមអំពីការទាមទារសំណងជម្ងឺចិត្ត។

[១៣] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៧៦០, ៧៦១

[១៤] មេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២, ក្រសួងយុត្តិធម៌, ឆ្នាំ២០១៦, ទំព័រ២២១

ប៉ុន្តែការទាមទារសំណងជម្ងឺចិត្តវាមានភាពស្មុគស្មាញខ្លាំង ព្រោះថាវាត្រូវពិចារណាលើមនោសញ្ចេតនារបស់ជនរងគ្រោះ ឬការខូចខាតផ្លូវចិត្តដែលជនរងគ្រោះត្រូវទទួលរង។ ចំពោះមនុស្សម្នាក់ៗការគិត និងមនោសញ្ចេតនាគឺ មិនដូចគ្នាទេ ហេតុនេះហើយក្នុងករណីមួយចំនួនទោះបីជាសកម្មភាពនោះជនរងគ្រោះអះអាងថាវាធ្វើឱ្យខ្លួនរងការប៉ះទង្គិចធ្ងន់ធ្ងរក៏ដោយ តែសម្រាប់អ្នកដទៃវាបែរជាក្លាយជារឿងតូចតាចទៅវិញ។ ហេតុនេះហើយក្នុងការសម្រេចអំពីចំនួនសំណងនៃជម្ងឺចិត្តវាជាឆន្ទានុសិទ្ធិរបស់ចៅក្រម។ សម្រាប់ជាមូលដ្ឋានក្នុងការគណនាចៅក្រមអាចពិចារណាលើធាតុផ្សំមួយចំនួនដូចជា កម្រិតនៃកំហុសនៃអំពើបំពាន ប្រភេទ និងកម្រិតនៃការខូចខាត ព្រមទាំងសកម្មភាពរបស់អ្នកប្រព្រឹត្តអំពើបំពាននៅក្រោយអំពើបំពាន (ការភ្ញាក់រលឹក) ជាដើម ហើយកំណត់នូវសំណងមួយដែលសមរម្យសម្រាប់ជនរងគ្រោះ។

# ជំពូកទី២

# ទិដ្ឋភាពទូទៅនៃកម្មសិទ្ធិបញ្ញា

# ជំពូកទី២
# ទិដ្ឋភាពទូទៅនៃកម្មសិទ្ធិបញ្ញា

## ២.១ ប្រវត្តិនៃកម្មសិទ្ធិបញ្ញា

កម្មសិទ្ធិបញ្ញាត្រូវបានការការពារក្រោមកិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗចំនួនពីរគឺ អនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៨៨៣ និងអនុសញ្ញាទីក្រុងប៊ែន ឆ្នាំ១៨៨៦ ដែលត្រូវបានទទួលស្គាល់ថាជាបទដ្ឋានគតិយុត្តិអន្តរជាតិដ៏មានឥទ្ធិពល។ នៅអឺរ៉ុបកម្មសិទ្ធិបញ្ញាត្រូវបានការពារដោយច្បាប់តាំងពីយូរលង់ណាស់មកហើយ ដោយឈរលើគោលការណ៍នៃកិច្ចព្រមព្រៀងអន្តរជាតិនានា។ ចំណែកប្រទេសកម្ពុជាវិញដោយសារឆ្លងកាត់នូវសង្គ្រាមជាច្រើនឆ្នាំបានធ្វើឱ្យសេដ្ឋកិច្ចប្រទេសជាតិធ្លាក់ចុះ មិនត្រឹមតែប៉ុណ្ណោះប្រព័ន្ធច្បាប់ស្ទើរតែទាំងស្រុងត្រូវបានបំផ្លាញចោល។ ហេតុនេះហើយការស្តារប្រទេសជាតិឡើងវិញចាំបាច់ត្រូវការពេលវេលា និងការជួយជ្រោមជ្រែងពីសំណាក់អង្គការអន្តរជាតិជាដើម។ ក្នុងនោះប្រទេសកម្ពុជាបានសម្រេចចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) [១៥] ដោយសង្ឃឹមថាអាចស្តារសេដ្ឋកិច្ចប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើងវិញ។ សម្រាប់កម្ពុជាការចូលជាសមាជិកនៃអង្គការអន្តរជាតិនេះការកសាងនីតិកម្មសិទ្ធិបញ្ញាត្រូវបានក្លាយជាលក្ខខណ្ឌតម្រូវមួយដ៏ចាំបាច់ដែលប្រទេសកម្ពុជាត្រូវតែបំពេញ។ ហេតុនេះហើយទើបប្រទេសកម្ពុជាចាប់ផ្តើមកសាងនូវនីតិកម្មសិទ្ធិបញ្ញានេះឡើងដោយមានជំនួយពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)។[១៦] រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានច្បាប់ទាក់ទងនឹងកម្មសិទ្ធិបញ្ញាចំនួន៥ ដែលរួមមាន៖

- ច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់[១៧] ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ (របស់ក្រសួងពាណិជ្ជកម្ម)
- ច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាកម្ម[១៨] ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ (របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល)
- ច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល[១៩] ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ (របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ)

---

[១៥] កម្ពុជាបានចូលជាសមាជិកទី១៤៨ នៃអង្គការពាណិជ្ជកម្មពិភពលោកនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៣

[១៦] កម្ពុជាបានចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥

[១៧] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០០៦, ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២

[១៨] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣

[១៩] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨, ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣

- ច្បាប់ ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ[២០] ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ (របស់ក្រសួងកសិកម្ម)
- ច្បាប់ ស្តីពីម៉ាក់សម្គាល់ភូមិសាស្ត្រទំនិញ[២១] ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ (របស់ក្រសួងពាណិជ្ជកម្ម)

លទ្ធផលទាំងនេះឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកសាង និងអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ។ ប៉ុន្តែប្រសិនបើប្រៀបធៀបជាមួយប្រទេសដទៃទៀតនីតិកម្មសិទ្ធិបញ្ញានេះហាក់ដូចជានៅថ្មីនៅឡើយសម្រាប់ប្រទេសកម្ពុជា។ ហេតុនេះហើយ ការអនុវត្តអាចនៅមានភាពខ្វះចន្លោះ និងមិនទាន់មានប្រសិទ្ធិភាពនៅឡើយទេ។

### ២.១.១ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

កម្មសិទ្ធិបញ្ញាសំដៅដល់សិទ្ធិអរូបីដែលកើតឡើងដោយបញ្ញារបស់មនុស្សដែលក្នុងនោះបែងចែកជា២ប្រភេទធំៗគឺ សិទ្ធិឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធ។ ប៉ុន្តែដូចបានបញ្ជាក់ជូនពីខាងដើម នៅក្នុងកិច្ចការស្រាវជ្រាវនេះ នាងខ្ញុំសូមធ្វើការកំណត់យកត្រឹមច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលប៉ុណ្ណោះជាវិសាលភាពនៃការស្រាវជ្រាវ។ ដោយសារនៅក្នុងសង្គមកម្ពុជាជាក់ស្តែង ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនេះហាក់ដូចជាមិនសូវទទួលបាននូវការយកចិត្តទុកដាក់ និងអនុវត្តឱ្យមានប្រសិទ្ធភាពប៉ុន្មានទេ។ ការហ៊ានលើកឡើងបែបនេះគឺ ដោយសារតែការមើលឃើញជាញឹកញាប់តាមរយៈព័ត៌មានអំពីការរំលោភសិទ្ធិអ្នកនិពន្ធដោយខុសច្បាប់ ប៉ុន្តែចំពោះដំណោះស្រាយវិញគេបែរជាមើលឃើញត្រឹមតែជាការព្រមានពីសំណាក់ក្រសួងពាក់ព័ន្ធប៉ុណ្ណោះ។[២២] តាមរយៈការមើលឃើញបែបនេះ អាចធ្វើឱ្យសិទ្ធិរបស់ម្ចាស់ស្នាដៃមិនអាចត្រូវបានការពារដោយមានប្រសិទ្ធិភាពតាមច្បាប់ឡើយ ដោយហេតុថាគ្រាន់តែសុំទោសពីជនល្មើសនោះរឿងនឹងត្រូវបានបញ្ចប់។[២៣]

ដើម្បីជាជំនួយដល់ការបកស្រាយ ជាដំបូងយើងនឹងធ្វើការសិក្សាពីចំណោះមូលដ្ឋានខ្លះៗ ស្តីអំពីសិទ្ធិអ្នកនិពន្ធនេះ។ សិទ្ធិអ្នកនិពន្ធសំដៅលើ សិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធ (អ្នកសរសេរសៀវភៅ អ្នកតែងបទទំនុក

[២០] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨

[២១] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

[២២] ការការពារសិទ្ធិអ្នកនិពន្ធត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

[២៣] ការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមិនទាន់មានប្រសិទ្ធិភាពពេញលេញនៅកម្ពុជា, គេហទំព័រ AMS, ចុះផ្សាយថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១

ច្រៀងជាដើម) ទៅលើស្នាដៃដែលកើតចេញពីការច្នៃប្រឌិត គំនិតប្រាជ្ញារបស់ខ្លួន។ សិទ្ធិដែលអ្នកនិពន្ធមានលើស្នាដៃរបស់ខ្លួនត្រូវបានបែងចែកជា ២ គឺ សិទ្ធិបេតិកភណ្ឌ[២៤] (សិទ្ធិសេដ្ឋកិច្ច) និងសិទ្ធសីលធម៌[២៥]។

សិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធត្រូវបានការពារដោយធានាពីការធ្វើអជីវកម្មស្វែងរកប្រាក់ចំណូលរបស់ម្ចាស់សិទ្ធិ។ ប្រសិនបើបុគ្គលណាម្នាក់បានយកស្នាដៃរបស់ម្ចាស់សិទ្ធិទៅធ្វើអាជីវកម្មរកប្រាក់ចំណេញក្នុងនាមប្រយោជន៍ផ្ទាល់ខ្លួននោះ ត្រូវបានចាត់ទុកថារំលោភសិទ្ធិបេតិកភណ្ឌរបស់អ្នកនិពន្ធ ព្រោះវាអាចបង្កឱ្យម្ចាស់ស្នាដៃបាត់បង់មិនអាចទទួលបាននូវចំណូលផ្ទាល់ខ្លួន។

ក្រៅពីការបំពានដែលធ្វើឱ្យបាត់បង់ចំណូលរបស់ម្ចាស់សិទ្ធិហើយនោះ ការបំពានទាំងឡាយណាដែលបណ្តាលឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកនិពន្ធនឹងត្រូវចាត់ទុកជាអំពើរំលោភសិទ្ធិសីលធម៌ផងដែរ។ រាល់អំពើនៃការកែប្រែខ្លឹមសារ បន្ថែមខ្លឹមសារ ឬលុបឈ្មោះអ្នកនិពន្ធចេញពីស្នាដៃជាដើម ត្រូវបានហាមឃាត់ដោយច្បាប់។

ប្រសិនបើមានអំពើរំលោភសិទ្ធិអ្នកនិពន្ធកើតឡើង បុគ្គលប្រព្រឹត្តនោះត្រូវទទួលទោសទណ្ឌដែលស្តែងឡើងក្នុងទម្រង់ជាទោសពិន័យដែលមានចំនួនទឹកប្រាក់ចន្លោះពី ១ ០០០ ០០០រៀល (មួយលានរៀល) ទៅ ២៥ ០០០ ០០០រៀល (ម្ភៃប្រាំលានរៀល) ឬពិន័យជាប់ពន្ធនាគារចន្លោះពី ៦ខែ (ប្រាំមួយខែ) ដល់ ១២ខែ (ដប់ពីរខែ)។ បន្ថែមពីលើនេះ ជនរងគ្រោះអាចទាមទារសំណងរដ្ឋប្បវេណីណាមួយចំពោះការខូចខាតរបស់ខ្លួនបាន[២៦]។

គួរបញ្ជាក់ផងដែរថា នៅក្នុងក្របខណ្ឌអន្តរជាតិកម្មសិទ្ធិខាងអក្សរសាស្ត្រនេះត្រូវបានការពារដោយអនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦ វិសោធនកម្មឆ្នាំ១៩៧៩ ឬហៅកាត់ថា អនុសញ្ញាទីក្រុងប៊ែន។[២៧] ប៉ុន្តែច្បាប់សិទ្ធិអ្នកនិពន្ធនៃប្រទេសកម្ពុជាតាក់តែងឡើងដោយមិនបានយោងទៅលើកិច្ចព្រមព្រៀងអន្តរជាតិនេះឡើយ ដោយសារតែនៅក្នុងពេលនោះប្រទេសកម្ពុជាពុំទាន់ក្លាយ

[២៤] សិទ្ធិបេតិកភណ្ឌ ជាសិទ្ធិផ្តាច់មុខរបស់អ្នកនិពន្ធក្នុងការធ្វើអាជីវកម្ម ឬទាញយកផលប្រយោជន៍នានាពីស្នាដៃរបស់ខ្លួនដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់សិទ្ធអ្នកនិពន្ធ។ សិទ្ធិនេះត្រូវបានការពារចាប់ពីថ្ងៃដែលស្នាដៃបានបង្កើតរហូតអស់មួយជីវិតរបស់អ្នកនិពន្ធ និង ៥០ឆ្នាំក្រោយមរណភាពរបស់អ្នកនិពន្ធ។

[២៥] សិទ្ធិសីលធម៌ ជាសិទ្ធិអចិន្ត្រៃយ៍ មិនអាចលក់ដូរបាន មិនអាចរឹបអូសបាន និងមិនអាចផុតអាជ្ញាយុកាល។ សិទ្ធិនេះរួមមាន សិទ្ធិក្នុងការសម្រេចអំពីរបៀប និងពេលវេលាផ្សព្វផ្សាយស្នាដៃ សិទ្ធិក្នុងការកំណត់អំពីឈ្មោះ ឋានៈសម្រាប់សាធារណជនទាក់ទង ជាដើមដូចមានកំណត់នៅក្នុងមាត្រា ២០ នៃច្បាប់សិទ្ធិអ្នកនិពន្ធ។

[២៦] សៀវភៅនីតិកម្មសិទ្ធិបញ្ញា, កាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤, ទំព័រ៨៧

[២៧] អនុសញ្ញាទីក្រុងប៊ែន គឺជាអនុសញ្ញាមួយដ៏សំខាន ឬត្រូវបានចាត់ទុកថាជាអនុសញ្ញាគោលផ្នែកសិទ្ធិអ្នកនិពន្ធដែលមានវិធានអនុវត្តគ្របដណ្តប់លើអនុសញ្ញា និងសន្ធិសញ្ញាទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ។ អនុសញ្ញានេះ ជាអនុសញ្ញាមួយដែលមានភាពចំណាស់ជាងគេផ្នែកសិទ្ធិអ្នកនិពន្ធ និងមានភាពល្បីល្បាញ កើតឡើងតាំងពីឆ្នាំ ១៨៨៦។

ជាភាគីនៃអនុសញ្ញាប៊ែននៅឡើយទេ។[២៨] ជាហេតុធ្វើឱ្យច្បាប់សិទ្ធិអ្នកនិពន្ធដែលកំពុងអនុវត្តសព្វថ្ងៃនេះអាចនៅមានភាពខ្វះចន្លោះច្រើន។ ក្រោយមកសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ឆ្នាំ១៨៨៦ និងវិសោធនកម្មឆ្នាំ១៩៧៩ ត្រូវបានរដ្ឋសភាអនុម័តរួចមក ប្រទេសកម្ពុជាក៏បានក្លាយជាសមាជិកនៃអនុសញ្ញានេះ ហើយនឹងត្រូវបំពេញតាមរាល់កាតព្វកិច្ចក្នុងនាមជាសមាជិកដែលក្នុងនោះតម្រូវឱ្យរដ្ឋាភិបាលធ្វើកំណែទម្រង់ ក៏ដូចជាវិសោធនកម្មលើច្បាប់សិទ្ធិអ្នកនិពន្ធឡើងវិញ។[២៩]

ប្រសិនបើយើងធ្វើការប្រៀបធៀបជាមួយច្បាប់នៃប្រទេសជប៉ុនវិញ ច្បាប់សិទ្ធិអ្នកនិពន្ធប្រទេសជប៉ុន ( ដែលជាភាសាជប៉ុនហៅថា 著作権法 ) មានប្រវត្តដ៏ចំណាស់ប្រសិនបើប្រៀបធៀបជាមួយប្រទេសកម្ពុជា ដោយមានទស្សនៈបានលើកឡើងថាច្បាប់នេះបានចាប់កំណត់តាំងពីសម័យម៉េជិឆ្នាំ១៨៦៩ មកម្ល៉េះ។ ប៉ុន្តែត្រូវបានគេធ្វើទំនើបកម្មនៅឆ្នាំ ១៨៩៩ ហើយក្រោយមកបន្ទាប់ពីបានក្លាយជាសមាជិកអនុសញ្ញាទីក្រុងប៊ែន[៣០] ច្បាប់នេះក៏បានដាក់បញ្ចូលនូវវិធានអន្តរជាតិនានាទៅក្នុងច្បាប់របស់ខ្លួនថែមទៀត។ ច្បាប់នេះក៏បានបន្តវិសោធនកម្មជាបន្តបន្ទាប់ជាច្រើនដងរហូតដល់ឆ្នាំ១៩៧០ ច្បាប់នេះត្រូវបានវិសោធនកម្មទាំងស្រុង ហើយដែលត្រូវបានដាក់ឱ្យប្រើប្រាស់រហូតមកដល់សព្វថ្ងៃ។ នេះបង្ហាញឱ្យឃើញពីភាពខុសគ្នាយ៉ាងខ្លាំងរវាងច្បាប់សិទ្ធិអ្នកនិពន្ធរបស់កម្ពុជា និងជប៉ុន។ យើងអាចសន្និដ្ឋានបានថា ច្បាប់សិទ្ធិអ្នកនិពន្ធរបស់ប្រទេសជប៉ុន មានស្តង់ដារស្របតាមអន្តរជាតិ និងអាចមានភាពពេញលេញជាងប្រទេសកម្ពុជា។

### ២.១.២ ការគ្រប់គ្រង និងស្ថាប័នមានសមត្ថកិច្ច

កម្មសិទ្ធិបញ្ញាត្រូវបានគ្រប់គ្រងដោយក្រសួងបីផ្សេងៗគ្នារួមមាន៖ ក្រសួងពាណិជ្ជកម្ម (គ្រប់គ្រងម៉ាកពាណិជ្ជនាម) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (គ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្មជាដើម) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (គ្រប់គ្រងផ្នែកសិទ្ធិអ្នកនិពន្ធ)។

នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញាតាមរយៈសេចក្តីសម្រេចលេខ១៦ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ហើយក្រោយមកនៅឆ្នាំ២០០៨ សេចក្តីសម្រេចនេះត្រូវបាននិរាករណ៍ដោយអនុក្រឹត្យលេខ១៤២ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ

[២៨] ប្រទេសកម្ពុជាបានចូលជាសមាជិកទី ១៨០ នៃអនុសញ្ញាទីក្រុងប៊ែន នៅឆ្នាំ២០២១ ដែលបានចូលជាធរមាននៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២។ សូមមើលគេហទំព័ររបស់ WIPO៖(https://www.wipo.int/wipolex/en/treaties/parties/remarks/KH/១៥) ។

[២៩] គេហទំព័រក្រសួងព័ត៌មាន, ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២, https://www.information.gov.kh/articles/៦៨៩៦៤

[៣០] ជប៉ុនបានក្លាយជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ែននៅ ឆ្នាំ១៨៩៩។ សូមមើលគេហទំព័ររបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក៖ (https://www.wipo.int/wipolex/en/treaties/ShowResults?search_what=C&treaty_id=១៥)

គ្រប់គ្រងកម្មសិទ្ធិបញ្ញា។ ដើម្បីជួយដឹកនាំការងារសម្របសម្រួល ជំរុញ និងពង្រឹងការអនុវត្តកម្មសិទ្ធិបញ្ញាបន្ថែមទៀត រដ្ឋាភិបានសម្រេចដាក់ចេញនូវអនុក្រឹត្យលេខ២០៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា។ គណៈកម្មាធិការនេះមានតួនាទីក្នុងការសម្របសម្រួល និងរៀបចំបទបញ្ញត្តិនានាទាក់ទងនឹងកម្មសិទ្ធិបញ្ញា ព្រមទាំងត្រួតពិនិត្យមើលវិស័យទាំងបីនៃកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា ធ្វើជាចំនុចប្រសព្វនៃកម្មសិទ្ធិបញ្ញា និងសម្របសម្រួលបញ្ហាកម្មសិទ្ធិបញ្ញាទាំងអស់ ជាមួយក្រសួងពាក់ព័ន្ធជាអាទិ៍។

ចំពោះវិវាទកម្មសិទ្ធិបញ្ញាវិញ ដោយសារតែប្រទេសកម្ពុជាមិនទាន់មានតុលាការពិសេសពាណិជ្ជកម្ម ឬកម្មសិទ្ធិបញ្ញាដោយឡែកនៅឡើយទេ ទើបតុលាការនៃនីតិរួមមានសមត្ថកិច្ចនៅក្នុងរឿងនេះ។ តុលាការកម្ពុជាមានសមត្ថកិច្ចគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាល ក្នុងន័យនេះ តុលាការនៃនីតិរួមក៏មានសមត្ថកិច្ចលើបណ្តឹងកម្មសិទ្ធិបញ្ញាផងដែរ។[៣១]

## ២.២ ស្ថានភាពជាក់ស្តែងនៃកម្មសិទ្ធិបញ្ញា

នៅក្នុងកិច្ចការស្រាវជ្រាវនេះយើងធ្វើការសិក្សាតែទៅលើសិទ្ធិអ្នកនិពន្ធប៉ុណ្ណោះ ហេតុនេះហើយយើងនឹងមើលអំពីស្ថានភាពនៃសិទ្ធិអ្នកនិពន្ធខ្លះៗនៅកម្ពុជា។ ដោយសារប្រទេសកម្ពុជាមិនទាន់បើកចំហរទូលាយនៅឡើយនូវសេចក្តីសម្រេចរបស់តុលាការ ហេតុនេះហើយទើបយើងមិនអាចប្រមូលព័ត៌មានអំពីការរំលោភសិទ្ធិអ្នកនិពន្ធនាពេលកន្លងមកបានឡើយ។ ប៉ុន្តែយើងបានឃើញជាញឹកញាប់តាមរយៈសារព័ត៌មាន ឬបណ្តាញសង្គមនានា អំពីការលួចចម្លងស្នាដៃអ្នកដទៃ ឬយកស្នាដៃរបស់អ្នកដទៃទៅបង្ហោះដោយគ្មានការអនុញ្ញាតជាដើម។ នាពេលកន្លងមកយើងឃើញមានការចុះផ្សាយអំពីការយកបទចម្រៀងមរតកដើមមកធ្វើការកែសម្រួល ឬផ្លាស់ប្តូរទំនុកច្រៀងជាដើម ដែលត្រូវបានចាត់ទុកជាការបំពានសិទ្ធិសីលធម៌របស់ម្ចាស់សិទ្ធិ។ រាល់អំពើបំពានទាំងនេះត្រូវបានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចេញលិខិតព្រមាន ដើម្បីលុបបំបាត់ការបំពាននោះ។ ជាក់ស្តែងដោយមើលឃើញពីការយកស្នាដៃមរតកជំនាន់ដើមដូចជាបទចម្រៀងទៅផលិតឡើងវិញដោយពុំមានការអនុញ្ញាតកាន់តែមានច្រើនឡើងៗ ក្រសួងបានដាក់ចេញសេចក្តីប្រកាសព័ត៌មានមួយក្នុងគោលបំណងស្នើឱ្យបណ្តាផលិតកម្ម និងអ្នកសិល្បៈមួយចំនួនឱ្យបញ្ឈប់ការយកបទចម្រៀងដែលជាមរតកដើម និងទទួលបានការគ្រប់គ្រងកម្មសិទ្ធិបញ្ញាពីម្ចាស់ដើម និងគ្រួសារមកច្រៀងឡើងវិញដោយមិនមានការអនុញ្ញាត។[៣២] ថ្មីៗនេះ

[៣១] រដ្ឋធម្មនុញ្ញ, លេខ នស/រកម/០៧០៤/០០១, ឆ្នាំ១៩៩៣, មាត្រា១២៨ ថ្មី

[៣២] សេចក្តីប្រកាសព័ត៌មាន ស្តីពីការរំលោភបំពានស្នាដៃអក្សរសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រីគ្មានអ្នកទទួលមរតក ឬគ្មានមរតកសាសន៍, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០

ផងដែរក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការព្រមានផលិតកម្មថោន ចំពោះការផលិតបទចម្រៀងក្រោមចំណងជើងថា Team ទឹកត្នោតជូរ ច្រៀងដោយ លោកម៉ៅ ហាជី ដែលបានបង្ហោះផ្សព្វផ្សាយលើប្រព័ន្ធ YouTube នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤។[៣៣] តាមរយៈលិខិតរបស់ក្រសួងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានឱ្យដឹងថាការ ផលិតបទចម្រៀងខាងលើជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិសីលធម៌របស់អ្នកនិពន្ធ (សម្ដេចព្រះមហាសង្ឃរាជ ជួន ណាត) និងជាការប្រើប្រាស់បទភ្លេងដែលមានតម្លៃសម្រាប់ជាតិ និងប្រជាជនទៅបំភ្លៃដោយមិនមានខ្លឹមសារអប់រំ និងគ្មានប្រយោជន៍សម្រាប់សង្គម។ ហេតុនេះហើយ ក្រសួងតម្រូវឱ្យផលិតកម្មថោនលុបចោលជាបន្ទាន់នូវការបង្ហោះផ្សព្វផ្សាយបទចម្រៀងនេះតាមគ្រប់មធ្យោបាយ និងត្រូវបញ្ឈប់នូវរាល់ការផលិតបទចម្រៀងដែលរំលោភច្បាប់សិទ្ធិអ្នកនិពន្ធ ព្រមទាំងត្រូវធ្វើលិខិតសុំទោសសាធារណជនចំពោះកំហុសដែលបានកើតឡើងនេះ។

ជាសេចក្ដីសន្និដ្ឋាន វិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាស្ថិតក្នុងស្ថានភាពមួយនៅមានកម្រិតនៅឡើយបើប្រៀបជាមួយប្រទេសដទៃ។ ប៉ុន្តែយើងឃើញថារដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិស័យកម្មសិទ្ធិបញ្ញានេះ។ ជាក់ស្ដែងដូចជាការចូលជាសមាជិកនៃអនុសញ្ញាទីក្រុងប៊ែន អាចឆ្លុះបញ្ចាំងបានពីការព្យាយាមពង្រឹងកម្មសិទ្ធិបញ្ញាផ្នែកអ្នកនិពន្ធនេះឱ្យកាន់តែប្រសើរឡើង និងស្របតាមស្តង់ដារអន្តរជាតិ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **"គោលនយោបាយជាតិស្ដីពីកម្មសិទ្ធិបញ្ញាឆ្នាំ២០២៣-២០២៨"** ដែលមានគោលដៅលើកកម្ពស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍវិស័យអាទិភាពសំខាន់ៗចំនួន៧ រួមមាន៖ (១)កសិកម្ម (២)ពាណិជ្ជកម្ម និងឧស្សាហកម្ម (៣)វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (៤)សុខាភិបាល (៥)វប្បធម៌ (៦)ទេសចរណ៍ (៧)អប់រំ និងការលើកកម្ពស់ចំណេះដឹងសាធារណៈ។ តាមរយៈនេះ យើងអាចធ្វើការសន្និដ្ឋានបានថាកម្មសិទ្ធិបញ្ញានឹងកាន់តែទទួលបានការយកចិត្តទុកដាក់បន្ថែមទៀត ហើយសង្ឃឹមថាប្រព័ន្ធនេះនឹងកាន់តែអាចអនុវត្តបានកាន់តែមានប្រសិទ្ធិភាពជាងមុន។ ដូចនេះ ក្នុងនាមយើងជាអ្នកសិក្សាស្រាវជ្រាវគួរតែប្បីយកចិត្តទុកដាក់លើបញ្ហានេះផងដែរ។

[៣៣] គេហទំព័រព័ត៌មានស៊ី អិន ស៊ី, ចុះផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២៩២៤, សូមចូលទៅកាន់គេហទំព័រតាមតំណរលីងនេះ៖ ក្រសួងវប្បធម៌ ព្រមានផលិតកម្មថោន ចំពោះការផលិតបទចម្រៀងរំលោភបំពានច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល - CNC News

# ជំពូកទី៣

# ទំនាក់ទំនងរវាងអំពើអនីត្យានុកូល
# និងកម្មសិទ្ធិបញ្ញា

# ជំពូកទី៣

# ទំនាក់ទំនងរវាងអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញា

បន្ទាប់ពីបានសិក្សាអំពីអំពើអនីត្យានុកូល និងកម្មសិទ្ធិបញ្ញាយ៉ាងស៊ីជម្រៅរួចមកយើងនឹងធ្វើការសិក្សាពីទំនាក់ទំនងរវាងវិស័យទាំងពីរនេះដោយលើកឡើងពីបញ្ហាប្រឈមដែលអាចកើតមានឡើង។ នៅក្នុងជំពូកនេះ នាងខ្ញុំនឹងលើកឡើងពីបញ្ហាចោទមួយចំនួនដែលគិតថាច្បាប់នៃប្រទេសកម្ពុជានៅមានភាពខ្វះចន្លោះដែលគួរតែទទួលបានការយកចិត្តទុកដាក់ ក៏ដូចជាកែសម្រួលបន្ថែមដើម្បីឱ្យការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធិភាព។

## ៣.១ បញ្ហាប្រឈមនៃអំពើអនីត្យានុកូល និងអំពើរំលោភកម្មសិទ្ធិបញ្ញា

ដូចបានបកស្រាយនៅក្នុងជំពូក១ រួចហើយមិនថាបុគ្គលនោះមានកំហុសចេតនា ឬអចេតនានោះទេគឺមិនអាចគេចផុតពីការទទួលខុសត្រូវបានឡើយ។ ដូចនេះ តើចំពោះការបំពានសិទ្ធិអ្នកនិពន្ធ ម្ចាស់សិទ្ធិអាចទាមទារសំណងដោយផ្អែកលើអ្វីខ្លះ? តើការបំពានកម្មសិទ្ធិបញ្ញានឹងត្រូវចាត់ទុកថាជាអំពើអនីត្យានុកូលដែរឬទេ?

ទោះបីជាមានបញ្ញត្តិច្បាប់ចែងការពារសិទ្ធរបស់អ្នកនិពន្ធក៏ដោយ ជាក់ស្តែងហាក់ឃើញថាបើប្រៀបធៀបជាមួយវិស័យដទៃទៀត ច្បាប់សិទ្ធិអ្នកនិពន្ធនេះមិនទាន់មានការអនុវត្តប្រកបដោយប្រសិទ្ធភាពនៅឡើយទេ។ អ្នកនិពន្ធមួយចំនួនបានបោះបង់ការតែងនិពន្ធអត្ថបទ ឬសៀវភៅ ដោយសារតែស្នាដៃរបស់ខ្លួនត្រូវបានគេយកទៅចម្លង និងដាក់លក់ដោយគ្មានការអនុញ្ញាត ជាហេតុធ្វើឱ្យស្នាដៃរបស់ខ្លួនត្រូវបាត់បង់ទីផ្សារ និងខាតបង់ចំណូល។ ជាក់ស្តែងអ្នកស្រី ម៉ៅ សំណាង ដែលត្រូវបានគេស្គាល់ថាជាអ្នកនិពន្ធមួយរូបដ៏ល្បីបានបង្ខំចិត្តផ្អាកការតែងនិពន្ធរបស់ខ្លួនដោយសារតែស្នាដៃរបស់អ្នកស្រីត្រូវបានយកទៅចម្លង និងផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធើណែតដោយគ្មានការអនុញ្ញាត។[៣៤] ទាំងនេះជាកត្តាមួយដែលធ្វើឱ្យស្នាដៃអ្នកស្រីដែលមានអ្នកគាំទ្រច្រើនប៉ុន្តែបែរជាលក់សៀវភៅបានតិចទៅវិញ ទើបអ្នកស្រីត្រូវបង្ខំចិត្តផ្អាកបោះពុម្ពរឿងប្រលោមលោករបស់អ្នកស្រី។

តាមរយៈករណីខាងលើនេះ យើងអាចគិតថា ហេតុអ្វីអ្នកស្រីមិនដាក់ពាក្យបណ្តឹងទៅតុលាការទៅប្រសិនបើមានការបំពានសិទ្ធិរបស់ខ្លួនកើតឡើងហើយនោះ? ប៉ុន្តែយើងក៏គួរតែពិចារណាលើចំណុចមួយចំនួនផងដែរថា ការដាក់ពាក្យបណ្តឹងទៅតុលាការត្រូវការចំណាយទាំងពេលវេលា និងថវិកា ហើយមិនតែប៉ុណ្ណោះនីតិវិធីស្មុគស្មាញថែមទៀតផង។ លោកស្រីក៏បានលើកឡើងផងដែរថា ការប្តឹងផ្តល់ទៅតុលាការនេះវាមិនផ្តល់

[៣៤] គេហទំព័រព័ត៌មានកោះសន្តិភាព ចុះថ្ងៃទី២៨ សីហា ឆ្នាំ២០១៨, https://kohsantepheapdaily.com.kh/article/៦៩៣៥៨៤.html

យុត្តិធម៌គ្រប់គ្រាន់ដល់អ្នកស្រីឡើយ មានតែខាតពេលវេលា និងថវិការតែប៉ុណ្ណោះ។[៣៥] បន្ថែមពីលើនេះ មូលហេតុចម្បងមួយទៀតដែលយើងអាចសន្មតបានពីការខ្វះជំនឿលើការដោះស្រាយតាមប្រព័ន្ធតុលាការនោះ គឺ អវត្តមាននៃតុលាការពិសេសខាងផ្នែកកម្មសិទ្ធិបញ្ញា។[៣៦] ហេតុនេះហើយទើបធ្វើឱ្យម្ចាស់សិទ្ធិបាត់បង់ទំនុកចិត្តលើការដោះស្រាយតាមប្រព័ន្ធតុលាការ ដោយគិតថាទោះបីជាខ្លួនអាចបានទទួលការដោះស្រាយតាមផ្លូវច្បាប់ហើយក៏ដោយ ប៉ុន្តែដោយសារកង្វះខាតច្បាប់ ក៏ដូចជាការខ្វះខាតអ្នកជំនាញខាងវិស័យកម្មសិទ្ធិបញ្ញាអាចបណ្តាលឱ្យលទ្ធផលដែលទទួលបាននោះវាមិនសមស្របនឹងកាយចំណាយទាំងពេលវេលា និងថវិកាដើម្បីតទល់ជាមួយនឹងអំពើបំពាននោះ។ ដែលត្រង់ចំណុចនេះដែរ យើងឃើញពីភាពខុសគ្នារវាងប្រព័ន្ធតុលាការប្រទេសកម្ពុជា និងប្រទេសជប៉ុនដោយប្រព័ន្ធតុលាការរបស់ប្រទេសជប៉ុនគេបានបង្កើតជាតុលាការសម្រាប់ដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាដោយឡែក។[៣៧]

តើបុគ្គលដែលបានរំលោភសិទ្ធិអ្នកនិពន្ធត្រូវទទួលខុសត្រូវយ៉ាងដូចម្តេច?

នៅពេលដែលដឹងថាមានអំពើបំពានសិទ្ធិ[៣៨]របស់ខ្លួនហើយនោះ អ្នកនិពន្ធអាចដាក់បណ្តឹងទៅតុលាការដើម្បីទទួលបានសំណងរដ្ឋប្បវេណី។ នៅក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលរបៀបនៃការគណនាសំណងការខូចខាតមិនត្រូវបានកំណត់ច្បាស់លាស់នោះទេ។ ប៉ុន្តែច្បាប់បានកំណត់នូវវិធានទូទៅមួយចំនួនដែលម្ចាស់សិទ្ធិអាចធ្វើការទាមទារបាន ដូចជា សំណងជម្ងឺចិត្ត សងការខូចខាតជាដើម។[៣៩] ការមិនបានកំណត់ជាក់លាក់ពីរបៀបនៃការគណនាសំណងនេះ ជាហេតុធ្វើឱ្យមានការលំបាកដល់ម្ចាស់សិទ្ធិក្នុងការបញ្ជាក់ពីការទាមទាររបស់ខ្លួន។ មិនតែប៉ុណ្ណោះ ចៅក្រមក៏មានការលំបាកខ្លាំងផងដែរក្នុងការកំណត់ចំនួនសំណងមួយដែលសមរម្យ។

ប៉ុន្តែយើងអាចពិចារណាបានម្យ៉ាងទៀតដែរថា ការរំលោភសិទ្ធិអ្នកនិពន្ធគឺជាការបំពាននូវសិទ្ធិអ្នកដទៃដោយខុសច្បាប់ ហើយតាមរយៈការបំពាននេះធ្វើឱ្យអ្នកដទៃបាត់បង់នូវប្រយោជន៍ ឬធ្វើឱ្យមានការខូចខាតកើត

---

[៣៥] យោងតាមគេហទំព័រ៖ ការអនុវត្តច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលមិនទាន់មានប្រសិទ្ធិ (ams.com.kh) ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២១

[៣៦] ប្រព័ន្ធតុលាការនៅកម្ពុជាត្រូវបានបែងចែកជា ៣ជាន់គឺ សាលាដំបូងខេត្ត-ក្រុង (តុលាការជាន់ទី១), សាលាឧទ្ធរណ៍ (តុលាការជាន់ទី២), តុលាការកំពូល (តុលាការជាន់ទី៣)។ ក្រៅពីនេះ តុលាការយោធា ជាតុលាការពិសេសសម្រាប់តែបទល្មើសយោធាប៉ុណ្ណោះ។ ហើយនៅថ្ងៃអនាគតត្រូវបានព្យាករថានឹងមានបង្កើតតុលាការពិសេសបន្ថែមទៀតរួមមាន៖ តុលាការរដ្ឋបាល, តុលាការគ្រួសារ, តុលាការការងារ, តុលាការពាណិជ្ជកម្ម

[៣៧] តុលាការកម្មសិទ្ធិបញ្ញាត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៥ ជាតុលាការដែលមានជំនាញក្នុងការដោះស្រាយសំណុំរឿងពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាក្នុងគោលបំណងពង្រឹង និងពន្លឿនការកាត់ក្តីសំណុំរឿងពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

[៣៨] អំពើដែលចាត់ទុកថាជាការរំលោភបំពានមានចែងនៅក្នុងច្បាប់មាត្រា៦២ នៃច្បាប់សិទ្ធិអ្នកនិពន្ធ

[៣៩] ច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣, មាត្រា៥៧

ឡើង។ ដូច្នេះចំណោទបញ្ហាចោទឡើងថា តើម្ចាស់សិទ្ធិអាចទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលបានដែរឬទេ?

យើងបានសិក្សារួចហើយនៅក្នុងជំពូកទី១ ពីលក្ខខណ្ឌនៃអំពើអនីត្យានុកូល។ ដើម្បីអាចទាមទារសំណងដោយផ្អែកលើអំពើអនីត្យានុកូលបានលុះត្រាបានបំពេញលក្ខខណ្ឌ ៤ ដូចបានរៀបរាប់ខាងលើ។ ដូចនេះដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងត្រូវពិចារណាថាការរំលោភសិទ្ធិអ្នកនិពន្ធអាចចាត់ទុកជាអំពើអនីត្យានុកូលដែរឬទេ។

### ៣.១.១ អំពើរំលោភសិទ្ធិអ្នកនិពន្ធ និងលក្ខខណ្ឌនៃអំពើអនីត្យានុកូល

ប្រសិនបើយើងពិចារណាពីស្ថានភាពជាក់ស្តែងនៃអំពើរំលោភសិទ្ធិអ្នកនិពន្ធនោះ យើងអាចសន្មតបានថាគ្មានបុគ្គលណាម្នាក់ដែលមិនបានយល់ដឹងទេថា ការថតចម្លង ឬការផ្សព្វផ្សាយស្នាដៃរបស់អ្នកដទៃដោយគ្មានការអនុញ្ញាតនោះ អាចធ្វើឱ្យម្ចាស់សិទ្ធិនៃស្នាដៃបាត់បង់នូវប្រយោជន៍ (**លក្ខខណ្ឌកំហុស**)។ ប៉ុន្តែចំពោះការអះអាងអំពីកំហុសក្នុងករណីខ្លះមិនមានភាពងាយស្រួលឡើយ។ ឧទាហរណ៍៖ ការយល់ច្រឡំពីសញ្ញាណនៃម្ចាស់សិទ្ធិ ឬអាជ្ញាយុកាលនៃការការពារសិទ្ធិជាដើម។

ជាទូទៅ យើងអាចព្យាករទុកជាមុនថាការយកស្នាដៃរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ឬការថតចម្លងស្នាដៃរបស់អ្នកដទៃដើម្បីប្រយោជន៍អ្វីមួយរបស់ខ្លួននោះជាអំពើខុសច្បាប់ (**លក្ខខណ្ឌផ្ទុយច្បាប់**) ហើយរាល់ការបំពានទាំងអស់នេះនឹងអាចធ្វើឱ្យប៉ះពាល់ដល់ការរកប្រាក់ចំណេញ ឬផលប្រយោជន៍ណាមួយដែលម្ចាស់ស្នាដៃគួរតែទទួលបានតែបែរជាមិនអាចទទួលបានដោយសារតែការបំពាននោះ ហើយក្នុងករណីមួយចំនួនអាចឈានដល់ការប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់អ្នកនិពន្ធ[៤០]ថែមទៀតផង (**លក្ខខណ្ឌនៃការខូចខាត**)។

ក្នុងចំណោមលក្ខខណ្ឌទាំងអស់លក្ខខណ្ឌនៃទំនាក់ទំនងហេតុ និងផលជាលក្ខខណ្ឌមួយដែលមានភាពស្មុគស្មាញជាងគេក្នុងការអះអាង។ ខុសពីអំពើអនីត្យានុកូលទូទៅដែលការខូចខាតទៅលើទ្រព្យសម្បត្តិជាអាទិ៍ ដែលអាចឃើញជាក់ស្តែងអំពីការខូចខាតដែលកើតឡើង។ ចំពោះការខូចខាតខាងផ្នែកកម្មសិទ្ធិបញ្ញាវិញ វាជាការខូចខាតខាងទីផ្សារ ដែលមិនមែនមនុស្សទូទៅសុទ្ធតែអាចអះអាងបាននោះទេ។ ឧទារហរណ៍៖ ប្រសិនបើអ្នកនិពន្ធអះអាងថាស្នាដៃរបស់ខ្លួនត្រូវបានគេថតចម្លងហើយដាក់លក់ក្នុងតម្លៃក្រោមទីផ្សារ ជាហេតុធ្វើឱ្យស្នាដៃរបស់ខ្លួនបាត់បង់ទីផ្សារ និងខាតបង់ចំណូល។ ក្នុងករណីនេះ ម្ចាស់ស្នាដៃនោះត្រូវប្រាកដថាខ្លួនពិតជាអាចអះអាងបានថាការលួចចម្លងស្នាដៃរបស់ខ្លួននោះពិតជានាំឱ្យស្នាដៃរបស់ខ្លួនបាត់បង់ទីផ្សារពិតមែន (**ទំនាក់ទំនងហេតុ និងផល**)។ ប្រសិនបើអ្នកបំពានសិទ្ធិនោះបានលួចថតចម្លងសៀវភៅរបស់ម្ចាស់សិទ្ធិដោយ

[៤០] សិទ្ធិសីលធម៌របស់អ្នកនិពន្ធដូចមានចែងក្នុងមាត្រា ២០ នៃច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

គ្មានការអនុញ្ញាត ហើយបានលក់ដាច់ចំនួន១០០០ក្បាល តើអ្នកនិពន្ធអាចអះអាងបានដែរទេថា ប្រសិនបើគ្មានការលួចចម្លងរបស់បុគ្គលម្នាក់នោះ ខ្លួនអាចលក់សៀវភៅដែលជាស្នាដៃរបស់ខ្លួននេះបានចំនួន ១០០០ក្បាល?

ហេតុនេះហើយរាល់ការបកស្រាយពីការទទួលស្គាល់នូវលក្ខខណ្ឌនីមួយៗ មានតែរង់ចាំមើលលើសេចក្តីសម្រេចរបស់តុលាការ។ ប៉ុន្តែរហូតមកដល់ពេលនេះដោយសារតែសាលក្រមរឿងក្តីកម្មសិទ្ធិបញ្ញាមិនត្រូវបានបង្ហាញជាសាធារណៈនោះទេ ហេតុនេះហើយទើបធ្វើឱ្យការសិក្សាពីយុត្តិសាស្ត្រ ឬមូលដ្ឋាននៃការពិចារណាក្នុងករណីអង្គហេតុដូចខាងលើនេះនៅតែចម្ងល់មិនទាន់អាចបកស្រាយបាននៅឡើយ។

ការអះអាងអំពីលក្ខខណ្ឌទាំងអស់នេះ ដើម្បីទទួលបាននូវសំណងការខូចខាតវាប្រៀបដូចជាការដាក់បន្ទុកមួយយ៉ាងធ្ងន់ទៅលើម្ចាស់សិទ្ធិយ៉ាងអញ្ចឹង។ ហើយមិនមានអ្វីត្រូវសង្ស័យទេថា ហេតុអ្វីបានជាម្ចាស់សិទ្ធិដឹងហើយថាសិទ្ធិរបស់ខ្លួនត្រូវបានបំពានហើយក៏ដោយ ប៉ុន្តែបែរជាមិនដាក់ពាក្យបណ្តឹងទៅវិញ។ ប្រសិនបើមិនមានវិធានការណាមួយដើម្បីដោះស្រាយបញ្ហានេះទេនោះ នឹងធ្វើឱ្យអ្នកនិពន្ធស្នាដៃទាំងអស់បាត់បង់នូវគំនិតក្នុងការបង្កើតថ្មី ព្រោះថាស្នាដៃរបស់ខ្លួនមិនត្រូវបានការពារបានយ៉ាងត្រឹមត្រូវនោះទេ។ ហេតុនេះទោះបីជាការបំពានសិទ្ធិកម្មសិទ្ធិបញ្ញាត្រូវបានចាត់ទុកជាអំពើអនីត្យានុកូលក៏ដោយ វាមិនមានភាពងាយស្រួលនោះទេក្នុងការអះអាងអំពីលក្ខខណ្ឌនីមួយៗ។ លើសពីនេះ មិនមែនតែម្ចាស់សិទ្ធិនោះទេដែលមានការលំបាកក្នុងការអះអាងអំពីការទាមទាររបស់ខ្លួន សូម្បីតែការសម្រេចអំពីចំនួននៃសំណងដែលត្រូវផ្តល់ដល់ជនរងគ្រោះ ក៏បានក្លាយជាបន្ទុករបស់ចៅក្រមទាំងស្រុងផងដែរ ដោយហេតុថាច្បាប់មិនបានផ្តល់ជាមូលដ្ឋានច្បាស់លាស់ក្នុងការគណនាឡើយ។ ដូចនេះ ជាជាងការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល គប្បីគួរមានបញ្ញត្តិដោយឡែក ឬវិធីណាមួយផ្សេងទៀតដើម្បីជួយសម្រួលបន្ទុកក្នុងការបញ្ជាក់អះអាងអំពីការទាមទាររបស់ម្ចាស់សិទ្ធិ ក៏ដូចជាធ្វើជាមូលដ្ឋានសម្រាប់ការសម្រេចសេចក្តីរបស់ចៅក្រមផងដែរ។

ជារួម អំពើរំលោភសិទ្ធិអ្នកនិពន្ធត្រូវបានចាត់ទុកថាជាអំពើអនីត្យានុកូលដរាបណាលក្ខខណ្ឌទាំង៤ ត្រូវបានបំពេញ។ ទោះជាយ៉ាងណា យើងឃើញថាការបញ្ជាក់ពីលក្ខខណ្ឌនីមួយៗពិតជាមិនមានភាពងាយស្រួលទេ។ ហេតុនេះហើយសំណួរមួយទៀតអាចនឹងត្រូវបានចោទឡើងថា តើម្ចាស់សិទ្ធិដែលត្រូវបានគេបំពានសិទ្ធិអាចទាមទារសំណងការខូចខាតដោយផ្អែកលើច្បាប់សិទ្ធិអ្នកនិពន្ធ ឬអំពើអនីត្យានុកូលនៃក្រមរដ្ឋប្បវេណី?

### ៣.១.២ មូលដ្ឋានក្នុងការទាមទារសំណងការខូចខាតចំពោះការបំពានកម្មសិទ្ធិបញ្ញា

ដូចបានរៀបរាប់ខាងលើរួចមកហើយ ប្រសិនបើអ្នកនិពន្ធអាចអះអាងបានពីលក្ខខណ្ឌទាំង៤ នោះគាត់អាចធ្វើការទាមទារសំណងបានដោយផ្អែកលើអំពើអនីត្យានុកូលបានដោយផ្អែកតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែប្រសិនបើយើងធ្វើការសិក្សាច្បាប់សិទ្ធិអ្នកនិពន្ធវិញ នៅមាត្រា៥៧-ខ ក៏បានកំណត់ផងដែរអំពីការទាមទារ

សំណងក្នុងករណីមានការបំពានសិទ្ធិកើតឡើង[៤១] ដោយបានបញ្ញត្តិដូចតទៅថា "... ដើមចោទអាចទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត សងការខូចខាតនិងប្រគល់មកវិញនូវវត្ថុតាងមានឧបករណ៍ ឬសម្ភារៈដែលជាប់រឿងហេតុព្រមទាំងប្រគល់នូវប្រាក់ចំណេញដែលបានមកពីអំពើខុសច្បាប់នោះ"។ ត្រង់ចំណុចនេះអាចនឹងមានការពិភាក្សាថា តើរវាងក្រមរដ្ឋប្បវេណី និងច្បាប់សិទ្ធិអ្នកនិពន្ធគួរយកច្បាប់មួយណាមកធ្វើជាមូលដ្ឋានក្នុងការគណនាសំណងនៃការខូចខាត?

ចំពោះការពិភាក្សានេះ មានមតិពីរ[៤២] ដែលបានលើកឡើងផ្សេងគ្នាគឺ រវាងមតិដែលលើកឡើងថាគួរតែយកច្បាប់សិទ្ធិអ្នកនិពន្ធធ្វើជាមូលដ្ឋានក្នុងការគណនា (ទ្រឹស្តីច្បាប់សិទ្ធិអ្នកនិពន្ធជាមូលដ្ឋាន)[៤៣] និងមតិដែលលើកឡើងអំពីការយកក្រមរដ្ឋប្បវេណីជាមូលដ្ឋានក្នុងការគណនា (ទ្រឹស្តីក្រមរដ្ឋប្បវេណីជាមូលដ្ឋាន)។[៤៤]

### ៣.១.២.១ ទ្រឹស្តីច្បាប់សិទ្ធិអ្នកនិពន្ធជាមូលដ្ឋាន

មាត្រា ៥៧-ខ នៃច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលបានចែងដូចតទៅថា៖

*「... ដើមចោទអាចទាមទារឱ្យចុងចម្លើយសងជម្ងឺចិត្ត សងការខូចខាត និងប្រគល់មកវិញនូវវត្ថុតាង មានឧបករណ៍ ឬសម្ភារៈដែលជាប់រឿងហេតុ ព្រមទាំងប្រគល់នូវប្រាក់ចំណេញដែលបានមកពីអំពើខុសច្បាប់នោះ។」*

យោងតាមអត្ថន័យខាងលើនេះ យើងអាចសន្និដ្ឋានបានថា ប្រសិនបើម្ចាស់សិទ្ធិបានដឹងថាស្នាដៃរបស់ខ្លួនត្រូវបានបំពានហើយនោះ ម្ចាស់សិទ្ធិអាចទាមទារឱ្យជនបំពាននោះ សំណងការខូចខាត ក៏ដូចជាសងជម្ងឺចិត្តបានដោយផ្អែកលើមាត្រា៥៧ ខាងលើនេះ។ ទោះបីជារបៀបនៃការគណនាសំណងច្បាស់លាស់មិនបានស្តែងនៅក្នុងបញ្ញត្តិនៃច្បាប់សិទ្ធិអ្នកនិពន្ធនេះក៏ពិតមែន ប៉ុន្តែច្បាប់ក៏បានព្យាយាមកំណត់សិទ្ធិមួយចំនួនដែល

---

[៤១] ទោះបីជាបញ្ញត្តិនេះបានកំណត់អំពីការទាមទារសំណងនៃការខូចខាតក៏ដោយ ប៉ុន្តែមិនបានកំណត់ច្បាស់លាស់អំពីមូលដ្ឋាននៃការគណនាឡើយ

[៤២] មតិនេះទទួលបានតាមរយៈការធ្វើបទសម្ភាសន៍ចៅក្រម មេធាវី និងអ្នកស្រាវជ្រាវ ដោយសិស្សច្បងដែលសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសជប៉ុន

[៤៣] ជាគោលការណ៍ប្រសិនបើច្បាប់ពិសេសមិនបានចែងនូវចំណុចណាមួយទេនោះ វិធាននៃច្បាប់ទូទៅនឹងត្រូវបានយកទៅអនុវត្ត។ ប៉ុន្តែប្រសិនបើបញ្ញត្តិនៃច្បាប់ពិសេសត្រូវបានកំណត់ហើយនោះ មិនចាំបាច់ត្រូវយកច្បាប់ទូទៅមកអនុវត្តឡើយ។ ជាក់ស្តែងនៅក្នុងច្បាប់សិទ្ធិអ្នកនិពន្ធមាត្រា ៥៧ បានបញ្ញត្តិយ៉ាងច្បាស់អំពីការទាមទារសំណងនៃការខូចខាត ហេតុនេះហើយទើបទ្រឹស្តីនេះកំណត់យកច្បាប់សិទ្ធិអ្នកនិពន្ធជាមូលដ្ឋាននៃការគណនាសំណង

[៤៤] ទោះបីជានៅក្នុងបញ្ញត្តិពិសេសមានចែងអំពីការទាមទារសំណងក៏ពិតមែន ប៉ុន្តែបញ្ញត្តិនេះបានត្រឹមតែកំណត់ថាម្ចាស់សិទ្ធិអាចទាមទារសំណងការខូចខាតបាន ចំណែកលក្ខខណ្ឌក្នុងការទាមទារ ឬវិធាននៃការគណនាសំណងវិញគឺត្រូវកំណត់យកតាមគោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី

ម្ចាស់សិទ្ធិអាចធ្វើការទាមទារបានដូចជា សំណងជម្ងឺចិត្ត សងការខូចខាត ប្រាក់ចំណេញដែលកើតចេញមកពីអំពើរំលោភសិទ្ធិនោះជាដើម។[៤៥]

ប៉ុន្តែការកំណត់ត្រឹមតែអត្ថន័យដូចមានចែងខាងលើនេះ មិនផ្តល់ភាពងាយស្រួលដល់ម្ចាស់សិទ្ធិឡើយ វាបែរជាក្លាយទៅជាបន្ទុកថែមទៀតផងទៅដល់ម្ចាស់សិទ្ធិក្នុងការអះអាងអំពីការទាមទាររបស់ខ្លួន។ មិនតែប៉ុណ្ណោះ វាក៏ក្លាយជាបន្ទុករបស់ចៅក្រមផងដែរក្នុងការសម្រេចអំពីចំនួននៃសំណងការខូចខាត ព្រោះច្បាប់មិនបានកំណត់អំពីស្តង់ដារជាក់លាក់ណាមួយឡើយ។

ចំពោះសិទ្ធិទាមទារសំណងការខូចខាតនេះមានទ្រឹស្តីលើកឡើងថា ម្ចាស់សិទ្ធិអាចទាមទារសំណងការខូចខាតដែលកើតចេញពីអំពើរំលោភសិទ្ធិដោយរាប់បញ្ចូលទាំងការខូចខាតដែលកើតជាក់ស្តែង និងពិតប្រាកដរហូតមកដល់ពេលបច្ចុប្បន្ន និងអនុភាពនៃការខូចខាតដែលអាចនឹងកើតមាននាពេលអនាគត។[៤៦] ប៉ុន្តែទ្រឹស្តីដែលបានលើកឡើងនេះក៏មិនបានបញ្ជាក់អ្វីលើសពីនេះដែរដូចជា ទំហំនៃការទាមទារការខូចខាត ឬគោលការណ៍ដែលជាការកំណត់ក្នុងការទាមទារ។

បញ្ញត្តិនៃមាត្រាខាងលើនេះហាក់បង្ហាញអំពីចេតនាដែលកំណត់យកមូលដ្ឋាននៃការគណនាសំណងការខូចខាតតាមបញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ទូទៅគឺ "ក្រមរដ្ឋប្បវេណី" ។ មានន័យថា ច្បាប់សិទ្ធិអ្នកនិពន្ធបង្ហាញពីចេតនាដែលអ្នកនិពន្ធដែលបានទទួលរងការបំពានសិទ្ធិអាចទាមទារសំណងការខូចខាតបាន ចំណែកការទាមទារដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ ឬការទាមទារត្រឹមកម្រិតប៉ុណ្ណានោះ ត្រូវផ្តល់ឈរលើគោលការណ៍នៃក្រមរដ្ឋប្បវេណី។

ដូចនេះ តើសំណងការខូចខាតនៅក្នុងច្បាប់សិទ្ធិអ្នកនិពន្ធ និងសំណងការខូចខាតនៅក្នុងក្រមរដ្ឋប្បវេណីឈរលើគោលការណ៍តែមួយ ឬក៏យ៉ាងណា? រហូតមកដល់ពេលនេះ មិនទាន់មានការស្រាយបញ្ជាក់ណាមួយនៅឡើយនោះទេ ហេតុនេះហើយយើងមានតែរង់ចាំការបកស្រាយរបស់តុលាការតែប៉ុណ្ណោះ។

### ៣.១.២.២ ទ្រឹស្តីនៃក្រមរដ្ឋប្បវេណីជាមូលដ្ឋាន

យើងបានធ្វើការសិក្សារួចមកហើយ ប្រសិនបើបុគ្គលនោះអាចអះអាងអំពីលក្ខខណ្ឌទាំង ៤ នៃអំពើអនីត្យានុកូលបាននោះ ការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលនឹងត្រូវបានទទួលស្គាល់។ ចំពោះសិទ្ធិអ្នកនិពន្ធវិញយើងក៏អាចធ្វើការបកស្រាយដូចគ្នាបានផងដែរ ប្រសិនបើអ្នកនិពន្ធចង់ទាមទារសំណងការខូចខាតពីអ្នកបំពានសិទ្ធិដោយផ្អែកលើអំពើអនីត្យានុកូលនោះ ត្រូវតែអះអាងអំពីលក្ខខណ្ឌ

[៤៥] សៀវភៅនីតិកម្មសិទ្ធិបញ្ញាកម្ពុជា, នី វិចិត្រ, បោះពុម្ពលើកទី២, ឆ្នាំ២០២៤, ទំព័រទី ៨៩
[៤៦] ដូចខាងលើ

ទាំង៤ នៃអំពើអនីត្យានុកូល។ នោះអានុភាពនៃអំពើអនីត្យានុកូលដែលបានរៀបរាប់ក្នុងជំពូកទី១ នៃកិច្ចការស្រាវជ្រាវនេះ នឹងត្រូវយកមកអនុវត្តដូចគ្នាចំពោះការទាមទារចំពោះការបំពានសិទ្ធិអ្នកនិពន្ធ។ ប៉ុន្តែចំណុចដែលគួរពិចារណានោះគឺ ការអះអាងដោយផ្អែកលើអំពើអនីត្យានុកូលជាបន្ទុករបស់ដើមបណ្តឹង។[៤៧] ពោលគឺ ម្ចាស់សិទ្ធិដែលត្រូវគេរំលោភបំពានសិទ្ធិនោះ ត្រូវធ្វើការបញ្ជាក់ចំពោះចៅក្រមអំពីការបាត់បង់ប្រយោជន៍ ឬការខូចខាតដែលខ្លួនបានទទួលដោយសារអំពើបំពាននោះ។ ប្រសិនបើការខូចខាតនោះជាទ្រព្យសម្បត្តិនោះវាមិនចោទជាបញ្ហាប៉ុន្មាននោះទេ ក្នុងការអះអាងអំពីទំហំនៃការខូចខាតនោះ។ ប៉ុន្តែអ្វីដែលបញ្ហាប្រឈមនោះគឺថា តើការបំពាននូវសិទ្ធិកម្មសិទ្ធិបញ្ញាដែលជាសិទ្ធិអរូបីនេះ បានបង្ក ឬនឹងបង្កឱ្យមានការខូចខាតត្រឹមទំហំណានោះ វាពិតជាមានការលំបាកខ្លាំងក្នុងការអះអាង។ ដូចធ្លាប់បានផ្តល់ជាឧទាហរណ៍ពីខាងដើមមកហើយថា តើអ្នកនិពន្ធពិតជាអាចអះអាងបានដែរទេថា ប្រសិនបើគ្មានសកម្មភាពបំពាននោះខ្លួនពិតជាអាចទទួលបាននូវប្រយោជន៍ស្មើនឹងទំហំដែលរងការខូចខាតនោះ? ហេតុនេះហើយ ការយកគោលការណ៍នៃអំពើអនីត្យានុកូលនៃក្រមរដ្ឋប្បវេណីមកធ្វើជាមូលដ្ឋាននៃការទាមទារសំណងនៃការរំលោភសិទ្ធិអ្នកនិពន្ធពិតជាសមហេតុផលដែរ ឬទេ?

ជារួម យើងឃើញថាក្នុងការទាមទារសំណងការខូចខាត ម្ចាស់សិទ្ធិអាចមានជម្រើស ២ គឺទាមទារដោយផ្អែកលើច្បាប់សិទ្ធិអ្នកនិពន្ធ និងទាមទារដោយផ្អែកលើអំពើអនីត្យានុកូលតាមក្រមរដ្ឋប្បវេណី។ ប៉ុន្តែទោះបីជាជ្រើសរើសយកវិធីណាមួយក៏ដោយ ក៏អ្នកនិពន្ធមានការលំបាកផងដែរក្នុងការអះអាងពីការទាមទាររបស់ខ្លួន។

## ៣.២ ករណីប្រៀបធៀបប្រទេសជប៉ុន

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងនឹងធ្វើការសិក្សាប្រៀបធៀបជាមួយប្រទេសជប៉ុនអំពីប្រព័ន្ធនៃការគណនាសំណងការខូចខាតក្នុងករណីមានការបំពានសិទ្ធិអ្នកនិពន្ធកើតឡើង។ យើងនឹងមើលថាតើប្រទេសជប៉ុនមានបញ្ហាប្រឈមដូចដែលបានលើកឡើងពីខាងដើមដូចប្រទេសកម្ពុជាដែរ ឬទេ? ហើយប្រសិនបើមាន តើគេមានដំណោះស្រាយបែបណា? ហើយប្រសិនបើគ្មាន តើគេធ្វើយ៉ាងដូចម្តេចទើបអាចជៀសផុតពីបញ្ហានេះបាន?

### ៣.២.១ ការបកស្រាយអំពីការបំពានសិទ្ធិ និងលក្ខខណ្ឌនៃអំពើអនីត្យានុកូល

ក្នុងករណីប្រទេសជប៉ុន ប្រសិនបើមានកាបំពានសិទ្ធិអ្នកនិពន្ធកើតឡើងនោះ ម្ចាស់សិទ្ធិអាចធ្វើការទាមទារសំណងការខូចខាតបានដោយផ្អែកលើមាត្រា ៧០៩ នៃក្រមរដ្ឋប្បវេណីដែលមានចែងអំពីអំពើ

[៤៧] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា៧៤៣ កថាខណ្ឌ ៣

អនីត្យានុកូល[៤៨]។ មិនខុសគ្នាពីច្បាប់សិទ្ធិអ្នកនិពន្ធរបស់កម្ពុជា ប្រសិនបើមានការរំលោភបំពានសិទ្ធិអ្នកនិពន្ធកើតឡើង បុគ្គលនោះនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលខុសត្រូវរដ្ឋប្បវេណី។ ចំពោះការទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះអាចទាមទារសំណងការខូចខាត ទាមទារឱ្យបញ្ឈប់សកម្មភាពបំពាន ឬសេចក្ដីចម្រើនឥតហេតុ។ ប៉ុន្តែនៅក្នុងផ្នែកនេះ យើងផ្តោតសំខាន់តែលើការទាមទារសំណងការខូចខាតប៉ុណ្ណោះ។ ជាគោលការណ៍ ម្ចាស់សិទ្ធិដែលត្រូវបានគេបំពានសិទ្ធិអាចទាមទារសំណងការខូចខាតបានដោយផ្អែកលើអំពើអនីត្យានុកូល[៤៩] បានប្រសិនបើបានបំពេញលក្ខខណ្ឌនៃអំពើអនីត្យានុកូលដូចមានចែងក្នុងក្រមរដ្ឋប្បវេណីជប៉ុន មាត្រាចាប់ពីមាត្រា៧០៩ ដល់ មាត្រា៧១៩។

តាមរយៈនេះ ហាក់បង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងរវាងកម្មសិទ្ធិបញ្ញា និងអំពើអនីត្យានុកូល។ ប៉ុន្តែទោះបីជាមានការបកស្រាយពីការទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលក្តី ក៏មានទ្រឹស្តីយ៉ាងច្រើនដែលបានលើកឡើងអំពីផលលំបាកក្នុងការបំពេញនូវលក្ខខណ្ឌនៃអំពើអនីត្យានុកូល។ ប្រសិនបើនៅប្រទេសជប៉ុនអ្នកនិពន្ធដែលរងការបំពានអាចទាមទារសំណងការខូចខាតបានដោយផ្អែកលើអំពើអនីត្យានុកូលបាននោះ តើមិនមានបញ្ហាប្រឈមដូចដែលយើងបានលើកឡើងនៅខាងដើមដូចប្រទេសកម្ពុជាទេ ឬយ៉ាងណា? ចម្លើយនោះគឺ មាន ។ មានទ្រឹស្តី ក៏ដូចជាអត្ថបទស្រាវជ្រាវជាច្រើនបានលើកឡើងដូចគ្នាអំពីផលវិបាកនៃការយកគោលការណ៍នៃអំពើអនីត្យានុកូលមកអនុវត្តចំពោះអំពើរំលោភបំពានកម្មសិទ្ធិបញ្ញា។ ទី១ ដើម្បីកំណត់បានថាមានអំពើអនីត្យានុកូលកើតឡើងគឺទាមទារឱ្យមាន **ចេតនា** ឬ**កំហុស**។ ចំពោះបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តនូវសកម្មភាពបំពានទៅលើសិទ្ធិអ្នកនិពន្ធ ហើយខ្លួនក៏បានដឹងដែរថា អំពើរបស់ខ្លួននោះជាការរំលោភលើសិទ្ធិអ្នកនិពន្ធ ក្នុងករណីនេះគេសន្មតថា លក្ខខណ្ឌចេតនាត្រូវបានបំពេញ។ ចំណែក កំហុសវិញកើតឡើងនៅពេលដែលបុគ្គលនោះមានលទ្ធភាពអាចព្យាករទុកជាមុននូវលទ្ធផលនៃអំពើរបស់ខ្លួន ហើយមិនចាត់វិធានការណាមួយដើម្បីទប់ស្កាត់អំពីការកើតឡើងនៃលទ្ធផលនោះឡើយ។ ក្នុងករណីដែលអំពើបំពាននោះជា ការបំពានដោយផ្ទាល់ដូចជា ការលួចចម្លងស្នាដៃរបស់អ្នកដទៃមកធ្វើជាស្នាដៃរបស់ខ្លួននោះ ភាគច្រើនគឺគេអះអាងអំពីចេតនារបស់ជនដែលប្រព្រឹត្តអំពើបំពាននោះ។ ប៉ុន្តែក្នុងករណីដែលអំពើបំពាននោះ ជាការបំពានដោយប្រយោលដូចជា ការយល់ច្រឡំអំពីម្ចាស់សិទ្ធិនៃស្នាដៃ ឬភ័ន្តច្រឡំអំពីអាជ្ញាយុកាលនៃការការពារសិទ្ធិនោះ គេនឹងធ្វើការពិចារណាលើកំហុសរបស់បុគ្គលនោះ។ ទី២ ចំពោះលក្ខខណ្ឌ

[៤៨] មាត្រា៧០៩ នៃក្រមរដ្ឋប្បវេណីជប៉ុនចែងថា «បុគ្គលដែលបានដល់សិទ្ធិ និងផលប្រយោជន៍តាមផ្លូវច្បាប់របស់បុគ្គលដទៃដោយចេតនា ឬកំហុស ត្រូវទទួលខុសត្រូវការសងការខូចខាតដែលកើតឡើងដោយអំពើនោះ»

[៤៩] សៀវភៅច្បាប់កម្មសិទ្ធិបញ្ញា, យ៉ាសឹយឹគី អាយឈិ, បោះពុម្ពឆ្នាំ២០១៨, ទំព័រ២៩៥ (愛知靖之ほか、『知的財産法』(有斐閣、២០១៨ 年)、២៩៥ 項)

ផ្ទុយច្បាប់វិញ ដូចមានការកំណត់នៅក្នុងច្បាប់សិទ្ធិអ្នកនិពន្ធរបស់កម្ពុជាដែរ រាល់ការលួចចម្លងស្នាដៃ ឬប្រើប្រាស់ស្នាដៃដោយគ្មានការអនុញ្ញាតរបស់អ្នកនិពន្ធដូចមានកំណត់នៅក្នុងច្បាប់សិទ្ធិអ្នកនិពន្ធប្រទេសជប៉ុន[៥០] នឹងត្រូវចាត់ទុកថាជាអំពើខុសច្បាប់។ ចុងក្រោយ ជាគោលការណ៍ ជនរងគ្រោះដែលចង់ទាមទារសំណងដោយផ្អែកលើអំពើអនីត្យានុកូលត្រូវអះអាងអំពីការកើតឡើងនូវការខូចខាត ព្រមទាំងបញ្ជាក់អំពីទំនាក់ទំនងហេតុ និងផលរវាងអំពើបំពាន និងការខូចខាតនោះ។ ប៉ុន្តែដូចបានរៀបរាប់ពីខាងដើមរួចមកហើយថា ការអះអាងអំពីលក្ខខណ្ឌនេះ ក៏ដូចជាចំនួននៃសំណងការខូចខាតវាមិនមានភាពងាយស្រួលនោះទេ ចំពោះម្ចាស់សិទ្ធិ និងម្ចាស់សិទ្ធិប្រហាក់ប្រហែលទាំងអស់។

ប៉ុន្តែគេបានរកដំណោះស្រាយចំពោះបញ្ហានេះរួចរាល់ហើយ ទោះបីវាមិនទាន់អាចដោះស្រាយបានទាំងស្រុង តែវាបានចូលរួមចំណែកដ៏ធំក្នុងការកាត់បន្ថយបញ្ហានេះ។ ដើម្បីជួយសម្រួលដល់បន្ទុករបស់ម្ចាស់សិទ្ធិក្នុងការអះអាងអំពីការទាមទាររបស់ខ្លួន ច្បាប់សិទ្ធិអ្នកនិពន្ធរបស់ជប៉ុនបានបញ្ញត្តិនូវបញ្ញត្តិពិសេសស្តីអំពីមូលដ្ឋាន ក៏ដូចជារបៀបក្នុងការគណនាសំណងការខូចខាត។ ដោយកំណត់យកគោលការណ៍នៃអំពើអនីត្យានុកូលនៃក្រមរដ្ឋប្បវេណី បទដ្ឋានគតិយុត្តិអន្តរជាតិនានា យុត្តិសាស្ត្រតុលាការ ទស្សនៈរបស់អ្នកស្រាវជ្រាវជាអាទិ៍ មកធ្វើជាមូលដ្ឋានក្នុងការពិចារណា។

### ៣.២.២ មូលដ្ឋានក្នុងការទាមទារសំណងការខូចខាត

មាត្រា ១១៤ នៃច្បាប់សិទ្ធិអ្នកនិពន្ធបាន កំណត់អំពីមូលដ្ឋានក្នុងការគណនាសំណងនៃការខូចខាត។ មាត្រានេះបង្កើតឡើងដោយយកគោលការណ៍នៃអំពើអនីត្យានុកូលជាមូលដ្ឋាន ដើម្បីកំណត់អំពីការគណនាសំណងករណីអំពើរំលោភសិទ្ធិអ្នកនិពន្ធ ដើម្បីបន្ធូរបន្ថយបន្ទុករបស់ម្ចាស់សិទ្ធិក្នុងការអះអាងពីការខូចខាត ក៏ដូចជាធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ចៅក្រមក្នុងការធ្វើការសម្រេចសេចក្តីអំពីសំណងការខូចខាតមួយដ៏សមរម្យ។

**ទី១** ម្ចាស់សិទ្ធិអាចទាមទារសំណងសម្រាប់ការខូចខាតដែលទទួលរងដោយសារការរំលោភលើសិទ្ធិអ្នកនិពន្ធ ដោយពិចារណាលើបរិមាណនៃផលិតផលដែលបានបង្កើតឡើងដោយការរំលោភនោះ គឺជាចំនួនទឹកប្រាក់ដែលទទួលបានដោយគុណចំនួននៃប្រាក់ចំណេញក្នុងមួយឯកតានៃបរិមាណនៃផលិតផលដែលម្ចាស់រក្សាសិទ្ធិអាចលក់បានក្នុងករណីដែលមិនមានការរំលោភបំពាន។ បន្ថែមពីលើនេះ ច្បាប់អនុញ្ញាតឱ្យម្ចាស់សិទ្ធិអាចទាមទារបន្ថែមនូវចំនួនទឹកប្រាក់ដែលម្ចាស់កម្មសិទ្ធិបញ្ញាអាចរកបានពីថ្លៃនៃអាជ្ញាប័ណ្ណលើស្នាដៃរបស់ខ្លួន

[៥០] ច្បាប់សិទ្ធិអ្នកនិពន្ធជប៉ុន, មាត្រា១១៣

[៥១] ។ ក្នុងការទាមទារនេះផងដែរ ត្រូវពិចារណាយ៉ាងណាមិនលើសពីចំនួនដែលសមស្របនឹងសមត្ថភាពលក់របស់ម្ចាស់សិទ្ធិផងដែរ (មាត្រា១១៤កថាខណ្ឌ១)។

<u>ឧទាហរណ៍៖</u> ករណីដែលក្រុមហ៊ុនផលិត និងលក់សៀវភៅពុម្ពសិក្សាបានផលិតឡើងវិញនូវរូបភាពដែលបង្កើតឡើងដោយអ្នកជាងគំនូរម្នាក់ (ម្ចាស់កម្មសិទ្ធិ) (ប្រាក់ចំណេញពីការលក់ ៥០០០ យ៉េនក្នុងមួយការងារ) ទៅជាសម្ភារៈអប់រំដោយគ្មានការអនុញ្ញាត និងលក់បាន ១០ ០០០ ក្បាល។ ក្នុងករណីនេះ ម្ចាស់សិទ្ធិអាចទាមទារចំនួនទឹកប្រាក់ដែលស្មើនឹងថ្លៃអាជ្ញាប័ណ្ណ ទៅតាមបរិមាណនៃការខូចខាតបាន។ ដូច្នេះក្នុងករណីខាងលើ ប្រសិនបើថ្លៃអាជ្ញាប័ណ្ណ ១០០០ យ៉េនក្នុងមួយក្បាលនោះ ថ្លៃអាជ្ញាប័ណ្ណ (១០០០ យ៉េនក្នុងមួយក្បាល) អាចត្រូវបានរាប់បញ្ចូលក្នុងការខូចខាតទាក់ទងនឹងសៀវភៅដែលក្រុមហ៊ុននោះបានលក់។ ប៉ុន្តែបើពិចារណាពីសមត្ថភាពក្នុងការលក់ដោយបុគ្គលវិញនោះ ក្នុងចំណោមសៀវភៅចំនួន ១០ ០០០ ក្បាលដែលក្រុមហ៊ុនអាចលក់នោះ មានតែ ១០០ ក្បាលប៉ុណ្ណោះដែលគេសន្មតថាម្ចាស់សិទ្ធិនោះមានលទ្ធភាពលក់បាន ហើយចំណែកដែលនៅសល់ ៩ ៩០០ ក្បាលចាត់ទុកថាជាសមត្ថភាពលក់របស់ក្រុមហ៊ុន។ ជាលទ្ធផល ម្ចាស់សិទ្ធិអាចមានលទ្ធភាពក្នុងការទាមទារសំណងផ្អែកតាមរូបមន្តដូចតទៅនេះ៖

| |
|---|
| (ចំនួនសៀវភៅដែលម្ចាស់សិទ្ធិមានលទ្ធភាពលក់ x ប្រាក់ចំណេញនៃសៀវភៅមួយក្បាល) + ចំណូលពីអាជ្ញាប័ណ្ណ |
| (៥០០០ យ៉េន× ១០០ក្បាល) + ១០០០យ៉េន× ៩ ៩០០ក្បាល |

**ទី២** ប្រសិនបើអ្នករំលោភសិទ្ធិនោះអាចរកបានប្រាក់ចំណេញពីស្នាដៃដែលខ្លួនប្រើប្រាស់ដោយខុសច្បាប់ នោះចំនួនទឹកប្រាក់នៃប្រាក់ចំណេញនោះត្រូវបានសន្មតថាជាចំនួននៃការខូចខាត។ ដូចនេះ ម្ចាស់សិទ្ធិដោយផ្អែកលើនេះអាចគណនាចំនួននៃការខូចខាត និងធ្វើការទាមទារបាន។ ទោះជាយ៉ាងណាក៏ដោយដោយសារការផ្តល់នេះគ្រាន់តែជាការសន្មតប៉ុណ្ណោះ ដោយការទាមទារនេះអាចត្រូវបានបដិសេធ ប្រសិនបើអ្នកបំពាននោះអាចបង្ហាញថាចំនួននៃការខូចខាតដែលម្ចាស់សិទ្ធិបានទទួលមានចំនួនតិចជាងប្រាក់ចំណេញដែលខ្លួនបានទទួល។ (មាត្រា ១១៤ កថាខណ្ឌ២)

<u>ឧទាហរណ៍៖</u> ប្រសិនបើបុគ្គលណាម្នាក់បានយកស្នាដៃចម្រៀងរបស់ម្ចាស់សិទ្ធិទៅបង្ហោះនៅលើអ៊ីនធើណែតដោយគ្មានការអនុញ្ញាត ហើយបុគ្គលនោះអាចរកប្រាក់ចំណូលបានពីការទស្សនារបស់អ្នកមើលនោះចំនួន ៣០០០ ដុល្លារ នោះម្ចាស់សិទ្ធិអាចទាមទារសំណងការខូចខាតបានចំនួន ៣០០០ ដុល្លារ។

[៥១] ថ្លៃអាជ្ញាប័ណ្ណ សំដៅលើថ្លៃប្រើប្រាស់ដែលបានបង់ដោយអ្នកប្រើប្រាស់លើស្នាដៃដែលបានរក្សាសិទ្ធិដោយម្ចាស់កម្មសិទ្ធិបញ្ញា

**ទី៣** ម្ចាស់កម្មសិទ្ធិបញ្ញា អាចទាមទារការខូចខាតដែលស្មើនឹងថ្លៃអាជ្ញាប័ណ្ណពីអ្នកដែលបានរំលោភលើសិទ្ធិអ្នកនិពន្ធរបស់ខ្លួន។ ការផ្តល់នេះត្រូវបានចាត់ទុកថាជាចំនួនអប្បបរមានៃការខូចខាតតាមច្បាប់ ហើយអ្នករំលោភបំពានមិនអាចកាត់បន្ថយចំនួននៃការខូចខាតដោយអះអាងថាចំនួនពិតប្រាកដនៃការខូចខាតមានចំនួនតិចជាងនេះទេ(មាត្រា ១១៤ កថាខណ្ឌ៣)។

<u>ឧទាហរណ៍</u>៖ ប្រសិនបើអ្នករំលោភបំពានបានលក់ច្បាប់ចម្លងនៃស្នាដៃដែលបានរក្សាសិទ្ធិ ហើយធ្វើការលក់ប្រចាំខែរកចំណូលបានចំនួន 10 លានយ៉េន ហើយអត្រាថ្លៃអាជ្ញាប័ណ្ណរបស់អ្នកកាន់កាប់សិទ្ធិគឺ ៩% នៃការលក់។ ដូចនេះ ការខូចខាតរបស់ម្ចាស់សិទ្ធិអ្នកនិពន្ធនឹងមានចំនួន ៩00 000 យ៉េនក្នុងមួយខែ ដែលវាក្លាយជាចំនួនដែលអ្នកនិពន្ធអាចធ្វើការទាមទារបាន។

ជារួម ប្រសិនបើមានអំពើបំពានកើតឡើងនោះ ម្ចាស់សិទ្ធិអាចធ្វើការជ្រើសរើសទាមទារសំណងតាមវិធីណាមួយដូចបានរៀបរាប់ខាងលើ។ យើងឃើញថា ច្បាប់សិទ្ធិអ្នកនិពន្ធជប៉ុនបានបញ្ញត្តិនូវមូលដ្ឋានក្នុងការទាមទារសំណងដែលបង្កភាពងាយស្រួលដល់ម្ចាស់សិទ្ធិក្នុងការអះអាងការទាមទាររបស់ខ្លួន។ មិនតែប៉ុណ្ណោះ វាក៏បានផ្តល់ភាពងាយស្រួលដល់ការធ្វើសេចក្តីសម្រេចរបស់ចៅក្រមផងដែរ ដោយវាបានផ្តល់ជាមូលដ្ឋានក្នុងការគណនា ក៏ដូចជាការទទួលស្គាល់ ឬមិនទទួលស្គាល់ការទាមទារជាដើម។ សរុបសេចក្តីមក ប្រសិនបើអ្នកប្រព្រឹត្តអំពើបំពានបានថតចម្លងសៀវភៅរបស់ម្ចាស់សិទ្ធិដោយគ្មានការអនុញ្ញាត ដូចនេះសំណងនៃការខូចខាតអាចត្រូវបានគណនាដូចតទៅនេះ៖

| **មាត្រា** | **របៀបគណនា** |
|---|---|
| មាត្រា ១១៤ កថាខណ្ឌទី១ | 「ចំនួនសៀវភៅដែលជនល្មើសលក់បាន」×「តម្លៃនៃផលប្រយោជន៍ដែលម្ចាស់សិទ្ធិនឹងទទួលបានពីសៀវភៅមួយក្បាល」+「ទឹកប្រាក់សាកសមនឹងតម្លៃនៃអាជ្ញាប័ណ្ណ」 |
| មាត្រា ១១៤ កថាខណ្ឌទី២ | អត្ថប្រយោជន៍ដែលជនល្មើសបានទទួល |
| មាត្រា ១១៤ កថាខណ្ឌទី៣ | ប្រយោជន៍ដែលម្ចាស់សិទ្ធិគួរទទួលបានតាមការអនុវត្តសិទ្ធិរបស់ខ្លួន (អាជ្ញាប័ណ្ណជាដើម) |

តាមរយៈការបកស្រាយខាងលើ យើងឃើញថាផលវិបាកក្នុងការទាមទារសំណងការខូចខាតរបស់ម្ចាស់សិទ្ធិដោយផ្អែកលើអំពើអនីត្យានុកូល ក៏ជាបញ្ហាប្រឈមសម្រាប់ច្បាប់នៃប្រទេសជប៉ុនផងដែរ។ ដោយឆ្លងកាត់នូវការពិភាក្សាវែកញែកពីសំណាក់អ្នកស្រាវជ្រាវជាច្រើន រួមផ្សំជាមួយនឹងយុទ្ធសាស្ត្រតុលាការប្រទេសជប៉ុននាពេលកន្លងមកផងនោះ ការអះអាងនូវការទាមទារសំណងការខូចខាតផ្អែកតាមអំពើអនីត្យានុកូលត្រូវបានគេទទួលស្គាល់ថាមានការលំបាកខ្លាំង និងមិនអាចផ្តល់ដល់ម្ចាស់សិទ្ធិនូវការការពារមួយដ៏សមរម្យឡើយ។ ជាលទ្ធផល ជប៉ុនបានតាក់តែងបញ្ញត្តិពិសេសដាច់ដោយឡែកនៅក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ ដើម្បីជួយសម្រួលបន្ទុករបស់ម្ចាស់សិទ្ធិ ជាពិសេសសម្រាប់ជាមូលដ្ឋានមួយក្នុងការវិនិច្ឆ័យចំនួនសំណងសមរម្យរបស់ចៅក្រមចំពោះម្ចាស់សិទ្ធិ។ វត្តមាននៃបញ្ញត្តិពិសេសនៃច្បាប់សិទ្ធិអ្នកនិពន្ធនេះ ផ្តល់ភាពងាយស្រួលដល់ម្ចាស់សិទ្ធិក្នុងការទាមទារ ដោយហេតុថាម្ចាស់សិទ្ធិមានដឹងថាខ្លួនអាចទាមទារអ្វីបានខ្លះ និងទាមទារបានតាមវិធីបែបណា។

## ៣.៣ ដំណោះស្រាយ

បន្ទាប់ពីយើងធ្វើការសិក្សារវាងប្រព័ន្ធរបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុនរួចមក យើងសន្និដ្ឋានបានថា បញ្ហាប្រឈមដែលកម្ពុជាកំពុងតែប្រឈមនេះ នៅប្រទេសជប៉ុនក៏ធ្លាប់ជួបប្រទះដែរ។ ប៉ុន្តែចំពោះបញ្ហានេះរហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសជប៉ុនបានដោះស្រាយរួចហើយដូចដែលយើងបានសិក្សាក្នុងផ្នែកទី២ខាងលើនេះ។

ឆ្លើយតបទៅនឹងចំណោទបញ្ហាដែលយើងបានលើកឡើងពីខាងដើម យើងឃើញថា ការរំលោភសិទ្ធិអ្នកនិពន្ធត្រូវបានចាត់ទុកជាអំពើអនីត្យានុកូល ដែលម្ចាស់សិទ្ធិអាចទាមទារសំណងការខូចខាតពីជនបង្កបានដោយផ្អែកលើអំពើអនីត្យានុកូល។ ប៉ុន្តែទោះបីជាយើងសន្និដ្ឋានបានយ៉ាងដូច្នេះក៏ដោយ ភាពខ្វះចន្លោះនៃមូលដ្ឋានក្នុងការគណនាសំណងនឹងនៅតែចោទជាបញ្ហាប្រសិនបើមិនមានវិធានការ ឬកំណែទម្រង់ណាមួយនៃច្បាប់នោះ។

អាស្រ័យហេតុនេះហើយ ការធ្វើកំណែទម្រង់នៃមាត្រានៃច្បាប់សិទ្ធិអ្នកនិពន្ធដោយបញ្ចូលនូវមូលដ្ឋានមួយជាក់លាក់ក្នុងការគណនាសំណងការខូចខាតជារឿងមួយដ៏ចាំបាច់ ពោលគឺ ជាជាងការយកបញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីមកអនុវត្តចំពោះសិទ្ធិកម្មសិទ្ធិបញ្ញា គប្បីមានការបង្កើតនូវបញ្ញត្តិពិសេសមួយដែលកំណត់ឱ្យបានជាក់លាក់ និងច្បាស់លាស់។

នៅក្នុងការតាក់តែងបញ្ញត្តិពិសេសនៃមូលដ្ឋានក្នុងការគណនានេះ យើងអាចឈរលើគោលការណ៍នៃក្រមរដ្ឋប្បវេណី និងយកប្រព័ន្ធនៃសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលមកធ្វើជាមូលដ្ឋានក្នុងការ

ពិចារណា។ លើសពីនេះ យើងអាចធ្វើការសិក្សាលើប្រព័ន្ធរបស់ប្រទេសដទៃ ជាពិសេសនោះគឺប្រទេសជប៉ុន ដែលជាប្រភពដើមនៃក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា។ ដោយដំបូងយើងសិក្សាអំពីប្រព័ន្ធនៃសំណងការខូចខាតរបស់ប្រទេសជប៉ុន បន្ទាប់មកទៀតយើងនឹងសិក្សាមូលដ្ឋានក្នុងការគណនាសំណងដោយផ្អែកលើការបំពានសិទ្ធិអ្នកនិពន្ធនៃច្បាប់សិទ្ធិអ្នកនិពន្ធរបស់ជប៉ុន។

បន្ទាប់ពីយើងដឹងថាដំណោះស្រាយនៃបញ្ហាជា ការចងក្រងនៃបញ្ញត្តិពិសេសហើយនោះ ជំហ៊ានបន្ទាប់គឺយើងត្រូវពិចារណាថាគួរតែចងក្រងវាបែបណា។ តើយើងគួរយកគំរូតាមបញ្ញត្តិរបស់ប្រទេសជប៉ុនដែរ ឬទេ? តើការអនុវត្តប្រដូចទៅនឹងប្រទេសជប៉ុនពិតជាត្រឹមត្រូវតាមស្ថានភាពសង្គមនៃប្រទេសកម្ពុជាដែរ ឬទេ? រាល់សំណួរទាំងនេះជាបញ្ហាចោទដែលយើងត្រូវធ្វើការសិក្សាស្រាវជ្រាវជាបន្តទៀត។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវស៊ីជម្រៅរួចមក ឃើញថារាល់ជនរងគ្រោះដែលបានទទួលរងនូវព្យសនកម្មទាំងឡាយដោយសារតែអំពើរបស់អ្នកដទៃនោះ នឹងត្រូវបានការពារដោយច្បាប់ តាមរយៈការផ្តល់សិទ្ធិក្នុងការទាមទារសំណងការខូចខាតចំពោះជនបង្កនោះ។ កន្លងមកនេះ យើងក៏ឃើញមានការទាមទារសំណងការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូលជាច្រើនករណីមកហើយ ដូចនេះយើងអាចសន្និដ្ឋានបានថា វត្តមាននៃបញ្ញត្តិនៃអំពើអនីត្យានុកូលពិតជាបានជួយសង្គ្រោះដល់ជនរងគ្រោះ និងជួយបង្ការមិនឱ្យមានអំពើអនីត្យានុកូលកើតឡើងផងដែរ។ ប៉ុន្តែយើងឃើញថា គោលការណ៍នៃអំពើអនីត្យានុកូលហាក់ដូចជា ពិចារណាត្រឹមតែការខូចខាតខាងទ្រព្យសម្បត្តិរូបីតែប៉ុណ្ណោះ ព្រោះបើយើងពិនិត្យទៅលើលក្ខខណ្ឌ ក៏ដូចជាអានុភាពរបស់វាហាក់បង្ហាញឱ្យឃើញថាអ្នកតាក់តែងច្បាប់មិនបានចែងជាបញ្ញត្តិពិសេសដាច់ដោយឡែកសម្រាប់ការខូចខាតទ្រព្យសម្បត្តិអរូបីឡើយ។ ដូចនេះយើងអាចធ្វើការបកស្រាយបានថាទោះបីជាការខូចខាតនោះជាទ្រព្យរូបីក្តី ឬទ្រព្យអរូបីក្តី គោលការណ៍នៃអំពើអនីត្យានុកូលនឹងត្រូវបានអនុវត្តដូចគ្នា។

មូលហេតុនៃការខ្វះចន្លោះនេះអាចមកពីមូលហេតុនៃភាពទន់ខ្សោយនៅឡើយនៃវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជា។ ទោះបីជាប្រទេសកម្ពុជាបានចងក្រមនូវបទបញ្ញត្តិនានាតាំងពីយូរលង់ណាស់មកហើយក្តី យើងឃើញថាការអនុវត្តមិនទាន់មានភាពខ្លាំងក្លានូវឡើយទេ។ ជាពិសេសគឺសិទ្ធិអ្នកនិពន្ធតែម្តង ដែលស្ទើរតែមិនទទួលបានការយកចិត្តទុកដាក់ទាល់តែសោះ។ រហូតមកដល់ថ្មីៗនេះ ទើបរាជរដ្ឋាភិបាលបានចាប់ផ្តើមយកចិត្តទុកដាក់កែសម្រួល និងពង្រឹងបន្ថែមការអនុវត្តសិទ្ធិអ្នកនិពន្ធនេះឡើងវិញ ដើម្បីជម្រុយលើកទឹកចិត្តដល់អ្នកនិពន្ធទាំងអស់ ក៏ដូចជា ដើម្បីលើកកម្ពស់ដល់វិស័យវប្បធម៌របស់ប្រទេសកម្ពុជា។ ការរីកចម្រើនផ្នែកវប្បធម៌ក៏ជាកាតាលីករមួយជម្រុយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ តាមរយៈការផ្សព្វផ្សាយវប្បធម៌កម្ពុជានៅលើឆាកអន្តរជាតិដែលអាចធ្វើឱ្យពិភពលោកស្គាល់ពីប្រទេសកម្ពុជាកាន់តែច្រើន និងអាចទាក់ទាញការធ្វើពាណិជ្ជកម្ម ក៏ដូចជាការវិនិយោគកាន់តែកើនឡើង។

ហេតុនេះហើយនៅក្នុងការពង្រឹងវិស័យកម្មសិទ្ធិបញ្ញា ការពិចារណាអំពីការទទួលបានសំណងសមរម្យចំពោះអំពើរំលោភបំពានគឺជា បញ្ហាមួយចម្បងក្នុងចំណោមបញ្ហាដទៃទៀតដែលយើងគួរយកចិត្តទុកដាក់។ ដោយសារតែប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ កង្វះខាតបច្ចេកទេស ឬវិធានចាំបាច់មួយចំនួនគឺជារឿងដែលមិនអាចគេចផុតនោះទេ។ ដូចនេះ យើងគួរតែសិក្សាពីប្រទេសអភិវឌ្ឍដទៃទៀតដែលគេមានការរីចម្រើនខ្លាំង និងមានបទពិសោធន៍ច្រើនជាង ដើម្បីធ្វើជាគំរូ និងជាមូលដ្ឋានមួយក្នុងការពិចារណា។

# អនុសាសន៍

# អនុសាសន៍

នាពេលកន្លងមកយើងឃើញថារដ្ឋាភិបាលបានខិតខំប្រឹងប្រែងពង្រឹងលើគ្រប់វិស័យទាំងអស់នៅកម្ពុជា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែមានភាពរីកចម្រើន។ ក្នុងនោះរដ្ឋាភិបាលក៏បានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់លើវិស័យកម្មសិទ្ធិបញ្ញាផងដែរ តាមរយៈការបង្កើតស្ថាប័នការពារសិទ្ធិ ការចូលជាសមាជិកនៃអង្គការអន្តរជាតិនានា ជាអាទិ៍។ នាងខ្ញុំពិតជាកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកសាងនូវប្រព័ន្ធច្បាប់តាំងពីចំណុចសូន្យរហូតដល់ពេលបច្ចុប្បន្ននេះ។ អាស្រ័យហេតុនេះហើយ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវមួយរូប នាងខ្ញុំសង្ឃឹមថាអាចចូលរួមចំណែកក្នុងការពង្រឹងបន្ថែមលើការអនុវត្តច្បាប់បន្ថែមទៀត ទោះបីជាអាចចូលរួមបានមួយចំណែកតូចក្តី។ តាមរយៈចំណេះដឹងដែលខ្លួនមាន និងឆ្លងកាត់ការសិក្សាស្រាវជ្រាវទាំងប្រព័ន្ធនៃប្រទេសកម្ពុជា និងប្រទេសជប៉ុននាងខ្ញុំសូមផ្តល់នៅអនុសាសន៍មួយចំនួនដូចតទៅៈ

- ដើម្បីឱ្យវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាកាន់តែមានភាពរីកចម្រើនបន្ថែមទៀតជាដំបូងគឺ ត្រូវការការយកចិត្តទុកដាក់ពោលគឺ បញ្ជ្រាបការយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញានេះ ដល់មន្ត្រីរាជការ អ្នកអនុវត្តច្បាប់ ពិសេសនោះគឺប្រជាពលរដ្ឋ ព្រោះថាប្រសិនបើគ្មានអ្នកខ្វល់ខ្វាយពីកម្មសិទ្ធិបញ្ញាទេនោះ ទោះបីជាយើងខិតខំអភិវឌ្ឍច្បាប់យ៉ាងណាក៏ដោយ ក៏ការអនុវត្តមិនមានប្រសិទ្ធភាពដែរ
- បច្ចុប្បន្នប្រទេសកម្ពុជាបានកំពុងរៀបចំដាក់បង្ហាញសាលក្រមជាសាធារណៈ ដែលក្នុងនោះយើងឃើញមានសេចក្តីសម្រេចតុលាការផ្នែករដ្ឋប្បវេណីមួយចំនួនបើកជាសាធារណៈនៅក្នុងគេហទំព័ររបស់ក្រសួងយុត្តិធម៌ដែលអនុញ្ញាតឱ្យមនុស្សគ្រប់គ្នាអាចចូលមើលបានដោយសេរី។ ជាការប្រសើរ មិនមែនត្រឹមតែរឿងក្តីរដ្ឋប្បវេណី ឬព្រហ្មទណ្ឌប៉ុណ្ណោះទេ ខ្ញុំសង្ឃឹមថាក្នុងពេលឆាប់ៗខាងមុខយើងក៏អាចទទួលបានការបើកជាសាធារណៈនូវសាលក្រមក្នុងរឿងក្តីកម្មសិទ្ធិបញ្ញាបានផងដែរ
- លើកទឹកចិត្តដល់អ្នកស្រាវជ្រាវ ឬសាស្ត្រាចារ្យឱ្យមានការស្រាវជ្រាវថ្មីៗបន្ថែមទៀតលើបញ្ហាកម្មសិទ្ធិ ដើម្បីជាជំនួយដល់សិក្សានុសិស្ស ក៏ដូចជាចំណែកមួយក្នុងការផ្តល់ចំណេះដឹងថ្មីៗដល់អ្នកស្រាវជ្រាវជំនាន់ក្រោយផងដែរ
- ចំពោះចំណោទបញ្ហាដែលបានចោទពីខាងដើម ជាដំណោះស្រាយគឺ ទាមទារឱ្យយើងយល់ពីទំនាក់ទំនងរវាងអំពើអនីត្យានុកូល និងកម្មសិទ្ធបញ្ញា ហេតុនេះហើយដំបូងឡើយ យើងត្រូវសិក្សាស្វែងយល់ពីប្រព័ន្ធអំពើអនីត្យានុកូលឱ្យបានស៊ីជម្រៅ ហើយមិនត្រឹមតែសិក្សាពីប្រព័ន្ធរបស់ប្រទេសកម្ពុជាតែប៉ុណ្ណោះទេ យើងគួរគប្បីស្វែងយល់បន្ថែមពីប្រព័ន្ធរបស់ប្រទេសជប៉ុនដែលជាច្បាប់គម្រូរបស់ក្រមរដ្ឋប្បវេណីកម្ពុជា។ ដោយសារតែវិសាលភាពនៃការស្រាវជ្រាវនេះនៅមានកម្រិត យើងមិនអាចផ្តល់នូវ

ដំណោះស្រាយបានទាំងស្រុងនោះទេ។ ហេតុនេះ នាងខ្ញុំលើកទឹកចិត្តដល់និស្សិត ក៏ដូចជាអ្នកស្រាវជ្រាវជំនាន់ក្រោយឱ្យសិក្សាស្វែងយល់ពីប្រព័ន្ធសំណងការខូចខាតករណីរំលោភកម្មសិទ្ធិបញ្ញារបស់ប្រទេសជប៉ុនបន្ថែមទៀត។ ដោយសារនៅប្រទេសកម្ពុជា ការស្វែងរកឯកសារពិតជាមានការលំបាកខ្លាំង ដូចនេះការសិក្សាពីបញ្ហានេះនៅប្រទេសជប៉ុនគឺជាការចាំបាច់ណាស់

- ជាចុងក្រោយនោះគឺការចូលរួមអនុវត្តពីសំណាក់ប្រជាពលរដ្ឋគ្រប់រូបពោលគឺ បញ្ឈប់នូវរាល់សកម្មភាពលួចចថតចម្លងស្នាដៃ ឬប្រើប្រាស់ស្នាដៃអ្នកដទៃដោយគ្មានការអនុញ្ញាត។ សំណូមពរដល់អ្នកគ្រប់គ្នាឱ្យចូលរួមលើកទឹកចិត្ត និងគាំទ្រនូវរាល់ស្នាដៃបង្កើតថ្មីទាំងឡាយរបស់កម្ពុជា។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងបទដ្ឋានគតិយុត្តិផ្សេងៗ

### ក. ខ្មែរ៖

- រដ្ឋធម្មនុញ្ញ, លេខ នស/រកម/០៧០៤/០០១, ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨
- ច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២
- ច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំរូឧស្សាហកម្ម, លេខ នស/រកម/០១០៣/០០៥, ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣
- ច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល, លេខ នស/រកម/០៣០៣/០០៨, ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣
- ច្បាប់ ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ, លេខ នស/រកម/០៥០៨/០១៥, ចុះ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ ស្តីពីម៉ាក់សម្គាល់ភូមិសាស្ត្រទំនិញ, លេខ នស/រកម/០១១៤/០០៦, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤
- អនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា, លេខ១៤២ អនក្រ.បក, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨
- អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា, លេខ២០៦ អនក្រ.បក, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១

### ខ. ជប៉ុន៖

- ក្រមរដ្ឋប្បវេណីជប៉ុន (民法)
- ច្បាប់ ស្តីពីសិទ្ធិអ្នកនិពន្ធជប៉ុន (著作権法)

### គ. អន្តរជាតិ៖

- អនុសញ្ញាទីក្រុងប៉ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦ វិសោធនកម្មឆ្នាំ១៩៧៩

- អនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៨៨៣


## ២. សៀវភៅ និងឯកសារផ្សេងៗ

### ក. ខ្មែរ៖


- សៀវភៅនីតិកម្មសិទ្ធិបញ្ញាកម្ពុជា,នី វិចិត្រ, បោះពុម្ពលើកទី២, ឆ្នាំ២០២៤
- សៀវភៅនីតិកម្មសិទ្ធិបញ្ញា, កាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤
- សៀវភៅមេរៀនក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគ ២, ក្រសួងយុត្តិធម៌, ឆ្នាំ២០១៦
- សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី, អ៊ីកិដា ម៉ាសាអុ, បោះពុម្ពលើកទី៦
- សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី, បោះពុម្ពលើកទី៦
- ណូមឹរ៉ា តូយ៉ូហ៊ីរ៉ូ, សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, កែសម្រួលទាំងស្រុងលើកចុងក្រោយ, ភ្នំពេញ, ឆ្នាំ២០១៤
- សៀវភៅវិធីសាស្ត្រគតិយុត្ត, កាន ច័ន្ទមេត្តា, កើត រិទ្ធ,ការ៉ិន គូបាំង, ចាំង ស៊ីណាត, អូជ្រេ ឆាអ៊ីន, ឈន សុភាព, ថេងច័ន្ទសង្វារ, អាន ធីតា នពេត្តម, នួន ផារ័ត្ន, អេម៉ាណុយអែល ប៊ូរហ្គ័រ, ផ្លូរ៉ង ដឺប៊ែរ, ណន ប៊ុនណា, បេអាទ្រីស បាលីវ, ប៉ែន រ៉ានី, លឹម ស៊ុយហុង, ស៊ូ សុជាតិ, ស៊ុម សុខម្លូ, សៀងធីរិទ្ធ និងនីកូឡា រីយ៉ាស, ភ្នំពេញ, ឆ្នាំ២០០៦


### ខ. ជប៉ុន៖


- សៀវភៅច្បាប់កម្មសិទ្ធិបញ្ញា, យ៉ាសឹយឹគី អាយឈិ, បោះពុម្ពឆ្នាំ២០១៨ ［愛知靖之ほか、『知的財産法』(有斐閣、2018 年)］
- សៀវភៅសេចក្តីផ្តើមនៃច្បាប់ស៊ីវិល, ថុយុហ៊ីរ ណុមឹរ៉ាក់, បោះពុម្ពលើកទី៨ ឆ្នាំ២០២៣ ［野村豊弘『民事法入門』（有斐閣アルマ、第 8 版補訂版、2023 年）］
- ទ្រឹស្តីសិទ្ធិ និងអំពើអនីត្យានុកូល, យ៉ាសឹហ៊ីរុ ហ្វីជីអូកា, ឆ្នាំ២០០៥ ［藤岡康宏、「不法行為と権利論」、（2005 年）］
- លក្ខខណ្ឌនៃអំពើអនីត្យានុកូលក្នុងសេចក្តីព្រាងក្រមរដ្ឋប្បវេណី,ស៊ូមីតា ម៉ូរីមីឈី, ឆ្នាំ២០២៣ ［住田守道、「日本民法起草者における権利侵害要件 :不法行為法における権利論の地位・序説」、（2023 年）］

- ការសិក្សាលទ្ធិផ្លូវច្បាប់នៃសំណងសម្រាប់ការខូចខាតដោយផ្អែកលើការរំលោភកម្មសិទ្ធិបញ្ញា, ឆ្នាំ២០២៤［REACH VILY、「知的財産権侵害に基づく損害賠償法理についての一考察―消極的知的財産損害の算定方法を中心に―」（2024 年）］
- ការស្ទង់មតិលើការអនុវត្តច្បាប់នៅកម្ពុជា, ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជាក់, 経済産業省委託事業「カンボジア下位法令調査（2015 年 6 月）」、survey_201508_kh.pdf (jetro.go.jp)　（2024 年 5 月 3 日閲覧）
- សៀវភៅច្បាប់សិទ្ធិអ្នកនិពន្ធ, យ៉ាស៊ូស៊ី កូម៉ាដា, ឆ្នាំ២០១៦［駒田泰士ほか『著作権法』(有斐閣ストゥディア、2016 年)］

## ៣. គេហទំព័រផ្សេងៗ

- គេហទំព័រព័ត៌មានកោះសន្តិភាព, https://kohsantepheapdaily.com.kh/
- គេហទំព័រនាយកដ្ឋានកម្មសិទ្ធិបញ្ញា, https://www.cambodiaip.gov.kh/department-of-intellectual-property-d-ipr/
- គេហទំព័រអង្គការកម្មសិទ្ធិបញ្ញាពិភពលោក(WIPO), https://www.wipo.int/portal/en/index.html
- គេហទំព័ររបស់ភ្នាក់ងារសម្រាប់កិច្ចការវប្បធម៌ជប៉ុន, https://www.bunka.go.jp/
- គេហទំព័រតុលាការរបស់ប្រទេសជប៉ុន, https://www.courts.go.jp/index.html
- គេហទំព័រតុលាការកម្មសិទ្ធិបញ្ញាជប៉ុន, https://www.ip.courts.go.jp/index.html

# បញ្ជីឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា, លេខ២០៦ អនក្រ.បក, ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី២៖** គោលនយោបាយជាតិស្ដីពីកម្មសិទ្ធិបញ្ញាឆ្នាំ២០២៣-២០២៨, ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលសរសេរជាអក្សរកាត់ថា**គ.ក.ប.** ដើម្បីដឹកនាំការងារសម្របសម្រួលពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា សំដៅជំរុញនិងធានានូវការអនុវត្តគោលនយោបាយជាតិកម្មសិទ្ធិបញ្ញា ពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីសិក្សា ផ្សព្វផ្សាយ អនុវត្តច្បាប់ និងបទប្បញ្ញត្តិកម្មសិទ្ធិបញ្ញានានាឱ្យមានប្រសិទ្ធភាព និងអនុលោមតាមការសន្យារបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានាជាមួយអង្គការពាណិជ្ជកម្មពិភពលោក អង្គការសហប្រជាជាតិ អង្គការអន្តរជាតិនានា និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី តំបន់និងពហុភាគី រួមទាំងសហការទទួលនិងប្រើប្រាស់ជំនួយបច្ចេកទេស ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញាពីអង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍនានាឱ្យមានប្រសិទ្ធភាពខ្ពស់។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ចនៃគ.ក.ប.

**មាត្រា២ ._**

គ.ក.ប. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ១រូប | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ១រូប | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា១រូប | សមាជិក |
| - តំណាងក្រសួងបរិស្ថាន១រូប | សមាជិក |
| - តំណាងក្រសួងព័ត៌មាន១រូប | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌១រូប | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍១រូប | សមាជិក |
| - តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |
| - តំណាងក្រសួងទេសចរណ៍១រូប | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី១រូប | សមាជិក |
| - តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ១រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគ.ក.ប. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ ._**

គ.ក.ប. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកជាចំណុចកណ្តាល ក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគីឬពហុភាគី លើវិស័យកម្មសិទ្ធិបញ្ញា ជាមួយបណ្តាប្រទេស អង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងការអនុវត្តគម្រោងនិងប្រើប្រាស់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា
- សហការជំរុញការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានិងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ព្រមទាំងការអនុវត្តកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានា
- សហការជំរុញការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាព ដើម្បីការពារទប់ស្កាត់និងលុបបំបាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងការរំលោភបំពានសិទ្ធិជាក់លាក់ដែលពាក់ព័ន្ធផ្សេងទៀត ដែលរួមទាំងធនធានសេនេទិក-ពន្ធុ ចំណេះដឹងជាប្រពៃណី ការសម្តែង វប្បធម៌ប្រពៃណី ក្រោមប្រព័ន្ធច្បាប់ដោយឡែក
- សហការជំរុញការអនុវត្តពិធីសារណាហ្គូយ៉ាស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក-ពន្ធុ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក-ពន្ធុដោយស្មើភាព និងសមធម៌នៃអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ
- សហការសិក្សាស្រាវជ្រាវនិងវាយតម្លៃអំពីផលប្រយោជន៍ និងផលប៉ះពាល់នៃកិច្ចព្រមព្រៀង អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានាដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា

- សហការរៀបចំនិងជំរុញការអនុវត្តគោលនយោបាយជាតិកម្មសិទ្ធិបញ្ញា និងផែនការសកម្មភាពការងាររបស់**គ.ក.ប.**
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិផ្នែកកម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ចំណេះដឹងដល់មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការ អ្នកបណ្តុះបណ្តាល អ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យកម្មសិទ្ធិបញ្ញា ទាំងក្នុងវិស័យឯកជនក៏ដូចជាសាធារណជន
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំបញ្ចូលមុខវិជ្ជាកម្មសិទ្ធិបញ្ញាចូលក្នុងកម្មវិធីសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជននានា ការបោះពុម្ពឯកសារបណ្តុះបណ្តាលនិងឯកសារស្រាវជ្រាវផ្សេងៗពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនប្រចាំឆ្នាំ ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនពីប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៣
## ការប្រព្រឹត្តទៅនៃគ.ក.ប.

**មាត្រា៤ .-**

**គ.ក.ប.** ត្រូវធ្វើការប្រជុំយ៉ាងតិច១(មួយ)ដងក្នុង១(មួយ)ឆ្នាំ។

សមាសភាព**គ.ក.ប.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាមួយ ដឹកនាំការប្រជុំជំនួសបាន។

របៀបរបបនៃការប្រជុំរបស់គ.ក.ប. ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

ក្នុងករណីចាំបាច់ គ.ក.ប. អាចអញ្ជើញបុគ្គលដែលមានជំនាញឬតំណាងក្រសួង ស្ថាប័នដែលពាក់ព័ន្ធក្រៅពីសមាជិកផ្តល់សេចក្តីបំភ្លឺឬចូលរួមក្នុងកិច្ចប្រជុំ។

**មាត្រា៥ .-**

**គ.ក.ប.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ប្រធាន
- មន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា២ អនុប្រធាននិងសមាជិក។

លេខាធិការដ្ឋានគ.ក.ប. មានទីតាំងស្ថិតនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម និងមានសិទ្ធិប្រើមន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញាតាមការចាំបាច់។

សមាសភាព តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាននៃ**គ.ក.ប.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគ.ក.ប.។

**មាត្រា៦ .-**

**គ.ក.ប.** មានសិទ្ធិប្រើរូបសញ្ញានិងត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៤
## ប្រភពធនធាននិងការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា៧ .-**

**គ.ក.ប.** មានធនធានសម្រាប់អនុវត្តសកម្មភាពការងារដោយថវិកាជាតិ នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម។

**គ.ក.ប.** មានសិទ្ធិទទួលនិងគ្រប់គ្រងតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន មូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា៨ .-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការតែងតាំងនិងការបង្កើតយន្តការនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងកម្មសិទ្ធិបញ្ញា ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

អនុក្រឹត្យលេខ១៤២ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ឆ្នាំ២០២៣-២០២៨

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៣

មាតិកា

# បុព្វកថា

អស់រយៈពេលជាងពីរទសវត្សកន្លងទៅ ចាប់តាំងពីការដាក់ចេញ **នយោបាយឈ្នះ ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បាននាំមកនូវសុខសន្តិភាព សាមគ្គីភាពជាតិ និងស្ថិរភាពនយោបាយនៅទូទាំងប្រទេស ដែលបង្កើតបានជាមូលដ្ឋានគ្រឹះដ៏សំខាន់នៅក្នុងការស្តារ កសាង និងធានាបាននិរន្តរភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច របស់ប្រទេសកម្ពុជាប្រកបដោយបរិយាប័ន្ន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនិងអនុវត្តយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល ប្រកបដោយការទទួលខុសត្រូវខ្ពស់របស់ក្រសួងស្ថាប័នពាក់ព័ន្ធ និងមានការចូលរួមគាំទ្រពីវិស័យឯកជនដែលជួយជំរុញការធ្វើកំណែទម្រង់ខាងក្នុង ឱ្យកាន់តែស៊ីជម្រៅសំដៅដល់ការលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលការងារ ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនិងវិនិយោគព្រមទាំងការចាប់យកនូវកាលានុវត្តភាពថ្មីៗ ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចទាំងនៅក្នុងកម្រិតតំបន់និងពិភពលោកដែលធ្វើឱ្យមានការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ដែលឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យមក្នុងរង្វង់៧ភាគរយក្នុងមួយឆ្នាំ គិតចាប់តាំងពីឆ្នាំ២០០៦ដល់ឆ្នាំ២០១៩ ការកាត់បន្ថយនៃអត្រាភាពក្រីក្រ ការអភិវឌ្ឍលើគ្រប់វិស័យ និងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ ព្រមទាំងការកសាងបាននូវភាពធន់សេដ្ឋកិច្ចរបស់កម្ពុជា ដែលអាចទប់ទល់ទៅនឹងវិបត្តិសាកលលោកនានា។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីសម្រេចបានកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០ តាមរយៈការចាប់យកកាលានុវត្តភាពនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែងនិងការលើកកម្ពស់ផលិតភាព ការធ្វើទំនើបកម្មសហគ្រាសធុនមីក្រូ តូច និងមធ្យម ការបង្កើនការកែច្នៃផលិតផលក្នុងស្រុក ដើម្បីបង្កើនការនាំចេញ និងកាត់បន្ថយការនាំចូល និងការទាញយកប្រយោជន៍ជាអតិបរមាពី វិស័យវប្បធម៌ វិស័យទេសចរណ៍ វិស័យឧស្សាហកម្មច្នៃប្រឌិត និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីបង្កើនតម្លៃបន្ថែមក្នុងសេដ្ឋកិច្ច និងប្រែក្លាយសក្តានុពលទាំងអស់នោះទៅជាឧត្តមភាពនៃការប្រកួតប្រជែង។ ការចាប់យកកាលានុវត្តភាពនេះ អាចធ្វើទៅបាន ចាំបាច់មានការពង្រឹងប្រព័ន្ធកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់កិច្ចការពារ ម៉ាក ប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ការសម្ងាត់ពាណិជ្ជកម្ម ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី វិញ្ញត្តិវប្បធម៌ និងសមាសភាពកម្មសិទ្ធិបញ្ញាដទៃទៀត ដើម្បីលើកទឹកចិត្តអ្នកវិនិយោគក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ ការផ្ទេរបច្ចេកវិទ្យានិងការអភិវឌ្ឍផលិតផល។

បន្ទាប់ពីក្លាយជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅឆ្នាំ១៩៩៥ និងជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤រួចមក រាជរដ្ឋាភិបាលបានកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដើម្បីជំរុញពាណិជ្ជកម្ម និងវិនិយោគ លើកកម្ពស់វប្បធម៌ និងជំរុញការច្នៃប្រឌិត។

ក្នុងគោលបំណងបន្តអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញានៅព្រះរាជាណាចក្រកម្ពុជា ឱ្យស្របទៅនឹងរបត់អន្តរជាតិ ដើម្បីកាត់បន្ថយគម្លាតនៃការអភិវឌ្ឍកម្មសិទ្ធិបញ្ញា គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ ត្រូវបានរៀបចំឡើងដោយដាក់ចេញយុទ្ធសាស្ត្រចំនួន៦(ប្រាំមួយ) ដែលយុទ្ធសាស្ត្រនីមួយៗ មានចង្កោមសកម្មភាពប្រទាក់ក្រឡាគ្នា ដែលភាគីពាក់ព័ន្ធអាចអនុវត្តបាន ដើម្បីបង្កើតជាប្រព័ន្ធអេកូឡូស៊ីកម្មសិទ្ធិបញ្ញា ដែលគ្របដណ្តប់គ្រប់ទិដ្ឋភាព ក្នុងវិស័យកម្មសិទ្ធិបញ្ញារួមបញ្ចូលការបង្កើតក្របខ័ណ្ឌគតិយុត្តមួយដែលមានសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ ពង្រីកវិសាលភាពនៃកិច្ចការពារកម្មសិទ្ធិបញ្ញា និងជំរុញការប្រើប្រាស់ឧបករណ៍កម្មសិទ្ធិបញ្ញា ឱ្យក្លាយទៅជាកម្លាំងចលករ ជំរុញនវានុវត្តភាពក្នុងសេដ្ឋកិច្ចឌីជីថល ប្រែក្លាយប្រទេសកម្ពុជាទៅជាសង្គមផ្អែកលើចំណេះដឹង និងបង្កើនល្បឿននៃការអភិវឌ្ឍ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះគំនិតផ្តួចផ្តើមរបស់ **ឯកឧត្តម ប៉ាន សូរស័ក្តិ អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** និង **លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា** ដែលបានខិតខំប្រឹងប្រែងក្នុងការដឹកនាំរៀបចំគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាឱ្យសម្រេចបានលទ្ធផលគួរជាទីមោទនៈ។ ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងអំណរគុណ **ឯកឧត្តម អ៊ុក ប្រជា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា(គ.ក.ប.) និងសមាជិកលេខាធិការដ្ឋាននៃ គ.ក.ប. ដែលបានចូលរួមប្រកបដោយស្មារតីបុរេសកម្ម និងប្រកបដោយការទទួលខុសត្រូវ។

ថ្ងៃ[illegible]ខែ[illegible]ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ខែ [illegible] ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**



148

## អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧ភាគរយក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ ដែលធ្វើឱ្យមានការអភិវឌ្ឍគ្រប់វិស័យ និងសម្រេចបាននូវប្រទេសចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥។ សមិទ្ធផលដ៏ត្រចះត្រចង់នេះ បានកើតចេញពីការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍជាតិ យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល និងគោលនយោបាយតាមវិស័យនានា ដើម្បីតម្រង់សកម្មភាពការងារឱ្យចំគោលដៅ ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍជាក់ស្តែងរបស់ប្រទេសនិងតាមរបត់អន្តរជាតិ។

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីសម្រេចបាន កំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០។ ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណនេះឱ្យមានប្រសិទ្ធភាព គឺជាការចាំបាច់ណាស់ក្នុងការពង្រឹងប្រព័ន្ធកម្មសិទ្ធិបញ្ញា ឱ្យក្លាយជាសសរស្តម្ភដ៏រឹងមាំមួយ សម្រាប់ការគាំទ្រនិងជំរុញការរីកចម្រើនក្នុងវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កសិកម្ម ទេសចរណ៍ សុខាភិបាល និងវប្បធម៌ តាមរយៈការផ្តល់ការលើកទឹកចិត្តនិងជំរុញនវានុវត្តន៍ក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍផលិតផល ការបង្កើតបច្ចេកវិទ្យាទំនើប ការនាំមកនូវរបកគំហើញថ្មីៗ និងការផ្ទេរបច្ចេកវិទ្យា ដែលជាលទ្ធផលមកពីការផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញា និងលើកកម្ពស់ការធ្វើពាណិជ្ជូបនីយកម្មទ្រព្យកម្មសិទ្ធិបញ្ញា។

ក្នុងគោលបំណងរៀបចំឱ្យមានផែនទីបង្ហាញផ្លូវមួយឱ្យបានច្បាស់លាស់ ក្នុងការអភិវឌ្ឍវិស័យកម្មសិទ្ធិបញ្ញារបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានការពាក់ព័ន្ធនឹងអន្តរវិស័យ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានចង្អុលបង្ហាញឱ្យក្រសួងពាក់ព័ន្ធបន្តសម្របសម្រួលតាមរយៈយន្តការគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងរៀបចំគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជាឱ្យក្លាយទៅជាកម្លាំងចលករ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ ទេសចរណ៍ និងកសិកម្ម តាមរយៈការលើកកម្ពស់កិច្ចការពារកម្មសិទ្ធិបញ្ញា កេរ្តិ៍ឈ្មោះម៉ាក និងផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ការបង្កើតស្នាដៃ សិទ្ធិអ្នកនិពន្ធ តក្កកម្ម ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ និងជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងការបង្កើតផលិតផលបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិត និងការបង្កើតថ្មី ព្រមទាំងឧស្សាហកម្មវប្បធម៌ ឱ្យឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ច និងសង្គមឌីជីថល និងបដិវត្តឧស្សាហកម្មជំនាន់ទី៤ ហើយចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០៥០។

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ មានគោលដៅបីសំខាន់ៗ : (ទី១)រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាឱ្យស្របតាមបទដ្ឋានអន្តរជាតិ និងពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចនិងសង្គម និងការអភិវឌ្ឍ (ទី២)ពង្រឹងនិងលើកកម្ពស់សមត្ថភាពមន្ត្រីនិងអង្គភាពក្នុងការអនុវត្តប្រព័ន្ធកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និង(ទី៣)ផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងសាធារណៈអំពីការប្រើប្រាស់កម្មសិទ្ធិបញ្ញា ក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន៦ និងផែនការសកម្មភាព គំនិតផ្តួចផ្តើម ប្រទាក់ប្រឡាគ្នា ដើម្បីសម្រេចគោលបំណងនិងគោលដៅ ដោយបង្កើតឱ្យមានក្របខ័ណ្ឌមួយច្បាស់លាស់សម្រាប់

ក្រសួងនិងស្ថាប័នទទួលបន្ទុកក្នុងការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដើម្បីសំដៅដល់ការអភិវឌ្ឍកម្មសិទ្ធិបញ្ញាផ្តោតលើវិស័យអាទិភាពចំនួន៧(ប្រាំពីរ) រួមមាន(១)កសិកម្ម (២)ពាណិជ្ជកម្មនិងឧស្សាហកម្ម (៣)វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (៤)សុខាភិបាល (៥)វប្បធម៌ (៦)ទេសចរណ៍ និង(៧)អប់រំនិងការលើកកម្ពស់ចំណេះដឹងសាធារណៈ។

ទន្ទឹមនឹងនេះ គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ ជាផែនទីបង្ហាញផ្លូវនិងជំរុញភាគីពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពជាយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងកម្មសិទ្ធិបញ្ញា កៀរគរធនធានក្នុងការលើកកម្ពស់កម្មសិទ្ធិបញ្ញា លើកកម្ពស់ប្រសិទ្ធភាពការងារ និងពង្រីកវិសាលភាពនៃការយល់ដឹងពីកម្មសិទ្ធិបញ្ញាទៅដល់គ្រប់ផ្នែកទាំងអស់នៃសង្គម។

ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ខ្ញុំជឿជាក់ថា ការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា នឹងទទួលបានលទ្ធផលតាមការរំពឹងទុកនិងរួមចំណែកអភិវឌ្ឍវិស័យទាំងប្រាំពីរដែលបានកំណត់ខាងលើ ដើម្បីបង្កើតផលិតភាពសេដ្ឋកិច្ច កសាងសុខុដុមនីយកម្មធុរកិច្ច ព្រមទាំងជានាដល់ការអភិវឌ្ឍ ប្រព្រឹត្តទៅប្រកបដោយចីរភាពនិងបរិយាប័ន្ន ដែលជាវត្ថុបំណងរួមរបស់យើងទាំងអស់គ្នា។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម ស្វួន វិជ្ជា** ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា និងជាប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និងក្រុមការងារនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានខិតខំសម្របសម្រួល និងចូលរួមតាក់តែងគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះឡើង។ ជាមួយគ្នានេះផងដែរ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា(គ.ក.ប.) សមាជិកលេខាធិការដ្ឋាននៃ គ.ក.ប. និងវិស័យឯកជនដែលបានចូលរួមយ៉ាងសកម្មក្នុងការផ្តល់ធាតុចូល ដែលធ្វើឱ្យការរៀបចំគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ជាថ្មីម្តងទៀត ខ្ញុំសូមជំរុញឱ្យភាគីពាក់ព័ន្ធទាំងអស់ មកពីស្ថាប័នរដ្ឋ វិស័យឯកជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា បន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញានិងលេខាធិការដ្ឋាននៃ គ.ក.ប. ចូលរួមអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ឱ្យមានប្រសិទ្ធភាពដើម្បីជាប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា**

**ចម និម្មល**

# មាតិកា


**បុព្វកថា** ..... i
**អារម្ភកថា** ..... iii
**បញ្ជីអក្សរកាត់** ..... vi
**១- សេចក្តីផ្តើម** ..... ១
**២- ចក្ខុវិស័យ** ..... ៣
**៣- គោលបំណងនិងគោលដៅ** ..... ៣
  ៣.១- គោលបំណង ..... ៣
  ៣.២- គោលដៅ ..... ៣
**៤- យុទ្ធសាស្ត្រ** ..... ៣
**៥- ផែនការសកម្មភាព** ..... ៨
  ៥.១- ក្របខ័ណ្ឌគតិយុត្តទាក់ទងនឹងកម្មសិទ្ធិបញ្ញា ..... ៨
  ៥.២- ពង្រីកនិងលើកកម្ពស់សមត្ថភាពមន្ត្រីនិងអង្គភាពក្នុងការអនុវត្តប្រព័ន្ធកម្មសិទ្ធិបញ្ញា ..... ៨
  ៥.៣- ផ្សព្វផ្សាយនិងលើកកម្ពស់ចំណេះដឹងសាធារណៈ អំពីការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ..... ៨
**៦- ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ** ..... ៩
**៧- សេចក្តីសន្និដ្ឋាន** ..... ៩
**៨- សន្ទានុក្រម** ..... ១១
**ឧបសម្ព័ន្ធ : សកម្មភាពលម្អិតសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា** ១៧

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| MoC | ក្រសួងពាណិជ្ជកម្ម | Ministry of Commerce |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | Ministry of Industry, Science, Technology & Innovation |
| MoCFA | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | Ministry of Culture and Fine Arts |
| MEF | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | Ministry of Economy and Finance |
| OCM | ទីស្តីការគណៈរដ្ឋមន្ត្រី | Office of the Council of Ministers |
| MoI | ក្រសួងមហាផ្ទៃ | Ministry of Interior |
| MFA.IC | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | Ministry of Foreign Affairs and International Cooperation |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | Ministry of Agriculture, Forestry and Fisheries |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា | Ministry of Education, Youth and Sport |
| MoE | ក្រសួងបរិស្ថាន | Ministry of Environment |
| MoInfo | ក្រសួងព័ត៌មាន | Ministry of Information |
| MoJ | ក្រសួងយុត្តិធម៌ | Ministry of Justice |
| MPTC | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | Ministry of Post and Telecommunications |
| MoH | ក្រសួងសុខាភិបាល | Ministry of Health |
| MoT | ក្រសួងទេសចរណ៍ | Ministry of Tourism |
| MoWA | ក្រសួងកិច្ចការនារី | Ministry of Women's Affairs |
| MLVT | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | Ministry of Labour and Vocational Training |
| NCIP | គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា | National Committee for Intellectual Property |
| DIP/MoC | នាយកដ្ឋានកម្មសិទ្ធិបញ្ញា | Department of Intellectual Property |
| DIP/MISTI | នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | Department of Industrial Property |
| DCRR | នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល | Department of Copyright and Related Rights |

## ១- សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាបានបង្កើតច្បាប់ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា តាមរយៈក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលមានចែងក្នុងមាត្រា៣៩១-បទក្លែងសញ្ញា(Marque) ដែលបោះក្នុងនាមនៃក្រុមរាជការសាធារណៈក្នុងផលប្រយោជន៍នៃរតនវត្ថុរបស់រង្វត្រូវតុលាការបារាំងជំនុំជម្រះ។

បន្ទាប់មក មានម៉ាកមួយចំនួនត្រូវបានចុះបញ្ជីការពារនៅព្រះរាជាណាចក្រកម្ពុជានៅក្នុងទសវត្ស១៩៦០និង១៩៧០ ប៉ុន្តែដោយសារមូលហេតុអស្ថិរភាពនយោបាយ ធ្វើឱ្យប្រព័ន្ធកម្មសិទ្ធិបញ្ញាត្រូវបានបោះបង់ចោលអស់រយៈពេលជាងពីរទសវត្សរហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ទើបព្រះរាជាណាចក្រកម្ពុជា មានឱកាសក្នុងការស្តារហេដ្ឋារចនាសម្ព័ន្ធនិងសេដ្ឋកិច្ចឡើងវិញ ដែលក្នុងនោះប្រព័ន្ធកម្មសិទ្ធិបញ្ញាចាប់ផ្តើមដំណើរការឡើងវិញ ហើយកិច្ចការចុះបញ្ជីម៉ាកស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល(បច្ចុប្បន្នក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) ហើយកិច្ចការពារសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ នៅឆ្នាំ១៩៩១ ការិយាល័យពាណិជ្ជសញ្ញាត្រូវបានបង្កើតឡើងនៅក្រោមក្រសួងពាណិជ្ជកម្ម។ បន្ទាប់មក នៅឆ្នាំ១៩៩៤ ការិយាល័យនេះត្រូវបានបង្កើតទៅជានាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ហើយបន្តបន្ទាប់មកទៀតត្រូវបានកែសម្រួលរចនាសម្ព័ន្ធនិងបន្ថែមតួនាទីភារកិច្ចក្នុងការចុះបញ្ជីការពារម៉ាកក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា ការចុះបញ្ជីម៉ាកសាជាថ្មី និងកិច្ចការក្រោយចុះបញ្ជីម៉ាកដទៃទៀត ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ការសម្ងាត់ពាណិជ្ជកម្មនិងព័ត៌មានមិនបង្ហាញ និងការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិតាមប្រព័ន្ធម៉ាឌ្រីដ។

នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកទាំងបីនៃកម្មសិទ្ធិបញ្ញា ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធាន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាអនុប្រធាន ឯកឧត្តមតំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងឯកឧត្តមតំណាងក្រសួងព័ត៌មាន ជាសមាជិក។

ហើយនៅឆ្នាំ២០០៨ រាជរដ្ឋាភិបាល បានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា(គ.ក.ប.) ដែលមានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធាន រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ជាអនុប្រធាន និងមានតំណាងក្រសួងចំនួន១១ផ្សេងទៀតជាសមាជិក។

ក្នុងគោលបំណង ដើម្បីដឹកនាំការងារសម្របសម្រួលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា សំដៅជំរុញនិងធានានូវការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ពង្រឹងកិច្ចសហការរវាងក្រសួងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីសិក្សា ផ្សព្វផ្សាយ អនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាឱ្យមានប្រសិទ្ធភាព និងអនុលោមតាមកាតព្វកិច្ចរបស់កម្ពុជាក្រោមក្របខ័ណ្ឌអន្តរជាតិ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២០៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលមានរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធាន រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធាន និងរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាអនុប្រធានអចិន្ត្រៃយ៍ និងមានតំណាងក្រសួងចំនួន១៣ផ្សេងទៀតជាសមាជិក ហើយមានប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ជាប្រធានលេខាធិការដ្ឋាន និងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធជាអនុប្រធាននិងសមាជិក។

ដើម្បីធ្វើសមាហរណកម្មវិស័យកម្មសិទ្ធិបញ្ញាទៅក្នុងតំបន់និងសាកលលោក ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលមានកាតព្វកិច្ចអនុវត្តកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹង

កម្មសិទ្ធិបញ្ញា ចូលជាសមាជិកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងជារដ្ឋភាគីនៃអនុសញ្ញាទីក្រុងប៉ារីស ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ពិធីសារទីក្រុងម៉ាឌ្រីដ ស្តីពីការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ កិច្ចព្រមព្រៀងទីក្រុងហេច ស្តីពីកិច្ចការពារគំនូរឧស្សាហកម្ម សន្ធិសញ្ញា ស្តីពីកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម កិច្ចព្រមព្រៀងទីក្រុងលីសបោនសម្រាប់កិច្ចការពារ ការហៅឈ្មោះតាមប្រភពទំនិញ និងការចុះបញ្ជីអន្តរជាតិ សន្ធិសញ្ញាទីក្រុងប៉េកាំង ស្តីពីការសម្តែងសោតទស្សន៍ អនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈ និងពិធីសារណាហ្គូយ៉ា ស្តីពីសិទ្ធិទទួលផលពីធនធានសេនេទិក-ពន្ធុ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានសេនេទិក-ពន្ធុដោយស្មើភាពនិងសមធម៌នៃអនុសញ្ញាសហប្រជាជាតិ ស្តីពីជីវៈចម្រុះនិងបានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកម្មសិទ្ធិបញ្ញាជាមួយដៃគូអភិវឌ្ឍនានា។

ព្រះរាជាណាចក្រកម្ពុជាបានរៀបចំច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងរៀបចំអនុក្រឹត្យ ប្រកាសពាក់ព័ន្ធកម្មសិទ្ធិបញ្ញាមួយចំនួន។ លើសពីនេះបានធ្វើវិសោធនកម្មច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ត្រង់មាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦។

សហគមន៍សេដ្ឋកិច្ចអាស៊ានត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥ ហើយផែនការសកម្មភាពកម្មសិទ្ធិបញ្ញាអាស៊ានឆ្នាំ២០១៦-២០២៥ បានអនុម័ត ដែលនៅក្នុងនោះមានគោលដៅយុទ្ធសាស្ត្រ : (១)ការបង្កើតប្រព័ន្ធកម្មសិទ្ធិបញ្ញាអាស៊ានកាន់តែរឹងមាំបន្ថែមទៀត ដោយពង្រឹងអង្គភាពកម្មសិទ្ធិបញ្ញានិងការកសាងហេដ្ឋារចនាសម្ព័ន្ធកម្មសិទ្ធិបញ្ញាក្នុងតំបន់ (២)ការបង្កើតហេដ្ឋារចនាសម្ព័ន្ធនិងថ្នាលកម្មសិទ្ធិបញ្ញាក្នុងតំបន់ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (៣)បង្កើតប្រព័ន្ធអេកូកម្មសិទ្ធិបញ្ញាអាស៊ានប្រកបដោយបរិយាប័ន្ននិងកាន់តែទូលំទូលាយបន្ថែមទៀត និង (៤)លើកកម្ពស់យន្តការតំបន់ ដើម្បីជំរុញការបង្កើតទ្រព្យនិងការធ្វើពាណិជ្ជូបនីយកម្មកម្មសិទ្ធិបញ្ញា ជាពិសេសម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងចំណេះដឹងជាប្រពៃណី។

ទន្ទឹមនឹងនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាបន្ថែមទៀត និងធ្វើវិសោធនកម្មច្បាប់កម្មសិទ្ធិបញ្ញាដែលមានស្រាប់ និងបន្តចូលជាសមាជិកនៃកិច្ចព្រមព្រៀង សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដទៃទៀត ឱ្យស្របតាមកាតព្វកិច្ចអន្តរជាតិ និងអាចទាញយកប្រយោជន៍សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងដំណាក់កាលអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញានេះ ព្រះរាជាណាចក្រកម្ពុជាមានបញ្ហាប្រឈមក្នុងការពង្រឹងស្ថាប័នកម្មសិទ្ធិបញ្ញា ក្នុងការគ្រប់គ្រងច្បាប់និងប្រព័ន្ធកម្មសិទ្ធិបញ្ញា ឱ្យមានតុល្យភាពនិងប្រសិទ្ធភាព ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីលើកកម្ពស់កិច្ចការពារកម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នសាធារណៈនិងវិស័យឯកជនក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ ការធ្វើពាណិជ្ជូបនីយកម្មនៃទ្រព្យកម្មសិទ្ធិបញ្ញា ការលើកកម្ពស់ការអប់រំនិងចំណេះដឹងសាធារណៈ ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ការពង្រឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងអង្គភាពកម្មសិទ្ធិបញ្ញាដែលនៅដាច់ដោយឡែកពីគ្នា។

ដើម្បីចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ បញ្ចកោណទី៣ មុំទី២និងទី៤របស់រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព ក្នុងការអភិវឌ្ឍវិស័យឯកជនដោយផ្តោតសំខាន់លើការលើកកម្ពស់ភាពប្រកួតប្រជែង និងការចូលរួមរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យមក្នុងវិស័យសេដ្ឋកិច្ច និងចូលរួមអនុវត្តគោលនយោបាយ សេដ្ឋកិច្ចសង្គមឌីជីថលដែលមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤តាមរយៈការផ្សារភ្ជាប់គម្លាត និងបង្កើតហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងឌីជីថលនានា ការផ្ទេរបច្ចេកវិទ្យា ការស្រាវជ្រាវ និងការអភិវឌ្ឍ និងការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិដើម្បីគាំទ្រដល់កំណើន បង្កើនផលិតភាព និងបម្លែងទៅជា

សេដ្ឋកិច្ចឌីជីថល ដើម្បីឱ្យវិស័យឯកជនអាចទទួល អភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ដំណើរការអាជីវកម្មរបស់ខ្លួន នៅគ្រប់ដំណាក់កាលនៃខ្សែច្រវាក់តម្លៃ គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាត្រូវបានរៀបចំឡើងដែលមានចក្ខុវិស័យ គោលបំណង និងគោលដៅ ដូចខាងក្រោម៖

## ២- ចក្ខុវិស័យ

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា មានចក្ខុវិស័យអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជាឱ្យក្លាយទៅជាកម្លាំងចលករ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ ទេសចរណ៍ និងកសិកម្ម ឱ្យឆ្លើយតបទៅនឹងបរិបទសេដ្ឋកិច្ច និងសង្គមឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ហើយចូលរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០៥០។

## ៣- គោលបំណងនិងគោលដៅ

### ៣.១- គោលបំណង

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា មានគោលបំណងលើកកម្ពស់កិច្ចការពារកម្មសិទ្ធិបញ្ញាជាអាទិ៍ កេរ្តិ៍ឈ្មោះម៉ាក និងផលិតផល របស់ព្រះរាជាណាចក្រកម្ពុជា ការបង្កើតស្នាដៃ សិទ្ធិអ្នកនិពន្ធ តក្កកម្ម ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី វិញ្ញត្តិវប្បធម៌ និងជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងការបង្កើត ផលិតផលបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិត និងការបង្កើតថ្មី ព្រមទាំងឧស្សាហកម្មវប្បធម៌។

### ៣.២- គោលដៅ

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា មានគោលដៅលើកកម្ពស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍវិស័យអាទិភាពសំខាន់ៗចំនួន៧ រួមមាន (១)កសិកម្ម (២)ពាណិជ្ជកម្មនិងឧស្សាហកម្ម (៣)វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (៤)សុខាភិបាល (៥)វប្បធម៌ (៦)ទេសចរណ៍ និង(៧)អប់រំនិងការលើកកម្ពស់ចំណេះដឹងសាធារណៈ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតទៅលើ៖

១- ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឱ្យស្របតាមបទដ្ឋានអន្តរជាតិ និងពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ច និងសង្គម និងការអភិវឌ្ឍ។

២- ការពង្រឹងនិងលើកកម្ពស់សមត្ថភាពមន្ត្រីនិងអង្គភាពក្នុងការអនុវត្តប្រព័ន្ធកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់ការអភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គម។

៣- ការផ្សព្វផ្សាយនិងលើកកម្ពស់ចំណេះដឹងសាធារណៈអំពីការប្រើប្រាស់កម្មសិទ្ធិបញ្ញា ក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

## ៤- យុទ្ធសាស្ត្រ

**យុទ្ធសាស្ត្រទី១ : រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដោយអនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិ សម្រាប់ផ្តល់កិច្ចការពារនិងលើកកម្ពស់កម្មសិទ្ធិបញ្ញាប្រកបដោយប្រសិទ្ធភាព ដោយផ្តល់សមភាពនៃផលប្រយោជន៍ ម្ចាស់សិទ្ធិនិងផលប្រយោជន៍សាធារណៈ ដើម្បីលើកកម្ពស់សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកវិទ្យា វប្បធម៌ និងផ្តល់ជំនឿទុកចិត្ត ដល់អ្នកវិនិយោគ តាមរយៈ៖**

- ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីផ្តល់កិច្ចការពារការសម្គាល់ពាណិជ្ជកម្ម សៀគ្វីបង្រួម ការគ្រប់គ្រង ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ គាំទ្រនិងអភិវឌ្ឍវិស័យវប្បធម៌ ទេសចរណ៍ និងទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនៃនិមិត្តសញ្ញាជាតិ និងវិស័យពាក់ព័ន្ធកម្មសិទ្ធិបញ្ញាផ្សេងទៀត

- ការពិនិត្យឡើងវិញនូវច្បាប់កម្មសិទ្ធិបញ្ញានិងធ្វើវិសោធនកម្មក្នុងករណីចាំបាច់ ដើម្បីទាញយកប្រយោជន៍ពីភាពអនុគ្រោះនៃកិច្ចព្រមព្រៀងអន្តរជាតិ
- ការសិក្សាអំពីគុណសម្បត្តិនិងគុណវិបត្តិនៃកិច្ចព្រមព្រៀង សន្ធិសញ្ញា អនុសញ្ញាពាក់ព័ន្ធកម្មសិទ្ធិបញ្ញាមុនព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកភាគីហត្ថលេខី និងផ្សារភ្ជាប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិជាមួយកម្មសិទ្ធិបញ្ញា
- ការសិក្សាស្រាវជ្រាវនិងបន្តផ្សារភ្ជាប់រាល់វេទិកាជាតិនិងអន្តរជាតិ ទាក់ទងនឹងកិច្ចការពារធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌
- ការបង្កើតយន្តការដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាបៃតងពីប្រទេសអភិវឌ្ឍ ក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ព្រមទាំងសិក្សាអំពីបញ្ហាប្រឈមនៃការផ្ទេរបច្ចេកវិទ្យា ការផ្តល់អាជ្ញាបណ្ណ និងចំណេះធ្វើ
- ការបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីទាញយកប្រយោជន៍ពីអាជ្ញាបណ្ណបញ្ជា លើសិទ្ធិផលិតឡើងវិញ និងសិទ្ធិបកប្រែស្នាដៃនិងកម្មសិទ្ធិបញ្ញាដទៃទៀត អាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ការធ្វើអាជីវកម្មដោយរាជរដ្ឋាភិបាល ឬដោយបុគ្គលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល និងអាជ្ញាបណ្ណបញ្ជាសម្រាប់ប្រកាសនីយបត្រគក្កកម្ម
- ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងធ្វើបច្ចុប្បន្នកម្ម វិធាន មគ្គុទ្ទេសក៍ នីតិវិធីរដ្ឋបាល សម្រាប់ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាប្រកបដោយភាពជាក់លាក់ មានលក្ខណៈងាយស្រួល និងមានតម្លាភាព។

**យុទ្ធសាស្ត្រទី២ : ធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលនិងការគ្រប់គ្រង ដើម្បីពង្រឹងស្ថាប័នក្នុងការគ្រប់គ្រងច្បាប់កម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាព និងប្រព័ន្ធកម្មសិទ្ធិបញ្ញាឱ្យមានតុល្យភាព ដោយលើកកម្ពស់ការផ្តល់សេវាចុះបញ្ជី ជំរុញការចុះបញ្ជី និងផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញា និងបង្កើតប្រព័ន្ធទិន្នន័យសម្រាប់ការផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា ក្នុងការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ និងអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម និងជំរុញបច្ចេកវិទ្យានិងនវានុវត្តន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា បន្ថែមទៀត តាមរយៈ៖**

- ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងប្រព័ន្ធព័ត៌មានវិទ្យានៃអង្គភាពកម្មសិទ្ធិបញ្ញា និងពង្រឹងការផ្តល់សេវាកម្មសិទ្ធិបញ្ញាឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា
- ការធ្វើការវិភាគលើធនធានមនុស្សនិងរចនាសម្ព័ន្ធអង្គភាពកម្មសិទ្ធិបញ្ញា ដើម្បីដោះស្រាយបញ្ហានៃការគ្រប់គ្រងនិងការចុះបញ្ជីកម្មសិទ្ធិបញ្ញា ព្រមទាំងលើកកម្ពស់គុណភាព និងអភិវឌ្ឍអង្គភាពកម្មសិទ្ធិបញ្ញាស្របតាមបទដ្ឋានអន្តរជាតិ
- ការបង្កើតផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញានិងការផ្ទេរបច្ចេកវិទ្យានៅតាមបណ្តាសាកលវិទ្យាល័យ វិទ្យាស្ថាន និងស្ថាប័នពាក់ព័ន្ធនឹងការស្រាវជ្រាវនិងការអភិវឌ្ឍ
- ការបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គភាពកម្មសិទ្ធិបញ្ញាជាតិនិងអន្តរជាតិ ក្នុងគោលបំណងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យកសិកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ការផ្តល់កិច្ចការពារនិងគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម និងកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមចំណែកអភិវឌ្ឍវិស័យកសិកម្ម ពាណិជ្ជកម្ម អភិរក្សវប្បធម៌ និងឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- ការផ្តល់កិច្ចការពារពូជថ្មីនៃដំណាំនិងជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា សម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍពូជថ្មីនៃដំណាំ និងបង្កើតទំនាក់ទំនងរវាងអាជ្ញាធរមានសមត្ថកិច្ច អ្នកបង្កាត់ពូជ និងសាកលវិទ្យាល័យ វិទ្យាស្ថានសិក្សាស្រាវជ្រាវកសិកម្ម

- ការរៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មនិងប្រព័ន្ធទិន្នន័យ សម្រាប់គ្រប់គ្រងការចុះបញ្ជីស្នាដៃសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងសម្រាប់កត់ត្រាតម្កល់ និងស្រាវជ្រាវស្នាដៃសិទ្ធិអ្នកនិពន្ធ និងផ្តល់ព័ត៌មានសម្រាប់ការចូលទៅកាន់ប្រព័ន្ធទិន្នន័យសិទ្ធិអ្នកនិពន្ធសម្រាប់ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល
- ការបង្កើតមជ្ឈមណ្ឌលផ្តល់អាជ្ញាបណ្ណសមូហភាពសម្រាប់ស្នាដៃសិទ្ធិអ្នកនិពន្ធ និងផ្តល់ការគាំទ្រនិងប្រឹក្សាយោបល់ដល់ម្ចាស់ស្នាដៃ ក្រោមអង្គភាពគ្រប់គ្រងសិទ្ធិរួម
- ការបង្កើតផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញានៅតាមបណ្តាគ្រឹះស្ថានផលិតឱសថ ដើម្បីជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍផលិតផលឱសថ និងជំរុញការប្រើប្រាស់ប្រព័ន្ធទិន្នន័យសម្រាប់ការស្រាវជ្រាវផលិតផលឱសថ និងការអភិវឌ្ឍវិទ្យាសាស្ត្រសុខាភិបាល
- ការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម សម្រាប់ផលិតផលឱសថបុរាណ
- ការបង្កើតនិងអភិវឌ្ឍមជ្ឈមណ្ឌលគាំពារព័ត៌មានបច្ចេកវិទ្យា ដើម្បីទទួលបានព័ត៌មានប្រកាសនីយបត្រតក្កកម្មឯកទេស សម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍ ការច្នៃប្រឌិត និងការទទួលបានព័ត៌មានកម្មសិទ្ធិបញ្ញាដទៃទៀត
- ការរៀបចំព្រឹត្តិការណ៍ជំរុញគំនិតច្នៃប្រឌិត តាមរយៈការប្រកួតប្រជែងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ និងការដាក់តាំងពិព័រណ៍ផលិតផលកម្មសិទ្ធិបញ្ញា
- ការរៀបចំយន្តការដើម្បីទទួលបានផលិតផលឱសថក្រោមប្រកាសនីយបត្រតក្កកម្ម និងឱសថទូទៅដទៃទៀតដែលព្រះរាជាណាចក្រកម្ពុជាមានតម្រូវការចាំបាច់ ក្នុងតម្លៃសមស្រប។

**យុទ្ធសាស្ត្រទី៣ : អភិវឌ្ឍមូលធនមនុស្សនៃស្ថាប័នសាធារណៈ ក្នុងការអភិវឌ្ឍធនធានមនុស្ស និងការលើកកម្ពស់សមត្ថភាពគ្រូបង្គោលសម្រាប់ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងជំនាញកម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍវិស័យវប្បធម៌ កសិកម្ម សុខាភិបាល វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈ៖**

- ការកសាងសមត្ថភាពមន្ត្រីទទួលបន្ទុកនិងភ្នាក់ងារកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់សេវានិងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម
- ការកសាងសមត្ថភាពរបស់មន្ត្រីគ្រប់គ្រងពូជដំណាំ ភ្នាក់ងារកម្មសិទ្ធិបញ្ញា អ្នកបង្កាត់ពូជថ្មីនៃដំណាំ និងផលិតករកសិកម្មឱ្យមានជំនាញកម្មសិទ្ធិបញ្ញា
- ការកសាងសមត្ថភាពនិងលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនៃនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ព្រមទាំងអភិវឌ្ឍសាលាសិល្បៈភាពយន្តនិងលើកកម្ពស់អភិបាលកិច្ចល្អនៃអង្គភាពគ្រប់គ្រងសិទ្ធិរួម
- ការកសាងសមត្ថភាពនិងអភិវឌ្ឍក្រុមប្រឹក្សាជាតិស្រាវជ្រាវវិទ្យាសាស្ត្រសុខាភិបាលនិងឱសថនៃព្រះរាជាណាចក្រកម្ពុជា និងផ្តល់ជំនាញកម្មសិទ្ធិបញ្ញាជូនដល់បុគ្គលិកសុខាភិបាលនិងគ្រឹះស្ថានផលិតឱសថសម្រាប់គាំទ្រដល់នវានុវត្តន៍ផ្នែកវេជ្ជសាស្ត្រ និងឱសថសាស្ត្រ និងបង្កើតបណ្តាញរឹងមាំជាមួយវិស័យឯកជន ដើម្បីទាក់ទាញវិនិយោគផ្ទាល់ក្នុងការផលិតឱសថថ្មីៗ
- ការលើកកម្ពស់សមត្ថភាពអង្គភាពកម្មសិទ្ធិបញ្ញានិងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីប្រើប្រាស់ប្រព័ន្ធទិន្នន័យកម្មសិទ្ធិបញ្ញាអន្តរជាតិ អំពីព័ត៌មានប្រកាសនីយបត្រតក្កកម្ម និងព័ត៌មានបច្ចេកវិទ្យាដទៃទៀត និងបង្កើតវិធីសាស្ត្រសមស្រប ក្នុងការលើកកម្ពស់ការច្នៃប្រឌិតថ្មីនៅក្នុងវិស័យអប់រំ
- ការជំរុញការអប់រំនិងការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញា ព្រមទាំងដកស្រង់បទពិសោធពីឧត្តមានុវត្តន៍របស់ប្រទេសអភិវឌ្ឍសម្រាប់អភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ ព័ត៌មានវិទ្យា សេដ្ឋកិច្ច សង្គមឌីជីថលកម្ពុជា
- ការកំណត់វិស័យអាទិភាពដែលជាតម្រូវការចាំបាច់របស់ជាតិ រួចផ្តល់មគ្គុទ្ទេសក៍សម្រាប់ធ្វើការស្រាវជ្រាវ និងការអភិវឌ្ឍ

- ការពង្រឹងសមត្ថភាពរបស់មន្ត្រីនៃអង្គភាពទទួលបន្ទុកកម្មសិទ្ធិបញ្ញានិងក្រសួងពាក់ព័ន្ធ ក្នុងការរៀបចំយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញានិងអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា។

**យុទ្ធសាស្ត្រទី៤ : ផ្សព្វផ្សាយនិងលើកកម្ពស់ការអប់រំ និងចំណេះដឹងសាធារណៈ អំពីកម្មសិទ្ធិបញ្ញា សម្រាប់ផលប្រយោជន៍សេដ្ឋកិច្ច សង្គម វប្បធម៌ កសិកម្ម ទេសចរណ៍ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈ៖**

- ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញានៃព្រះរាជាណាចក្រកម្ពុជា ជំនាញកម្មសិទ្ធិឧស្សាហកម្ម សិទ្ធិអ្នកនិពន្ធ និងកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម
- ការរៀបចំយុទ្ធនាការផ្សព្វផ្សាយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ផលិតផលម្ហូបអាហារ ផលិតផលបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិតរបស់កម្ពុជា ដើម្បីជំរុញការកសាងកេរ្តិ៍ឈ្មោះម៉ាក និងការប្រើប្រាស់ផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា
- ការផ្សព្វផ្សាយនិងលើកកម្ពស់សមត្ថភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍផលិតផលឱសថ តាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យបើកចំហ និងប្រព័ន្ធកម្មវិធីសិក្សាស្រាវជ្រាវសម្រាប់ការអភិវឌ្ឍនិងនវានុវត្តន៍នានា
- ការកសាងសមត្ថភាពវិស័យឯកជនក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍផលិតផលទេសចរណ៍ កសិកម្ម វត្ថុប្រមាញ់ និងនេសាទ ចំណេះដឹងជាប្រពៃណី ធនធានពន្ធុ និងវិញ្ញត្តិវប្បធម៌ និងផលិតផលបច្ចេកវិទ្យា
- ការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការប្រើប្រាស់កម្មសិទ្ធិបញ្ញា ក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ការអភិវឌ្ឍសមត្ថភាពអ្នកនិពន្ធស្នាដៃអក្សរសាស្ត្រ តូរ្យតន្ត្រី ស្នាដៃចម្លាក់ វិចិត្រករ ផលិតករភាពយន្ត សិល្បៈសូនរូប ស្ថាបត្យករ ការរចនាប្លង់សិល្បៈ និងភាគីពាក់ព័ន្ធ
- ការកសាងនិងអភិវឌ្ឍសមត្ថភាពសមាគមតក្កករនិងអ្នកច្នៃប្រឌិតនៃព្រះរាជាណាចក្រកម្ពុជា
- ការរៀបចំកម្មវិធីសិក្សាសម្រាប់គ្រឹះស្ថានអប់រំនិងកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញាទាក់ទងនឹងគោលគំនិតបច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់សាកលវិទ្យាល័យ វិទ្យាស្ថានជំនាញបច្ចេកវិទ្យា វិទ្យាសាស្ត្រ សុខាភិបាល វិស្វកម្ម ពាណិជ្ជកម្មនិងសេដ្ឋកិច្ច និងរៀបចំឯកសារបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញាសម្រាប់ការផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងសាធារណៈ
- ការរៀបចំវេទិកាគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ទិវាកម្មសិទ្ធិបញ្ញាពិភពលោក និងវេទិកាជជែកពិភាក្សាអំពីកម្មសិទ្ធិបញ្ញាសម្រាប់អ្នកសារព័ត៌មាននិងសាធារណជន និងព្រឹត្តិការណ៍កម្មសិទ្ធិបញ្ញាផ្សេងៗ
- ការបង្កើតបណ្តាញផ្តល់ព័ត៌មានសម្រាប់គាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងសាធារណជន តាមរយៈបញ្ជរផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា ចំណេះដឹងសាធារណៈ និងឯកសារបណ្តុះបណ្តាល។

**យុទ្ធសាស្ត្រទី៥ : បង្កើតយន្តការពង្រឹងការអនុវត្តច្បាប់ ការដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាព ប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានកម្មសិទ្ធិបញ្ញា ដើម្បីកសាងសង្គមមួយឱ្យមានជំនឿទុកចិត្ត និងការគោរពកម្មសិទ្ធិបញ្ញាពីសាធារណជន តាមរយៈ៖**

- ការបង្កើតយន្តការដោះស្រាយវិវាទកម្មសិទ្ធិបញ្ញា តាមរយៈតុលាការពាណិជ្ជកម្ម និងលើកកម្ពស់យន្តការដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាក្រៅប្រព័ន្ធតុលាការ សម្រាប់គាំទ្រវិស័យពាណិជ្ជកម្មនិងឧស្សាហកម្ម
- ការពង្រឹងការអនុវត្តច្បាប់ ដើម្បីផ្តល់កិច្ចការពារកម្មសិទ្ធិបញ្ញាឱ្យកាន់តែប្រសើរ ដោយលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងអង្គភាពអនុវត្តច្បាប់ ផ្លាស់ប្តូរព័ត៌មាន និងបទពិសោធនៃការអនុវត្ត ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានិងបច្ចេកវិទ្យា ដើម្បីប្រយុទ្ធប្រឆាំងនឹងទំនិញក្លែងក្លាយនៅតាមអនឡាញ និងតភ្ជាប់ប្រព័ន្ធស្រាវជ្រាវទិន្នន័យកម្មសិទ្ធិបញ្ញារវាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ
- ការធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីប្រយុទ្ធប្រឆាំងនឹងទំនិញក្លែងក្លាយនៅលើទីផ្សារ និងបទល្មើសកម្មសិទ្ធិបញ្ញាដទៃទៀត ដើម្បីបង្កើនជំនឿទុកចិត្តរបស់អតិថិជននិងអ្នកទេសចរ

- ការពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីការពារម្ចាស់សិទ្ធិនិងបង្កើនជំនឿទុកចិត្តដល់អ្នកប្រើប្រាស់ផលិតផលចំណេះដឹងជាប្រពៃណី និងផលិតផលវប្បធម៌
- ការរៀបចំយុទ្ធសាស្ត្រនិងប្រព័ន្ធត្រួតពិនិត្យ ដើម្បីលើកកម្ពស់កិច្ចការពារចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ និងពង្រឹងការអនុវត្តច្បាប់ចំពោះការប្រើប្រាស់មិនត្រឹមត្រូវនៃធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា ដោយប្រទេសដទៃទៀត
- ការចាត់វិធានការការពារការក្លែងបន្លំម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្មរបស់ព្រះរាជាណាចក្រកម្ពុជា នៅបរទេស
- ការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងជំរុញឱ្យអង្គភាពទូរផ្សាយអនុវត្តនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងកម្មសិទ្ធិបញ្ញា
- ការពង្រឹងសមត្ថភាពមន្ត្រីក្រសួងសុខាភិបាល មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ និងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីលុបបំបាត់ផលិតផលឱសថក្លែងក្លាយ ដែលប៉ះពាល់ដល់សុខភាពសាធារណៈ
- ការកសាងសមត្ថភាពមន្ត្រីទទួលបន្ទុកកម្មសិទ្ធិបញ្ញា ភ្នាក់ងារទេសចរណ៍ និងភាគីពាក់ព័ន្ធ និងជំរុញការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីបង្កើនទំនុកចិត្តរបស់អ្នកប្រើប្រាស់ទៅលើគុណភាព ភាពជឿជាក់ ភាពត្រឹមត្រូវ និងយថាភាពនៃសេវា និងផលិតផលទេសចរណ៍។

**យុទ្ធសាស្ត្រទី៦ : ធ្វើពាណិជ្ជូបនីយកម្មទ្រព្យកម្មសិទ្ធិបញ្ញា ដើម្បីទទួលបានតម្លៃសេដ្ឋកិច្ចសម្រាប់ម្ចាស់កម្មសិទ្ធិបញ្ញា តាមរយៈ៖**

- ការជំរុញការផលិតឱសថ ក្រោមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម ច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ដែលអនុលោមតាមភាពបត់បែន នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា
- ការជំរុញការបង្កើតផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញានិងអភិវឌ្ឍសមត្ថភាពបុគ្គលិកជំនាញ ដើម្បីលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ នៅតាមបណ្តាក្រុមហ៊ុនគោលដៅ
- ការជំរុញកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យនិងវិស័យឯកជន ដើម្បីស្រាវជ្រាវនិងអភិវឌ្ឍរួមគ្នា និងកសាងសមត្ថភាពក្នុងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា
- ការផ្តល់ការគាំទ្រហិរញ្ញប្បទាននិងលើកទឹកចិត្តដល់តក្កករនិងអ្នកច្នៃប្រឌិតដែលជាក្រុមគោលដៅ ក្នុងការបង្កើតទ្រព្យកម្មសិទ្ធិបញ្ញា សម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍ និងធ្វើពាណិជ្ជូបនីយកម្មផលិតផលកម្មសិទ្ធិបញ្ញា
- ការផ្តល់ការគាំទ្រដល់សហគ្រិន វិស្វករ អ្នកស្រាវជ្រាវ តក្កករ និងភាគីពាក់ព័ន្ធ ក្នុងការកំណត់តក្កកម្មថ្មីសម្រាប់ធ្វើការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម
- ការរៀបចំ គ្រប់គ្រង និងជំរុញការអនុវត្តកិច្ចសន្យាផ្តល់អាជ្ញាបណ្ណកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាព
- ការបង្កើតកម្មវិធីកម្មសិទ្ធិបញ្ញាក្នុងការភ្ញាស់គំនិតអាជីវកម្ម បង្កើនប្រវាក់តម្លៃ ប្រវាក់ផ្គត់ផ្គង់ កាត់បន្ថយថ្លៃដើម និងចំណាយប្រតិបត្តិការ បង្កើនផលិតភាព និងកាត់បន្ថយការចំណាយរបស់អ្នកប្រើប្រាស់ស្នាដៃ និងបន្ទុករបស់ម្ចាស់សិទ្ធិ ដើម្បីគាំទ្រនិងអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាពិសេសក្រុមហ៊ុនដែលទើបបង្កើតថ្មី តក្កករ អ្នកច្នៃប្រឌិត និងម្ចាស់ស្នាដៃសិទ្ធិអ្នកនិពន្ធ
- ការជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍផលិតផលវប្បធម៌ និងប្រែក្លាយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនិងម៉ាកសមូហភាព ឱ្យទៅជាគោលដៅទេសចរណ៍
- ការជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញានិងផ្តល់បច្ចេកទេសសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍពូជថ្មីនៃដំណាំ និងផលិតផលកែច្នៃពីជីវៈចម្រុះនិងជំរុញការធ្វើពាណិជ្ជកម្មពូជដំណាំនិងពូជថ្មីនៃដំណាំរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៥- ផែនការសកម្មភាព

ដោយផ្អែកតាមយុទ្ធសាស្ត្រនិងការកំណត់បញ្ហាខាងលើ គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាបានកំណត់ផែនការសកម្មភាពដូចខាងក្រោម ដើម្បីដោះស្រាយបញ្ហានានានិងសម្រេចបានគោលដៅ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញានៅកម្ពុជាឱ្យក្លាយទៅជាកម្លាំងចលករក្នុងការអភិវឌ្ឍវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ ទេសចរណ៍ កសិកម្ម សុខាភិបាល វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងអប់រំ ឈានឆ្ពោះសម្រេចបានចក្ខុវិស័យនៃគោលនយោបាយនេះ។

### ៥.១- ក្របខ័ណ្ឌគតិយុត្តទាក់ទងនឹងកម្មសិទ្ធិបញ្ញា

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះឱ្យមានប្រសិទ្ធភាព ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងកម្មសិទ្ធិបញ្ញាត្រូវអនុលោមតាមភាពបត់បែននៃកិច្ចព្រមព្រៀងអន្តរជាតិ និងផ្តោតលើការផ្តល់ផលប្រយោជន៍សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ការច្នៃប្រឌិតក្នុងវិស័យវប្បធម៌ ការការពារ និងលើកកម្ពស់ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ ធ្វើឱ្យប្រសើរឡើងនូវវិស័យសុខាភិបាលបន្ថែមទៀត លើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ និងគាំទ្រដល់សេវាកម្មទេសចរណ៍ ពង្រឹងការអនុវត្តច្បាប់ដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម និងបង្កើនជំនឿទុកចិត្តពីសាធារណជនទូទៅ។

### ៥.២- ពង្រឹងនិងលើកកម្ពស់សមត្ថភាពមន្ត្រីនិងអង្គភាពក្នុងការអនុវត្តប្រព័ន្ធកម្មសិទ្ធិបញ្ញា

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះឱ្យមានប្រសិទ្ធភាព ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវពង្រឹងប្រព័ន្ធរដ្ឋបាលនិងការគ្រប់គ្រង លើកកម្ពស់ការការពារកម្មសិទ្ធិបញ្ញា រៀបចំស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីកម្មសិទ្ធិបញ្ញា បង្កើតប្រព័ន្ធសម្រាប់គ្រប់គ្រង និងចុះបញ្ជីពូជដំណាំ ប្រព័ន្ធគ្រប់គ្រងនិងការពារធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ បង្កើតប្រព័ន្ធស្រាវជ្រាវនិងផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា សិក្សានិងរៀបចំចុះបញ្ជីផលិតផលកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកំណត់ផលិតផលវប្បធម៌ដូចជាចម្លាក់ សិល្បៈសូនរូប សិល្បៈភាពយន្ត និងការរចនាប្លង់សិល្បៈនានា ដែលមានសក្តានុពលជាម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឬម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម។

កសាងសមត្ថភាពមន្ត្រីអង្គភាពកម្មសិទ្ធិបញ្ញា និងទទួលបន្ទុកសម្រាប់ផ្តល់ជំនួយបច្ចេកទេសដល់វិស័យឯកជនក្នុងការធ្វើឱ្យប្រសើរឡើងដល់វិស័យកសិកម្ម វិស័យវប្បធម៌ កសាងនិងអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាជាតិស្រាវជ្រាវវិទ្យាសាស្ត្រសុខាភិបាលនិងឱសថ សមាគមតក្កករ និងអ្នកច្នៃប្រឌិត និងជំរុញការប្រើប្រាស់ប្រព័ន្ធទិន្នន័យកម្មសិទ្ធិបញ្ញាដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងសុខាភិបាល និងរៀបចំការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់។

### ៥.៣- ផ្សព្វផ្សាយនិងលើកកម្ពស់ចំណេះដឹងសាធារណៈ អំពីការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះឱ្យមានប្រសិទ្ធភាព ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវ៖

- ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់ផលិតផលកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអភិវឌ្ឍផលិតផលចំណេះដឹងជាប្រពៃណី និងផលិតផលវប្បធម៌ និងកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យក្លាយទៅជាគោលដៅទេសចរណ៍
- លើកកម្ពស់សមត្ថភាពសាកលវិទ្យាល័យនិងវិស័យឯកជន ក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍផលិតផលបច្ចេកវិទ្យា និងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា
- បង្កើតបណ្តាញផ្តល់ព័ត៌មានសម្រាប់គាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម បង្កើតកម្មវិធីពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាដើម្បីអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម។

## ៦- ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ប្រព័ន្ធកម្មសិទ្ធិបញ្ញាដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម វប្បធម៌ សុខាភិបាល ទេសចរណ៍ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយត្រូវការចាំបាច់នូវរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងអភិបាលកិច្ចក្នុងការដឹកនាំប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងយន្តការអនុវត្តប្រកបដោយភាពប្រទាក់ក្រឡា និងកិច្ចសហប្រតិបត្តិការស៊ីជម្រៅ គឺជាកត្តាមិនអាចខ្វះបាន។

ដើម្បីធានាបានការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ប្រកបដោយ វឌ្ឍនភាព ប្រសិទ្ធភាព និងសង្គតិភាព ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់ទី១ របស់រាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា មានសមត្ថកិច្ច ដឹកនាំ ត្រួតពិនិត្យ វាយតម្លៃ និងលើកទឹកចិត្ត នៃការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ឆ្នាំ២០២៣-២០២៨ ដោយមានការជំរុញពីទីស្តីការគណៈរដ្ឋមន្ត្រី។

ប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបែងចែកជា២ប្រភេទ។ ១- ការត្រួតពិនិត្យ សំដៅលើការពិនិត្យសកម្មភាពនិងលទ្ធផលតាមការិយបរិច្ឆេទនីមួយៗ។ ២- ការវាយតម្លៃ សំដៅលើការប្រមូលព័ត៌មាន ដើម្បីវាស់វែងពីប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពលើលទ្ធផលចុងក្រោយនៃការអនុវត្តសកម្មភាព និងយុទ្ធសាស្ត្រដើម្បីសម្រេចគោលនយោបាយជាតិនេះ។

## ៧- សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាឆ្នាំ២០២៣-២០២៨ ត្រូវបានរៀបចំឡើងក្នុងបរិបទ ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកំពុងបង្កើនភាពធន់សេដ្ឋកិច្ច អភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម កសាងមូលធនមនុស្ស ដើម្បីសម្រេចបាននូវចក្ខុវិស័យប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ព្រមទាំងឆ្លើយតបទៅនឹងការវិវត្តឥតឈប់ឈររបស់ពិភពលោក។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ដោយផ្តោតទៅលើការអភិវឌ្ឍវិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខាភិបាល វប្បធម៌ ទេសចរណ៍ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបានកំណត់សកម្មភាពអាទិភាពដើម្បីដោះស្រាយបញ្ហាប្រឈមនានាទាក់ទងទៅនឹង (១)ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តឱ្យមានសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ (២)ពង្រឹងនិងលើកកម្ពស់សមត្ថភាពមន្ត្រីនិងអង្គភាពក្នុងការអនុវត្តប្រព័ន្ធកម្មសិទ្ធិបញ្ញានិងរក្សាគុណភាពរវាងម្ចាស់សិទ្ធិនិងផលប្រយោជន៍សាធារណៈ (៣)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងមូលធនមនុស្ស ដើម្បីផ្តល់ការគាំទ្រដល់វិស័យឯកជន ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍនិងពង្រឹងការអនុវត្តច្បាប់ ដើម្បីកសាងសង្គមមួយដែលមានការគោរពកម្មសិទ្ធិបញ្ញា (៤)ការលើកកម្ពស់ការអប់រំនិងចំណេះដឹងសាធារណៈ ដើម្បីជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍគំនិតច្នៃប្រឌិតបង្កើតផលិតផលបច្ចេកវិទ្យា និងធ្វើពាណិជ្ជូបនីយកម្មនៃទ្រព្យកម្មសិទ្ធិបញ្ញាដើម្បីអភិវឌ្ឍវិស័យឯកជនដែលជាកម្លាំងជំរុញសេដ្ឋកិច្ច។ គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ នឹងផ្តោតទៅលើការអភិវឌ្ឍ វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម សុខាភិបាល វប្បធម៌ ទេសចរណ៍ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

លទ្ធផលដែលទទួលបានពីការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ នឹងចូលរួមចំណែកការប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីលើកកម្ពស់ពូជថ្មីនៃដំណាំ ផលិតផលកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការការពារធនធានពន្ធុ ចំណេះដឹងជាប្រពៃណី វិញ្ញត្តិវប្បធម៌ និងវប្បធម៌ច្នៃប្រឌិត ដែលជាសមាសធាតុមួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ហើយគោលនយោបាយនេះនឹងជំរុញការកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ឱ្យក្លាយជាគោលដៅទេសចរណ៍ ការលើកកម្ពស់ចំណេះដឹងសាធារណៈអំពីកម្មសិទ្ធិបញ្ញាក្នុងចំណោមសាធារណជនទូទៅ ជំរុញនិងអភិវឌ្ឍ

ផលិតផលបច្ចេកវិទ្យា និងបំផុសគំនិតច្នៃប្រឌិតរបស់ព្រះរាជាណាចក្រកម្ពុជា ការធ្វើពាណិជ្ជូបនីយកម្មនៃទ្រព្យកម្មសិទ្ធិបញ្ញា ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ពង្រឹងការអនុវត្តច្បាប់ ដើម្បីបង្កើនជំនឿទុកចិត្តដល់អ្នកប្រើប្រាស់ និងអ្នកទេសចរ និងកសាងសង្គមមួយដែលមានការគោរពកម្មសិទ្ធិបញ្ញាក្នុងចំណោមសាធារណជនទូទៅ ដើម្បីបង្កើនសេដ្ឋកិច្ច និងជំនឿទុកចិត្តពីអ្នកវិនិយោគ ហើយការអភិវឌ្ឍប្រព័ន្ធកម្មសិទ្ធិបញ្ញាគឺជាកម្លាំងចលករមួយដែលមិនអាចខ្វះបានក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១របស់រាជរដ្ឋាភិបាល និងចូលរួមកសាងសង្គម សេដ្ឋកិច្ចឌីជីថល និងស្របតាមបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ដែលចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនិងសេដ្ឋកិច្ច។ ជារួម កម្មសិទ្ធិបញ្ញាផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋគ្រប់រូបនិងគ្រប់ផ្នែកទាំងអស់នៃសង្គម។

គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញានេះ ត្រូវបានចាត់ទុកជា "ឯកសាររស់" ដែលអាចនឹងត្រូវបានកែសម្រួលបន្ថែមជាយថាហេតុ ដើម្បីធានាបាននូវសង្គតិភាព និងភាពសមស្របទៅតាមភាពរីកចម្រើន និងការវិវត្តជាក់ស្តែងរបស់វិស័យកម្មសិទ្ធិបញ្ញា ក៏ដូចជាការប្រែប្រួលនៃស្ថានការណ៍សេដ្ឋកិច្ច និងសង្គមជាក់ស្តែងនៅក្នុងប្រទេស តំបន់ និងសកលលោកផងដែរ។

## ៨- សន្ទានុក្រម

| | | |
|---|---|---|
| ការកសាងកេរ្តិ៍ឈ្មោះម៉ាក | Branding | សំដៅដល់ការលើកកម្ពស់គុណតម្លៃរបស់ផលិតផល តាមរយៈការបង្កើតផលិតផលបច្ចេកវិទ្យា ការការពារម៉ាក រួមបញ្ចូលការរចនាឡូហ្គូ និងសម្បកវេចខ្ចប់ រូបរាងផលិតផល ប្រកបដោយសោភណភាព ការការពារស្នាដៃសិទ្ធិអ្នកនិពន្ធ ដើម្បីបង្កើនទ្រព្យអរូបីរបស់ក្រុមហ៊ុន។ |
| ការសម្តែង | Performance | សំដៅដល់ការបញ្ចេញស្នាដៃលើឆាក ដូចជារាំ ប្រគំតន្ត្រី ច្រៀង ឬបង្ហាញតាមមធ្យោបាយនិងវិធីផ្សេងៗនូវស្នាដៃសិល្បៈប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ ការអប់រំ ឬវិទ្យាសាស្ត្រ។ |
| ការសម្ងាត់ពាណិជ្ជកម្ម | Trade Secret | សំដៅដល់ព័ត៌មានដែល៖<br>ក-សម្ងាត់ក្នុងន័យថា ការសម្ងាត់ពាណិជ្ជកម្មនោះមិនត្រូវទម្លាយចេញឱ្យដឹងជាទូទៅទាំងមូល ឬជារូបសណ្ឋានជាក់លាក់ និងជាបង្គុំសមាសភាគរបស់វា ឬអាចបើកមើលយ៉ាងងាយស្រួលក្នុងចំណោមបុគ្គលដែលស្ថិតនៅក្នុងមជ្ឈដ្ឋាននានា ដែលទាក់ទងជាធម្មតាទៅនឹងប្រភេទព័ត៌មានទាំងនេះ<br>ខ- មានតម្លៃពាណិជ្ជកម្មជាក់ស្តែង ឬមានសក្តានុពល ពីព្រោះវាជាការសម្ងាត់ និង<br>គ- ស្ថិតក្រោមវិធានការសមស្របតាមកាលៈទេសៈនានា ដោយបុគ្គលដែលមានសិទ្ធិស្របច្បាប់ក្នុងការគ្រប់គ្រងព័ត៌មាននោះជាសម្ងាត់។ |
| កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា | Agreement on Trade-Related Aspects of Intellectual Property Rights(TRIPS) | សំដៅដល់កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាក្នុងឧបសម្ព័ន្ធ១(គ) នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ |
| កិច្ចសន្យាហ្វ្រេនឆាយ | Franchising Contract | សំដៅដល់កិច្ចសន្យាដែលធ្វើឡើងរវាងពាណិជ្ជករពីរឬច្រើនរូប ដោយអ្នកទទួលហ្វ្រេនឆាយ ត្រូវបង់កម្រៃទៅឱ្យម្ចាស់ហ្វ្រេនឆាយ ជាថ្នូរនឹងសិទ្ធិធ្វើអាជីវកម្ម។ |
| កិច្ចសន្យាអាជ្ញាបណ្ណ | Licensing Contract | សំដៅដល់កិច្ចសន្យាមួយដែលម្ចាស់អាជ្ញាបណ្ណជាពាណិជ្ជករ ឬមិនមែនជាពាណិជ្ជករ ផ្តល់សិទ្ធិប្រើប្រាស់កម្មសិទ្ធិបញ្ញាទៅឱ្យអ្នកទទួលអាជ្ញាបណ្ណដែលជាពាណិជ្ជករ ដើម្បីផលិតនិង/ឬលក់ទំនិញ ជាកម្មវត្ថុនៃអាជ្ញាបណ្ណនោះ។ |
| កម្មសិទ្ធិបញ្ញា | Intellectual Property | សំដៅដល់របកគំហើញនៃគំនិត រួមមានការបង្កើតផ្នែកអក្សរសាស្ត្រ និងសិល្បៈ និមិត្តសញ្ញា ឈ្មោះរូបភាព និងគំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម ដែលប្រើប្រាស់ក្នុងពាណិជ្ជកម្ម។ |

| | | |
|---|---|---|
| គំនូរឧស្សាហកម្ម | Industrial Design | សំដៅដល់ការផ្គុំនៃបន្ទាត់ ឬពណ៌ ឬទម្រង់បីវិមាត្រ ឬសម្ភារៈណាមួយ ទោះបីជាមានឬពុំមានការផ្គុំរួមជាមួយបន្ទាត់ ឬពណ៌ក៏ដោយ ឱ្យតែការផ្គុំទម្រង់ឬសម្ភារៈទាំងនោះរំលេចឡើងជារូបរាងពិសេសរបស់ផលិតផលឧស្សាហកម្មឬសិប្បកម្ម និងដែលអាចធ្វើជាគំរូផលិតផលឧស្សាហកម្មឬសិប្បកម្ម និងអាចសម្គាល់បានដោយចក្ខុ។ |
| ចំណេះដឹងជាប្រពៃណី | Traditional Knowledge | សំដៅដល់ចំណេះដឹង ចំណេះធ្វើ ជំនាញ និងទម្លាប់អនុវត្ត រួមទាំងរូបមន្តឬក្បួនដែលពាក់ព័ន្ធនឹងធនធានពន្ធុ ហើយត្រូវបានអភិវឌ្ឍនិងថែរក្សាដោយបុគ្គលម្នាក់ៗនៅក្នុងសហគមន៍មួយឬសហគមន៍ច្រើន ដែលចំណេះដឹងជាប្រពៃណីទាំងនេះ ជាញឹកញាប់ គឺជាផ្នែកមួយនៃអត្តសញ្ញាណវប្បធម៌ ទំនៀមទម្លាប់ ឬសក្ការបូជារបស់សហគមន៍ទាំងនោះ។ |
| ឈ្មោះដែន | Domain Name | សំដៅដល់នាមឬអាសយដ្ឋានសម្រាប់សម្គាល់ស្ថាប័នក្នុងបណ្តាញអ៊ីនធឺណិត។ |
| តក្កកម្ម | Invention | សំដៅដល់គំនិតរបស់តក្កករ ដែលអាចយកទៅអនុវត្តបាននៅក្នុងដំណោះស្រាយបញ្ហាជាក់លាក់ណាមួយក្នុងវិស័យបច្ចេកវិទ្យា។ |
| ធនធានពន្ធុ | Genetic Resource | សំដៅដល់សមាសភាគរុក្ខជាតិ សត្វ មីក្រុប ឬសមាសភាគប្រភពដើមផ្សេងទៀត ដែលមានផ្ទុកមុខងារនៃឯកតាតំណពូជ ដែលមានគុណតម្លៃ ឬមានសក្តានុពលជាក់ស្តែង ក្នុងនោះរួមទាំងសមាសភាពគីមីជីវៈនៃធនធានពន្ធុ ព័ត៌មានពន្ធុ និងនិស្សន្ទវត្ថុ។ |
| ប្រព័ន្ធទិន្នន័យស្រាវជ្រាវសម្រាប់ការអភិវឌ្ឍនិងនវានុវត្តន៍ | Access to Research for Development and Innovation (ARDI) | សំដៅដល់ការចូលទៅកាន់ប្រព័ន្ធទិន្នន័យស្រាវជ្រាវសម្រាប់ការអភិវឌ្ឍនិងនវានុវត្តន៍របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលអនុញ្ញាតឱ្យប្រើប្រាស់ទស្សនាវដ្ដីបច្ចេកទេសនិងវិទ្យាសាស្ត្រ តាមប្រព័ន្ធអនឡាញ។ |
| បច្ចេកវិទ្យាបៃតង | Green Technology | សំដៅដល់ប្រព័ន្ធបច្ចេកទេសនិងបច្ចេកវិទ្យាដែលមិនបង្កឱ្យមានការខូចខាតដល់បរិស្ថាន ដូចជាបច្ចេកវិទ្យាកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បច្ចេកវិទ្យាកាត់បន្ថយការសាយភាយសារធាតុបំពុលបរិស្ថាន បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព បច្ចេកវិទ្យាអភិវឌ្ឍស្អាត និងបច្ចេកវិទ្យាសម្រាប់ការកែច្នៃនិងការប្រើប្រាស់ឡើងវិញនូវធនធានដែលបានប្រើរួច។ |

| | | |
|---|---|---|
| ប្រព័ន្ធម៉ាឌ្រីដ | Madrid System | សំដៅដល់ការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ ក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។ ម៉ាកអន្តរជាតិ អាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមរយៈអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីជ្រើសរើសការចុះបញ្ជីម៉ាកតាមបណ្ដាប្រទេសជាគោលដៅ។ ម៉ាកកម្ពុជា អាចដាក់ពាក្យតាមរយៈនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្នុងនាមការិយាល័យដើម ដើម្បីទទួលបានការចុះបញ្ជីម៉ាកនៅបណ្ដាប្រទេសជាគោលដៅ។ |
| ប្រកាសនីយបត្រតក្កកម្ម | Patent | សំដៅដល់វិញ្ញាបនបត្រដែលបានផ្ដល់ដើម្បីការពារតក្កកម្ម។ |
| ផលបត្រកម្មសិទ្ធិបញ្ញា | IP Portfolio | សំដៅដល់ការប្រមូលផ្ដុំទ្រព្យកម្មសិទ្ធិបញ្ញា ដែលបង្កើតបានជាផលិតផលរបស់ក្រុមហ៊ុន។ |
| ពាណិជ្ជូបនីយកម្មកម្មសិទ្ធិបញ្ញា | IP Commercialization | សំដៅដល់ការធ្វើពាណិជ្ជកម្មទ្រព្យកម្មសិទ្ធិបញ្ញា ដែលបានស្រាវជ្រាវ និងអភិវឌ្ឍ រួមទាំងម៉ាក ប្រកាសនីយបត្រតក្កកម្ម គំនូរឧស្សាហកម្ម និងសិទ្ធិអ្នកនិពន្ធ។ |
| ពិធីសារទីក្រុងម៉ាឌ្រីដ | Madrid Protocol | សំដៅដល់ពិធីសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្ដីពីការចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ ដែលត្រូវបានអនុម័តនៅទីក្រុងម៉ាឌ្រីដនៃប្រទេសអេស្ប៉ាញ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨៩ ដែលប្រទេសកម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥។ |
| ពិធីសារណាហ្គូយ៉ា | Nagoya Protocol | សំដៅដល់ពិធីសារណាហ្គូយ៉ា ស្ដីពីសិទ្ធិទទួលផលពីធនធានពន្ធុ និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ ដោយស្មើភាពនិងសមធម៌ នៃអនុសញ្ញាសហប្រជាជាតិស្ដីពីជីវៈចម្រុះ។ |
| ពូជថ្មីនៃដំណាំ | New Varieties of Plants | សំដៅដល់ពូជដំណាំដែលមានភាពថ្មី ភាពខុសប្លែក ឯកសណ្ឋានភាព និងស្ថិរភាព។ |
| ម៉ាក | Mark | សំដៅដល់សញ្ញាដែលមើលឃើញ ដែលអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញឬសេវានៃសហគ្រាសនីមួយៗ។ |

| | | |
|---|---|---|
| ម៉ាកវិញ្ញាតកម្ម | Certification Mark | សំដៅដល់ឈ្មោះ និមិត្តសញ្ញា ឬរូបសញ្ញា ឬបង្គុំនៃសញ្ញាទាំងនោះ ដែលបង្ហាញថា ទំនិញឬសេវានោះទាក់ទងនឹងម៉ាកវិញ្ញាតកម្មដែលបានប្រើប្រាស់ និងមានការបញ្ជាក់ពីម្ចាស់ម៉ាកបានចុះបញ្ជីរួចអំពីវត្ថុធាតុដើម ប្រភពវិធីសាស្ត្រ របៀបផលិតទំនិញ ឬផ្តល់សេវា គុណភាព ភាពច្បាស់លាស់ ឬចរិតលក្ខណៈផ្សេងទៀត។ |
| ម៉ាកសមូហភាព | Collective Mark | សំដៅដល់សញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសម្គាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី។ |
| ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ | Geographical Indication (GI) | សំដៅដល់ឈ្មោះ សញ្ញាសម្គាល់ និង/ឬ រូបភាពផ្សេងៗទៀតដែលមានលក្ខណៈញែកដាច់ ដែលជាឈ្មោះឬតំណាងឱ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយហើយឈ្មោះសញ្ញាសម្គាល់ និង/ឬរូបភាពនោះ សម្រាប់កំណត់អត្តសញ្ញាណទំនិញមានប្រភពក្នុងភូមិសាស្ត្រនោះ ដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ។ |
| មជ្ឈមណ្ឌលគាំពារព័ត៌មានបច្ចេកវិទ្យា | Technology and Innovation Support Center (TISC) | សំដៅដល់មជ្ឈមណ្ឌលមួយ ផ្តល់ឱ្យអ្នកច្នៃប្រឌិតក្នុងប្រទេសកំពុងអភិវឌ្ឍ នូវលទ្ធភាពទទួលបានព័ត៌មានបច្ចេកវិទ្យាដែលមានគុណភាពខ្ពស់ និងសេវាកម្មពាក់ព័ន្ធក្នុងមូលដ្ឋានផ្ទាល់ ហើយជួយពួកគេអាចទាញយកប្រយោជន៍ ពីភាពច្នៃប្រឌិតមានសក្តានុពល ដោយបង្កើត ការពារ និងគ្រប់គ្រងសិទ្ធិកម្មសិទ្ធិបញ្ញារបស់ពួកគេ។ |
| វិស្វកម្មបំបែកនិងផ្គុំ | Reverse Engineering | សំដៅដល់ការទទួលបាននូវសមត្ថភាពបច្ចេកវិទ្យា តាមរយៈការធ្វើត្រាប់តាមនៃគំរូផលិតផលមួយ ជាទូទៅសំដៅទៅលើការយកផ្នែកណាមួយនៃផលិតផល ដើម្បីស្វែងរកថាតើវាប្រតិបត្តិការយ៉ាងដូចម្តេច។ |
| វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | Utility Model Certificate | សំដៅដល់វិញ្ញាបនបត្រ ដែលបានផ្តល់ដើម្បីការពារម៉ូដែលមានអត្ថប្រយោជន៍។ ម៉ូដែលមានអត្ថប្រយោជន៍ គឺជាតក្កកម្មណាមួយដែលថ្មី និងអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និងដែលអាចជាផលិតផល ឬដំណើរការផលិតកម្ម ឬដែលអាចទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។ |
| វិញ្ញត្តិវប្បធម៌ | Cultural Expression | សំដៅដល់ការបង្ហាញឬការសម្តែង ដែលកើតចេញគំនិតច្នៃប្រឌិតរបស់បុគ្គលម្នាក់ របស់ក្រុមមនុស្សនិងសង្គម ហើយមានបង្កប់នូវខ្លឹមសារវប្បធម៌។ |

| | | |
|---|---|---|
| សិទ្ធិអ្នកនិពន្ធ | Copyright | សំដៅដល់សិទ្ធិដែលផ្តល់ឱ្យដោយច្បាប់ដល់អ្នកនិពន្ធ សិល្បករ ឬអ្នកបង្កើតស្នាដៃផ្សេងៗទៀត ក្នុងការប្រើប្រាស់និងការពារស្នាដៃរបស់ខ្លួន។ |
| សន្ធិសញ្ញាទីក្រុងម៉ារ៉ាកេស | Marrakesh Treaty | សំដៅដល់សន្ធិសញ្ញាទីក្រុងម៉ារ៉ាកេសស្តីពីការសម្រួលដល់ការទទួលបាននូវស្នាដៃ ដែលបានបោះពុម្ពសម្រាប់ជនពិការភ្នែក បាត់បង់សមត្ថភាពចក្ខុទស្សន៍ ឬការបោះពុម្ពដទៃទៀតសម្រាប់ជនពិការ។ |
| សន្ធិសញ្ញាទីក្រុងប៉េកាំង | Beijing Treaty | សំដៅដល់សន្ធិសញ្ញាទីក្រុងប៉េកាំង ស្តីពីការសម្តែងសោតទស្សន៍ ដែលបានអនុម័តកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១២។ |
| សៀគ្វីបង្រួម | Intergrated Circuit | សំដៅដល់ ផលិតផលមួយក្នុងទម្រង់ជាផលិតផលសម្រេច ឬពាក់កណ្តាលសម្រេចដែលក្នុងចំណោមធាតុជាច្រើនដែលបង្កើតផលិតផលនោះ យ៉ាងហោចណាស់មានធាតុមួយជាធាតុសកម្ម ហើយបានបង្កើតឡើងនូវការភ្ជាប់គ្នាទៅវិញទៅមកនៃធាតុមួយចំនួនឬទាំងអស់ ដោយរួមបញ្ចូលគ្នានៅក្នុងឬនៅលើវត្ថុមួយបន្ទះ ហើយមានគោលបំណងដំណើរការមុខងារផ្នែកអេឡិចត្រូនិក។ |
| សង្គមឌីជីថល | Digital Society | សំដៅដល់សង្គមដែលប្រកបដោយគុណភាពនិងសមធម៌ ដោយផ្តោតសំខាន់លើប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ |
| សិទ្ធិប្រហាក់ប្រហែល | Related Rights | សំដៅដល់សិទ្ធិអ្នកសម្តែង សិទ្ធិរបស់ផលិតករហ្វូណូក្រាម សិទ្ធិផលិតករវីដេអូ និងសិទ្ធិនៃអង្គភាពទូរផ្សាយ។ |
| សន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក | WIPO Copyright Treaty (WCT) | សំដៅដល់សន្ធិសញ្ញាដែលបង្កើតឡើងក្នុងឆ្នាំ១៩៩៦ ក្រោមអនុសញ្ញាទីក្រុងប៊ែន ស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈក្នុងទម្រង់ឌីជីថល ដូចជាកម្មវិធីកុំព្យូទ័រនិងមូលទិន្នន័យ។ |
| សហភាពអន្តរជាតិការពារពូជថ្មីនៃដំណាំ | Union for the Protection of New Varieties of Plants ( UPOV ) | សំដៅដល់អនុសញ្ញាអន្តរជាតិសម្រាប់កិច្ចការពារពូជថ្មីនៃដំណាំដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៦១។ |

| | | |
|---|---|---|
| សន្ធិសញ្ញាស្ដីពីការសម្ដែងនិងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក | WIPO Performances and Phonograms Treaty (WPPT) | សំដៅដល់សន្ធិសញ្ញាដែលបង្កើតឡើងក្នុងឆ្នាំ១៩៩៦ ទាក់ទងនឹងកិច្ចការពារសិទ្ធិអ្នកសម្ដែងនិងផលិតករហ្វូណូក្រាម ជាទម្រង់ឌីជីថល។ |
| សន្ធិសញ្ញាសិង្ហបុរីស្ដីពីច្បាប់ម៉ាក | Singapore Treaty on the Law of Trademarks (STLT) | សំដៅដល់សន្ធិសញ្ញាដែលរៀបចំឡើងក្នុងឆ្នាំ២០០៦ និងចូលជាធរមានក្នុងឆ្នាំ២០០៩ សម្រាប់ផ្ដល់កិច្ចសម្រួលនិងសុខដុមនីយកម្មនៃនីតិវិធីរដ្ឋបាល របស់ភាគីហត្ថលេខីសម្រាប់ការដាក់ពាក្យក្នុងការចុះបញ្ជីម៉ាក ក្រោមក្របខ័ណ្ឌអន្តរជាតិ។ |
| ហ្វូណូក្រាម | Phonogram | សំដៅដល់វត្ថុដែលបានថតបញ្ចូលសំឡេងនៃការសម្ដែង ឬសំឡេងផ្សេងៗទៀត ឬនិមិត្តសញ្ញានៃសំឡេង ក្រៅពីទម្រង់នៃការថតបញ្ចូលជាខ្សែភាពយន្ត ឬស្នាដៃសោតទស្សន៍ផ្សេងៗទៀត។ |
| អាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ | Compulsory License for Public Health | សំដៅដល់អាជ្ញាបណ្ណដែលផ្ដល់ដោយក្រសួងសុខាភិបាល ដែលអនុញ្ញាតឱ្យផលិត ឬនាំចូល ឬនាំចេញនូវផលិតផលឱសថដែលការពារដោយប្រកាសនីយបត្រតក្កកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម។ |
| អនុសញ្ញាទីក្រុងប៉ារីស | Paris Convention | សំដៅដល់អនុសញ្ញាទីក្រុងប៉ារីសសម្រាប់កិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ជាកិច្ចព្រមព្រៀងអន្តរជាតិអនុវត្តលើកម្មសិទ្ធិឧស្សាហកម្មយ៉ាងទូលំទូលាយ រួមមានប្រកាសនីយបត្រតក្កកម្ម ម៉ាក គំនូរឧស្សាហកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ពាណិជ្ជនាមម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងការទប់ស្កាត់ការប្រកួតប្រជែងមិនស្មោះត្រង់។ |
| អនុសញ្ញាទីក្រុងប៊ែន | Berne Convention | សំដៅដល់អនុសញ្ញាទីក្រុងប៊ែន ស្ដីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រនិងសិល្បៈឆ្នាំ១៨៨៦។ |

## ឧបសម្ព័ន្ធ : សកម្មភាពលម្អិតសម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា

| គោលដៅទី១៖<br>ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាឱ្យស្របតាមបទដ្ឋានអន្តរជាតិ និងពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច និងសង្គម និងការអភិវឌ្ឍ។ | | | | |
|---|---|---|---|---|
| **វិស័យ** | **គំនិតផ្តួចផ្តើម** | **សកម្មភាពដែលត្រូវស្នើ** | **ក្រសួងទទួលបន្ទុកអនុវត្ត** | **រយៈពេល** |
| **កសិកម្ម** | ពិនិត្យច្បាប់កម្មសិទ្ធិបញ្ញារបស់ព្រះរាជាណាចក្រកម្ពុជាឡើងវិញ ដើម្បីកំណត់ចំណុចដែលត្រូវធ្វើវិសោធនកម្ម ឱ្យស្របតាមភាពបត់បែននិងការអនុគ្រោះរបស់កិច្ចព្រមព្រៀងអន្តរជាតិ ដើម្បីទាញយកប្រយោជន៍ដល់វិស័យកសិកម្ម។ | **សកម្មភាព១.១** : ធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងពិនិត្យឡើងវិញនូវច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងច្បាប់កម្មសិទ្ធិបញ្ញាពាក់ព័ន្ធ ក្នុងករណីចាំបាច់ ត្រូវធ្វើការកែលម្អ ធ្វើបច្ចុប្បន្នកម្មនិងដកចេញនូវមាត្រាណាដែលផ្ទុយនិងមិនសមស្រប ដើម្បីផ្តល់អត្ថប្រយោជន៍ដល់វិស័យកសិកម្ម។ | MoC/MAFF ដឹកនាំ<br>MISTI/MoCFA/MoJ | រយៈពេលមធ្យម |
| | ត្រៀមចូលជាសមាជិកអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ។ | **សកម្មភាព១.២** : សិក្សាអំពីគុណសម្បត្តិនិងគុណវិបត្តិនៃការចូលជាសមាជិកអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ។ | MISTI/MAFF ដឹកនាំ<br>MoC/MoCFA/<br>MoE/MoJ | រយៈពេលខ្លី |
| | | **សកម្មភាព១.៣** : ពិនិត្យឡើងវិញអំពីច្បាប់ស្តីពីពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំឱ្យស្របតាមអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ ក្នុងករណីចាំបាច់ធ្វើវិសោធនកម្មច្បាប់។ | MISTI/MAFF ដឹកនាំ<br>MoC/MoCFA/<br>MoE/MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤** : រៀបចំនីតិវិធីនិងបែបបទចូលជាសមាជិកអនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារពូជថ្មីនៃដំណាំ។ | MAFF/MISTI ដឹកនាំ<br>MoC/MoCFA/<br>MoE/MoJ/OCM | រយៈពេលមធ្យម |
| | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងធនធានពន្ធុ និងការ | **សកម្មភាព១.៥** : រៀបចំលិខិតបទដ្ឋាននិងនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្មសម្រាប់ជីវៈចម្រុះ។ | MISTI/MAFF/<br>MoE ដឹកនាំ | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | បែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយស្មើភាពនិងសមភាព។ | | MoC/MoCFA/ MoJ/OCM | |
| | | **សកម្មភាព១.៦** ៖ រៀបចំនីតិវិធីរដ្ឋបាលសម្រាប់ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាទាក់ទងនឹងប្រកាសនីយបត្រតក្កកម្មសម្រាប់ជីវៈចម្រុះ។ | MISTI/MAFF/ MoE ដឹកនាំ MoC/MoCFA/ MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៧** ៖ ផ្សព្វផ្សាយនិងរៀបចំនីតិវិធីសម្រាប់អនុវត្តអនុក្រឹត្យស្តីពីការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ។ | MoE ដឹកនាំ MoC/MISTI/ MoCFA/ MAFF/OCM | រយៈពេលមធ្យម |
| **វប្បធម៌** | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនិងពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាដើម្បីគាំទ្រនិងអភិវឌ្ឍការច្នៃប្រឌិតក្នុងវិស័យវប្បធម៌របស់ព្រះរាជាណាចក្រកម្ពុជា។ | **សកម្មភាព១.៨** ៖ ពិនិត្យឡើងវិញនូវច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងអនុក្រឹត្យស្តីពីឧស្សាហកម្មភាពយន្ត ដើម្បីធ្វើបច្ចុប្បន្នកម្មឱ្យកាន់តែមានសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិ ក្នុងករណីចាំបាច់ធ្វើវិសោធនកម្មច្បាប់ ដើម្បីអភិវឌ្ឍវិស័យឧស្សាហកម្មភាពយន្ត។ | MoCFA/MoInfo ដឹកនាំ MoC/MISTI/ MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៩** ៖ ពិនិត្យឡើងវិញនូវច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងធ្វើវិសោធនកម្មច្បាប់ ដោយបញ្ចូលជំពូកអង្គភាពគ្រប់គ្រងសិទ្ធិរួម និងបញ្ចូលវិធានការការពារបច្ចេកវិទ្យា។ | MoCFA ដឹកនាំ MoC/MISTI/MoJ/ MoInfo/MPTC/ MoEYS/MLVT/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.១០** ៖ រៀបចំអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ | MoCFA ដឹកនាំ MoC/MISTI/ MoJ/MoInfo/ MPTC/OCM | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.១១** : រៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ក្នុងនោះនឹងមានការសិក្សាដោយបន្ថែមខ្លឹមសារទាក់ទងនឹងកម្មសិទ្ធិបញ្ញា។ | MoInfo ដឹកនាំ MoC/MISTI/ MoCFA/MoJ/OCM | រយៈពេលមធ្យម |
| | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការចូលជាសមាជិកនៃសន្ធិសញ្ញាស្តីពីការសម្តែងនិងហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ | **សកម្មភាព១.១២** : សិក្សាអំពីគុណសម្បត្តិនិងគុណវិបត្តិនៃការចូលជាសមាជិកសន្ធិសញ្ញាស្តីពីការសម្តែងនិងហ្វូណូក្រាម របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ | MoCFA/MoC ដឹកនាំ MISTI/MoInfo/MoJ | រយៈពេលខ្លី |
| | | **សកម្មភាព១.១៣** : ធ្វើវិសោធនកម្មច្បាប់សិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ឱ្យស្របតាមសន្ធិសញ្ញាស្តីពីការសម្តែង និងហ្វូណូក្រាម របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងស្របតាមការវិវត្តបច្ចេកវិទ្យា។ | MoCFA/MoC ដឹកនាំ MISTI/MoInfo/ MoJ/MPTC/MoEYS/ MLVT/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.១៤** : រៀបចំនីតិវិធីនិងបែបបទសម្រាប់ការចូលជាសមាជិកសន្ធិសញ្ញាទីក្រុងម៉ារ៉ាកេសស្តីពីការសម្រួលដល់ការទទួលបាននូវស្នាដៃដែលបានបោះពុម្ពសម្រាប់ជនពិការភ្នែក បាត់បង់សមត្ថភាពចក្ខុទស្សន៍ ឬការបោះពុម្ពដទៃទៀតសម្រាប់ជនពិការ។ | MoCFA/MoC ដឹកនាំ MISTI/MoInfo/ MoJ/MoSVY/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.១៥** : រៀបចំនីតិវិធីនិងបែបបទសម្រាប់ចូលជាសមាជិកនៃសន្ធិសញ្ញាស្តីពីការសម្តែងនិងហ្វូណូក្រាម របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងសន្ធិសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។ | MoCFA/MoC ដឹកនាំ MISTI/MoInfo/ MoJ/OCM | រយៈពេលមធ្យម |
| | បង្កើតប្រព័ន្ធអាជ្ញាបណ្ណបញ្ញាកម្មសិទ្ធិបញ្ញានិងអាជ្ញាបណ្ណបញ្ញាសម្រាប់គ្រប់គ្រងការបោះពុម្ពឡើងវិញ និងបង្កើត | **សកម្មភាព១.១៦** : រៀបចំប្រព័ន្ធអាជ្ញាបណ្ណបញ្ញាក្នុងការប្រើប្រាស់ ស្នាដៃសម្រាប់ជនពិការភ្នែកដែលបាត់បង់សមត្ថភាពចក្ខុទស្សន៍ ឬមិនអាចទទួលបានការបោះពុម្ពដទៃទៀត និងប្រព័ន្ធអាជ្ញាបណ្ណបញ្ញាកម្មសិទ្ធិបញ្ញាដទៃទៀត។ | MoCFA ដឹកនាំ MoC/MISTI/ MoInfo | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | ប្រព័ន្ធទិន្នន័យគ្រប់គ្រងការប្រើប្រាស់ស្នាដៃ សម្រាប់បង្កើតមាតិកានៅលើប្រព័ន្ធអ៊ីនធឺណិតនិងថ្នាលបច្ចេកវិទ្យា។ | **សកម្មភាព១.១៧** : សិក្សានិងបង្កើតវិធានការចាំបាច់ដើម្បីផ្តល់ដំណោះស្រាយនិងការគាំទ្រដល់វិស័យឯកជន ក្នុងគោលបំណងកាត់បន្ថយការចំណាយរបស់អ្នកប្រើប្រាស់ស្នាដៃ និងបន្ទុករបស់ម្ចាស់សិទ្ធិ។ | MoCFA ដឹកនាំ MoC/MISTI/ MoInfo/MoEYS | រយៈពេលមធ្យម |
| | | **សកម្មភាព១.១៨** : បង្កើតបញ្ជរតែមួយ និងប្រព័ន្ធទិន្នន័យប្រមូលផ្តុំក្នុងការគ្រប់គ្រងនិងផ្តល់ការអនុញ្ញាតប្រើប្រាស់ស្នាដៃសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល សម្រាប់បង្កើតមាតិកា តូរ្យតន្ត្រី ភាពយន្ត អក្សរសាស្ត្រ។ល។ នៅលើប្រព័ន្ធអ៊ីនធឺណិត និងថ្នាលបច្ចេកវិទ្យាផ្សេងៗ។ | MoCFA ដឹកនាំ MoC/MISTI/ MoInfo/MoEYS | រយៈពេលមធ្យម |
| | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌។ | **សកម្មភាព១.១៩** : សិក្សា និងផ្សារភ្ជាប់រាល់វេទិកាជាតិ និងអន្តរជាតិ ដើម្បីទាញយកប្រយោជន៍អំពីធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌។ | MoE/MoCFA ដឹកនាំ MoC/MISTI/ MAFF/MoH/MoInfo | រយៈពេលខ្លី |
| | | **សកម្មភាព១.២០** : សិក្សាស្រាវជ្រាវនិងចងក្រងសន្និធិនៃធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ ដែលត្រូវបានការពារឱ្យមានប្រសិទ្ធភាពក្រោមប្រព័ន្ធច្បាប់ដាច់ដោយឡែក។ | MoE/MoCFA ដឹកនាំ MoC/MISTI/ MAFF/MoH/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព១.២១** : បង្កើតច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ ព្រមទាំងបទប្បញ្ញត្តិសម្រាប់អនុវត្ត។ | MoCFA/MoE ដឹកនាំ MoC/MISTI/ /MoH/MAFF/ MoInfo/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.២២** : រៀបចំប្រព័ន្ធទិន្នន័យនិងតាមដានត្រួតពិនិត្យការប្រើប្រាស់ធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ដោយគ្មានការអនុញ្ញាតពីព្រះរាជាណាចក្រកម្ពុជា។ | MoE/MoCFA ដឹកនាំ MoC/MISTI//MoH/ MAFF/MoInfo | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.២៣** : រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តដើម្បីគ្រប់គ្រង និងការពារនូវការប្រើប្រាស់មិនត្រឹមត្រូវ ឬការប្រើប្រាស់ផ្ទុយនឹងសីលធម៌ និងសណ្តាប់ធ្នាប់សាធារណៈនៃរូបភាពបូជនីយដ្ឋាន ប្រវត្តិសាស្ត្រ អង្គរ រចនាបថប្រាសាទបុរាណ ទង់ជាតិ និមិត្តសញ្ញាជាតិ នានារបស់ព្រះរាជាណាចក្រកម្ពុជា។ | MoCFA/MoC ដឹកនាំ MISTI/MFA.IC/ OCM | រយៈពេលមធ្យម |
| **ការអប់រំនិងការលើកកម្ពស់ចំណេះដឹងសាធារណៈ** | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រការលើកកម្ពស់ការអប់រំនិងចំណេះដឹងសាធារណៈ។ | **សកម្មភាព១.២៤** : ពិនិត្យឡើងវិញនូវច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល និងបទប្បញ្ញត្តិពាក់ព័ន្ធ ក្នុងករណីចាំបាច់ធ្វើវិសោធនកម្ម ដើម្បីឱ្យព្រះរាជាណាចក្រកម្ពុជាអាចទាញយកប្រយោជន៍ពេញលេញពីកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលផ្តល់ការអនុគ្រោះក្នុងការទទួលបានស្នាដៃអក្សរសាស្ត្រ ព័ត៌មាន និងចំណេះដឹង សម្រាប់គោលបំណងអប់រំ និងលើកកម្ពស់ចំណេះដឹងសាធារណៈ។ | MoCFA/MoEYSដឹកនាំ MoC/MISTI/ MoInfo/MLVT/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.២៥** : រៀបចំប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារតំណាងស្របច្បាប់នៃសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ | MoCFA ដឹកនាំ MoC/MISTI | រយៈពេលខ្លី |
| | | **សកម្មភាព១.២៦** : រៀបចំប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារតំណាងស្របច្បាប់នៃប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងពូជថ្មីនៃដំណាំ។ | MISTI ដឹកនាំ MoC/MoCFA | រយៈពេលខ្លី |
| | | **សកម្មភាព១.២៧** : រៀបចំប្រកាសស្តីពី មគ្គុទ្ទេសក៍ជាតិនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។ | MISTI ដឹកនាំ MoC/MoCFA | រយៈពេលខ្លី |
| | | **សកម្មភាព១.២៨** : រៀបចំប្រកាសស្តីពីមគ្គុទ្ទេសក៍ជាតិសម្រាប់ការចុះបញ្ជីម៉ាក។ | MoC ដឹកនាំ MISTI/MoCFA/ MoInfo | រយៈពេលខ្លី |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.២៩** : រៀបចំប្រកាសស្តីពីមគ្គុទ្ទេសក៍ជាតិនៃការចុះបញ្ជីពូជថ្មីនៃដំណាំ។ | MISTI/MAFF | រយៈពេលខ្លី |
| | | **សកម្មភាព១.៣០** : រៀបចំផែនការយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញានៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍពាក់ព័ន្ធ។ | MISTI/MoEY ដឹកនាំ MoCFA/MLVT/ MPTC/MAFF | រយៈពេលខ្លី |
| **សុខាភិបាល** | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា និងបង្កើនកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ដើម្បីទទួលបានផលិតផលឱសថ សម្រាប់ធ្វើឱ្យប្រសើរឡើងថែមទៀតនូវវិស័យសុខាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា។ | **សកម្មភាព១.៣១** : ពិនិត្យឡើងវិញនូវច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ដើម្បីកំណត់ចំណុចដែលត្រូវកែលម្អ និងធ្វើបច្ចុប្បន្នកម្ម ឱ្យស្របតាមបទដ្ឋានអន្តរជាតិដែលអាចអនុវត្តបាន ដើម្បីផ្តល់អត្ថប្រយោជន៍ដល់សុខភាពសាធារណៈ។ | MISTI/MoH ដឹកនាំ MoC/MoCFA/ MFA.IC/OCM | រយៈពេលវែង |
| | | **សកម្មភាព១.៣២** : ពិនិត្យឡើងវិញនូវវិធានការបច្ចុប្បន្ន និងរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តសម្រាប់កិច្ចការពារ និងធានាប្រសិទ្ធភាពនៃឱសថបុរាណ និងការព្យាបាលតាមបែបចំណេះដឹងជាប្រពៃណី។ | MoH ដឹកនាំ MoC/MISTI/ MoCFA/MoE/ MoJ/MAFF | រយៈពេលមធ្យម |
| | | **សកម្មភាព១.៣៣** : ជំរុញការផលិតឱសថស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអនុគ្រោះដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និងស្របតាមច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ តាមរយៈការផ្តល់ការអនុគ្រោះពន្ធ និងការលើកទឹកចិត្តដល់អ្នកវិនិយោគ និងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ | MISTI/MoH ដឹកនាំ MoC/MoCFA/ MEF/CDC | រយៈពេលវែង |
| | | **សកម្មភាព១.៣៤** : បន្តអភិវឌ្ឍគេហទំព័រដែលមានស្រាប់របស់នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និង | MoH ដឹកនាំ MoC/MISTI/ MoCFA/MoEYS/ | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | ចំណីអាហារសម្រាប់ការចូលទៅកាន់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងផលិតផលឱសថ និងធ្វើការតភ្ជាប់ ទៅកាន់ប្រព័ន្ធនានា ដូចជាការស្រាវជ្រាវផលិតផលឱសថតាមរយៈប្រព័ន្ធបើកចំហ និងកម្មវិធីចូលទៅកាន់ការសិក្សាស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ និងនវានុវត្តន៍របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក សម្រាប់ឱសថការីនិងភាគីពាក់ព័ន្ធក្នុង ការស្រាវជ្រាវនិងការអភិវឌ្ឍផលិតផលឱសថសម្រាប់បង្ការនិងព្យាបាលជំងឺ។ | MPTC | |
| | | **សកម្មភាព១.៣៥** : បង្កើតក្រុមប្រឹក្សាជាតិស្រាវជ្រាវវិទ្យាសាស្ត្រសុខាភិបាលនិងឱសថ។ | MoH/MISTI ដឹកនាំ<br>MoC/MoCFA/MoEYS | រយៈពេលខ្លី |
| | | **សកម្មភាព១.៣៦** : អភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាជាតិស្រាវជ្រាវវិទ្យាសាស្ត្រសុខាភិបាលនិងឱសថ ក្នុងការអភិវឌ្ឍផលិតផលឱសថទូទៅ គក្កកម្មឱសថ និងឧបករណ៍បរិក្ខារពេទ្យ។ | MoH/MISTI ដឹកនាំ<br>MoC/MoCFA/<br>MoEYS/MPTC | រយៈពេលវែង |
| | | **សកម្មភាព១.៣៧** : រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការនៃអង្គភាពទទួលបន្ទុក និងផ្សព្វផ្សាយ អនុវត្តច្បាប់កម្មសិទ្ធិបញ្ញាក្នុងការទប់ស្កាត់និងលុបបំបាត់ផលិតផលឱសថក្លែងក្លាយ។ | MoH/MoI/<br>MoJ ដឹកនាំ<br>MoC/MISTI/MoCFA/<br>MoInfo/OCM | រយៈពេលមធ្យម |
| **ពាណិជ្ជកម្ម និងឧស្សាហកម្ម** | កែសម្រួល និងរៀបចំបង្កើតច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់វិស័យពាណិជ្ជកម្មនិងឧស្សាហកម្ម។ | **សកម្មភាព១.៣៨** : ពិនិត្យឡើងវិញនូវច្បាប់កម្មសិទ្ធិបញ្ញាពាក់ព័ន្ធដើម្បីកំណត់ចំណុចដែលត្រូវកែលម្អ ឱ្យស្របតាមបទដ្ឋានអន្តរជាតិ ដែលអាចអនុវត្តបានដើម្បីផ្តល់អត្ថប្រយោជន៍ដល់ឧស្សាហកម្មពាណិជ្ជកម្ម ជាពិសេស សហគ្រាសធុនមីក្រូ តូច និងមធ្យម។ | MoC/MISTI/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១.៣៩** : ពិនិត្យច្បាប់ស្តីពីការប្រកួតប្រជែង និងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ក្នុងករណីចាំបាច់បញ្ចូលផ្នែកកម្មសិទ្ធិបញ្ញា។ | MoC ដឹកនាំ<br>MISTI/MoCFA/<br>OCM/MoJ | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.៤០** : រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនបង្ហាញ។ | MoC ដឹកនាំ MISTI/MoH/ MAFF/MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤១** : រៀបចំអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងព័ត៌មានមិនបង្ហាញ។ | MoC ដឹកនាំ MISTI/MoH/ MAFF/MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤២** : រៀបចំអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលសម្រាប់ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា។ | MoC ដឹកនាំ MISTI/MoCFA/ MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤៣** : រៀបចំប្រកាសស្តីពីយន្តការដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាក្រៅប្រព័ន្ធតុលាការ។ | MoC ដឹកនាំ MISTI/MoCFA/MoJ | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤៤** : ពិនិត្យឡើងវិញនូវប្រកាសស្តីពីការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម ក្នុងករណីចាំបាច់ធ្វើការកែសម្រួល ដើម្បីជំរុញការអនុវត្ត កិច្ចសន្យាអាជ្ញាបណ្ណ និង កិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្មឱ្យមានប្រសិទ្ធភាព។ | MoC ដឹកនាំ MISTI/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤៥** : កែសម្រួលប្រកាសស្តីពីការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ ដោយបញ្ចូលផ្នែកនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ | MoC | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤៦** : រៀបចំប្រកាសពាក់ព័ន្ធនឹងយន្តការដោះស្រាយវិវាទនៃការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិតជាមួយនឹងម៉ាក និងនាមករណ៍សហគ្រាស។ | MPTC/MoC ដឹកនាំ MoJ | រយៈពេលមធ្យម |
| | | **សកម្មភាព១.៤៧** : បង្កើតប្រព័ន្ធតភ្ជាប់សម្រាប់ធ្វើការស្រាវជ្រាវឈ្មោះដែនជាតិ ដែលបានដាក់ពាក្យចុះបញ្ជីនៅក្រសួងប្រៃសណីយ៍និង | MPTC/MoC ដឹកនាំ | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | ទូរគមនាគមន៍ ទៅនឹងម៉ាកនិងនាមករណ៍សហគ្រាសដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ | | |
| | | **សកម្មភាព១.៤៨** : រៀបចំប្រកាសពាក់ព័ន្ធនឹងនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម ជាលក្ខណៈអន្តរជាតិ។ | MISTI ដឹកនាំ MoC/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព ១.៤៩** : ពិនិត្យឡើងវិញនូវបច្ចុប្បន្នកម្ម ប្រកាសស្តីពីនីតិវិធីផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងប្រកាសស្តីពីនីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម ។ | MISTI ដឹកនាំ MoC/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥០** : រៀបចំឧបករណ៍និងឯកសារសម្រាប់ការបណ្តុះបណ្តាល ការកសាងកេរ្តិ៍ឈ្មោះម៉ាក ដើម្បីពង្រឹងភាពប្រកួតប្រជែងរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម។ | MoC ដឹកនាំ MISTI/MoCFA/ MEF | រយៈពេលខ្លី |
| | | **សកម្មភាព១.៥១** : រៀបចំតុលាការពាណិជ្ជកម្មសម្រាប់ដោះស្រាយវិវាទកម្មសិទ្ធិបញ្ញា។ | MoJ ដឹកនាំ MoC/MISTI/ MoCFA//MoI | រយៈពេលវែង |
| | | **សកម្មភាព១.៥២** : ពិនិត្យសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ក្នុងករណីចាំបាច់បញ្ចូលជំពូកកម្មសិទ្ធិបញ្ញា។ | MoI ដឹកនាំ MoC/MoCFA/ MISTI/MoJ/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥៣** : បង្កើតប្រព័ន្ធតភ្ជាប់សម្រាប់ការស្រាវជ្រាវម៉ាកដែលបានចុះបញ្ជី រវាងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | MoC/MEF | រយៈពេលខ្លី |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.៥៤** : បង្កើតប្រព័ន្ធតភ្ជាប់សម្រាប់ការស្រាវជ្រាវ ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម រវាងនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | MISTI/MEF | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥៥** : រៀបចំប្រកាសស្តីពីនីតិវិធីបណ្តឹងតវ៉ាម៉ាក។ | MoC ដឹកនាំ<br>MISTI/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥៦** : រៀបចំប្រកាសស្តីពីនីតិវិធីបណ្តឹងតវ៉ាប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គំនូរឧស្សាហកម្ម។ | MISTI ដឹកនាំ<br>MoC/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥៧** : រៀបចំប្រកាសស្តីពីនីតិវិធីបណ្តឹងតវ៉ា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ | MoCFA ដឹកនាំ<br>MoC/MISTI | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥៨** : រៀបចំប្រកាសទាក់ទងនឹងការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណចំពោះប្រកាសនីយបត្រតក្កកម្មនិងគំនូរឧស្សាហកម្ម។ | MISTI ដឹកនាំ<br>MoC/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១.៥៩** : រៀបចំប្រកាសទាក់ទងនឹងការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណចំពោះសិទ្ធិអ្នកនិពន្ធ។ | MoCFA ដឹកនាំ<br>MoC/MISTI | រយៈពេលមធ្យម |
| **ទេសចរណ៍** | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់សេវាកម្មនិងផលិតផលទេសចរណ៍របស់ព្រះរាជាណាចក្រកម្ពុជា។ | **សកម្មភាព១.៦០** : ពិនិត្យឡើងវិញនូវច្បាប់កម្មសិទ្ធិបញ្ញាពាក់ព័ន្ធ ដើម្បីកំណត់ចំណុចដែលត្រូវកែលម្អ ឱ្យស្របតាមបទដ្ឋានអន្តរជាតិ ដែលអាចអនុវត្តបាន ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ឧស្សាហកម្មទេសចរណ៍។ | MoT/MoC ដឹកនាំ<br>MoCFA/MISTI/<br>MAFF/MoE/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៦១** : រៀបចំប្រកាសស្តីពីការគ្រប់គ្រងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព សម្រាប់គោលដៅទេសចរណ៍។ | MoC/MoT ដឹកនាំ<br>MoCFA/MAFF/MoE | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.៦២** : បន្តពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីទប់ស្កាត់និងបង្ក្រាបទំនិញក្លែងក្លាយនៅលើទីផ្សារ និងការពារអ្នកប្រើប្រាស់ ដើម្បីបង្កើនជំនឿទុកចិត្តពីអតិថិជននិងអ្នកទេសចរ។ | MoI/ MoC/<br>MoT ដឹកនាំ<br>MoCFA/MEF/MoE | រយៈពេលវែង |
| | | **សកម្មភាព១.៦៣** : រៀបចំនិងសិក្សាផលិតផលទេសចរណ៍ ដែលមានសក្តានុពល ដើម្បីរៀបចំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម។ | MoC/MoT ដឹកនាំ<br>MoCFA/MoE/MAFF | រយៈពេលខ្លី |
| | | **សកម្មភាព១.៦៤** : រៀបចំបទប្បញ្ញត្តិនិងនីតិវិធីក្នុងការចុះបញ្ជីម៉ាកវិញ្ញាតកម្មនៃផលិតផលទេសចរណ៍ ដើម្បីអាចឱ្យអតិថិជនធ្វើការកំណត់អំពីកម្រិតគុណភាពនៃទំនិញឬសេវាកម្ម ដើម្បីលើកកម្ពស់ ជំនឿទុកចិត្តរបស់អតិថិជន និងអ្នកទេសចរ។ | MoT/MoC ដឹកនាំ<br>MoCFA/MISTI/<br>MAFF/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៦៥** : រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយនិងទំនាក់ទំនង ដើម្បីលើកកម្ពស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម និងម៉ាកសំខាន់ៗ និងផលិតផលបច្ចេកវិទ្យា និងគំនិតច្នៃប្រឌិតរបស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈការរៀបចំវីដេអូផ្សព្វផ្សាយខ្លីៗ ខិត្តប័ណ្ណផ្សព្វផ្សាយ ការចូលរួមវេទិកា ពិព័រណ៍ និងការដាក់តាំងបង្ហាញនានា ដើម្បីកសាងកេរ្តិ៍ឈ្មោះម៉ាក របស់ព្រះរាជាណាចក្រកម្ពុជាជាគោលដៅទេសចរណ៍។ | MoC/MoT ដឹកនាំ<br>MISTI/MoCFA/<br>MPTC/MAFF/<br>MoInfo/MoEYS/<br>MLVT | រយៈពេលវែង |
| **វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា** | រៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងកម្មសិទ្ធិបញ្ញា សម្រាប់សិក្សាស្រាវជ្រាវនិងអភិវឌ្ឍ។ | **សកម្មភាព១.៦៦** : ពិនិត្យនិងជំរុញការអនុវត្តកាតព្វកិច្ចរបស់កម្ពុជាដើម្បីឱ្យមានអនុលោមភាព និងអាចទាញយកប្រយោជន៍នៃការផ្ទេរបច្ចេកវិទ្យា ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា។ | MISTI ដឹកនាំ<br>MoC/MoCFA/MoH/<br>MPTC/MAFF/<br>MoInfo/MoEYS/<br>MLVT/MFA.IC | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.៦៧** ៖ រៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញាសម្រាប់បច្ចេកវិទ្យានិងនវានុវត្តន៍។ | MISTI/MoC ដឹកនាំ MoCFA/MoEYS/ MPTC/MLVT | រយៈពេលមធ្យម |
| | | **សកម្មភាព១.៦៨** ៖ សិក្សាគុណសម្បត្តិ និងគុណវិបត្តិ អំពី អនុសញ្ញាទីក្រុងព្រុចសែលទាក់ទងនឹងការចែកចាយរលកសញ្ញានៃកម្មវិធីដែលបញ្ជូនតាមរយៈផ្កាយរណប។ | MPTC ដឹកនាំ MoC/MoCFA/ MISTI/MoInfo | រយៈពេលខ្លី |
| | | **សកម្មភាព១.៦៩** ៖ សិក្សាពិនិត្យលទ្ធភាពដើម្បីត្រៀមរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការចែកចាយរលកសញ្ញាផ្ទុកកម្មវិធីដែលបញ្ជូនតាមរយៈផ្កាយរណប។ | MPTC ដឹកនាំ MoC/MoCFA/ MISTI/MoInfo/ OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៧០** ៖ ពិនិត្យបច្ចុប្បន្នកម្មនិងធ្វើវិសោធនកម្មច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ឱ្យស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ និងការវិវត្តនៃបច្ចេកវិទ្យា។ | MISTI ដឹកនាំ MoC/MoCFA/ MPTC/MoH/ MoInfo/OCM | រយៈពេលវែង |
| | | **សកម្មភាព១.៧១** ៖ រៀបចំច្បាប់ស្តីពីគំនូសបង្ហាញនៃសៀគ្វីបង្រួម។ | MISTI ដឹកនាំ MPTC/MoC/ MoCFA/OCM | រយៈពេលមធ្យម |
| | | **សកម្មភាព១.៧២** ៖ សិក្សាអំពីបញ្ហានិងលទ្ធភាពនៃការផ្ទេរបច្ចេកវិទ្យាជំនាញ និងការផ្តល់អាជ្ញាបណ្ណ ក្នុងករណីចាំបាច់បង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាបៃតង និងដោះស្រាយនូវបញ្ហាទាំងនេះ។ | MISTI ដឹកនាំ MoC/MoCFA/ MPTC/MLVT/ MoE/MFA.IC | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព១.៧៣** : បង្កើតមជ្ឈមណ្ឌលគាំពារព័ត៌មានបច្ចេកវិទ្យា និងប្រព័ន្ធសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក សម្រាប់ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ។ | MoC/MISTI ដឹកនាំ MoCFA/MAFF/ MPTC/MoEYS/ MLVT | រយៈពេលមធ្យម |
| | ពិនិត្យនិងអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារ និងការអនុគ្រោះផ្សេងៗ ព្រមទាំងឧបត្ថម្ភទុន ដើម្បីជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ។ | **សកម្មភាព១.៧៤** : សិក្សាពីរបៀបដែលប្រទេសមួយចំនួនប្រើវិធានការសារពើពន្ធ ដើម្បីជំរុញការច្នៃប្រឌិត និងការបង្កើតថ្មី និងពិនិត្យលទ្ធភាពរៀបចំបង្កើតលិខិតបទដ្ឋានគតិយុត្ត ដើម្បីផ្តល់ការអនុគ្រោះពន្ធនិងការអនុគ្រោះផ្សេងៗដល់ក្រុមហ៊ុនពាក់ព័ន្ធ និងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។ | MEF/MISTI ដឹកនាំ MoC/MoCFA/ MPTC/MoEYS/ MLVT | រយៈពេលខ្លី |
| | | **សកម្មភាព១.៧៥** : ផ្តល់ធនធាននិងដំណោះស្រាយនូវតម្រូវការជាក់លាក់របស់តក្កករ អ្នកច្នៃប្រឌិត ដែលជាក្រុមគោលដៅក្នុងការបង្កើតទ្រព្យកម្មសិទ្ធិបញ្ញា និងការធ្វើពាណិជ្ជកម្ម។ | MEF/MISTI ដឹកនាំ MoC/MPTC/ MoEYS/MLVT | រយៈពេលវែង |
| **គំនិតផ្តួចផ្តើមគន្លឹះ:** | | | | |
| កសាងសមត្ថភាពផ្នែកកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងសិក្សាស្រាវជ្រាវនិងអភិវឌ្ឍ។ | | **សកម្មភាព១.៧៦** : បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញាសម្រាប់លើកកម្ពស់សមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា អ្នកសិក្សាស្រាវជ្រាវនិងអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម និងការអភិវឌ្ឍបច្ចេកវិទ្យា និងនវានុវត្តន៍។ | MoC/MISTI ដឹកនាំ MoCFA/MPTC/ MoEYS/MLVT/ MoE/MAFF/MoJ/ MoInfo/MoI/MEF/ MoWA | រយៈពេលវែង |
| | | **សកម្មភាព១.៧៧** : បង្កើតនិងគាំទ្រការអភិវឌ្ឍសមាគមតក្កករនិងអ្នកច្នៃប្រឌិតនៃព្រះរាជាណាចក្រកម្ពុជា។ | MISTI ដឹកនាំ MoC/MoCFA/ MPTC/MoEYS/ MLVT/MAFF/ MEF/MoWA | រយៈពេលវែង |

**គោលដៅទី២៖**

ការពង្រឹងនិងលើកកម្ពស់សមត្ថភាពមន្ត្រីនិងអង្គភាពក្នុងការអនុវត្តប្រព័ន្ធកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

| វិស័យ | ការផ្តួចផ្តើម | សកម្មភាពដែលបានស្នើឡើង | ក្រសួងទទួលបន្ទុកអនុវត្ត | រយៈពេល |
|---|---|---|---|---|
| **កសិកម្ម** | កសាងសមត្ថភាពមន្ត្រីទទួលបន្ទុក និងភ្នាក់ងារកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់ជំនួយបច្ចេកទេស និងជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាដោយវិស័យឯកជនដើម្បីធ្វើឱ្យវិស័យកសិកម្មកាន់តែប្រសើរឡើង។ | **សកម្មភាព២.១** : ផ្តល់ការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពដល់មន្ត្រីទទួលបន្ទុក គ្រូបង្គោលតាមបណ្តារាជធានី ខេត្ត មន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងភ្នាក់ងារកម្មសិទ្ធិបញ្ញា លើមុខវិជ្ជាពាក់ព័ន្ធនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម និងការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីផ្តល់ប្រឹក្សាយោបល់ និងជួយគាំទ្រដល់កសិករនិងសហគ្រិនផ្នែកកសិកម្ម។ | MoC/MAFF ដឹកនាំ MISTI/MoEYS/MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព២.២** : សហការជាមួយនឹងអង្គភាពកម្មសិទ្ធិបញ្ញា ដៃគូអភិវឌ្ឍ ក្នុងការចែករំលែកបទពិសោធ និងបច្ចេកទេស និងរៀបចំកម្មវិធីបណ្តុះបណ្តាល និងផ្តល់ការគាំទ្រដល់មន្ត្រី គ្រប់គ្រងពូជដំណាំ អ្នកបង្កាត់ពូជថ្មីនៃដំណាំ កសិករ និងភាគីពាក់ព័ន្ធ។ | MAFF/MISTI ដឹកនាំ MoC/MoE/MoEYS | រយៈពេលវែង |
| | | **សកម្មភាព២.៣** : ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា និងផ្តល់បច្ចេកទេស សម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍពូជថ្មីនៃដំណាំនិងជំរុញការធ្វើពាណិជ្ជកម្មពូជដំណាំដែលបង្កាត់ដោយកសិករនិងអ្នកបង្កាត់ពូជថ្មីនៃដំណាំរបស់ព្រះរាជាណាចក្រកម្ពុជា។ | MAFF/MISTI ដឹកនាំ MoC/MoE/MoEYS | រយៈពេលវែង |
| | បង្កើតប្រព័ន្ធសម្រាប់គ្រប់គ្រង និងចុះបញ្ជីពូជដំណាំ និងរៀបចំការចុះបញ្ជី | **សកម្មភាព២.៤** : បង្កើតផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញា និងផ្ទេរបច្ចេកវិទ្យា នៅសាកលវិទ្យាល័យ វិទ្យាស្ថាន និងស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍកសិកម្ម និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គភាព | MAFF/MISTI ដឹកនាំ MoC/MEF/MoEYS | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម។ | កម្មសិទ្ធិបញ្ញាជាតិ និងអន្តរជាតិ ក្នុងគោលបំណងស្រាវជ្រាវនិងអភិវឌ្ឍវិស័យកសិកម្ម។ | | |
| | | **សកម្មភាព២.៥** : បង្កើតប្រព័ន្ធទិន្នន័យគ្រប់គ្រងនិងចងក្រងពូជដំណាំ និងនីតិវិធីសម្រាប់ការចុះបញ្ជីពូជថ្មីនៃដំណាំ។ | MAFF/MISTI ដឹកនាំ MoC/MoE | រយៈពេលមធ្យម |
| | | **សកម្មភាព២.៦** : សិក្សាស្រាវជ្រាវនិងចងក្រងផលិតផលកសិកម្មដែលមានសក្តានុពលសម្រាប់ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម។ | MoC/MAFF ដឹកនាំ MISTI/MoCFA/ MoE/MoI | រយៈពេលខ្លី |
| | | **សកម្មភាព២.៧** : រៀបចំចុះបញ្ជីនិងកសាងកេរ្តិ៍ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ដូចជាអំបិលនិងផ្កាអំបិលកំពតកែប ទឹកត្រីកំពត បង្កងតាកែវ ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល នំបញ្ចុកសៀមរាប ក្រូចពោធិ៍សាត់ អង្ករព្រះវិហារ សូត្រខ្មែរ អង្ករស្មាច់ស្វាយរៀង មៀនប៉ៃលិន អង្ករថ្មគោលបាត់ដំបង ស្រាពាងមណ្ឌលគិរី កាហ្វេមណ្ឌលគិរី ប្រហុកសៀមរាប សាច់ក្រកសៀមរាប ផាមូងកោះដាច់ សូត្រភ្នំស្រុក ទុរេនកំពត។ | MoC ដឹកនាំ MISTI/MoCFA/ MAFF/MoE | រយៈពេលវែង |
| **វប្បធម៌** | កសាងសមត្ថភាពមន្ត្រីទទួលបន្ទុក និងភ្នាក់ងារកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់ជំនួយបច្ចេកទេស និងជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាដោយវិស័យឯកជន និងវិស័យព័ត៌មាននិងសោតទស្សន៍ ដើម្បីធ្វើឱ្យប្រសើរឡើងដល់វិស័យវប្បធម៌។ | **សកម្មភាព២.៨** : រៀបចំវគ្គបណ្តុះបណ្តាលអំពីកម្មសិទ្ធិបញ្ញា ជូនអ្នកសារព័ត៌មាន អ្នកនិពន្ធស្នាដៃអក្សរសាស្ត្រ តូរ្យតន្ត្រី ស្នាដៃចម្លាក់ វិចិត្រករ ផលិតករភាពយន្ត សិល្បៈសូនរូប ស្ថាបត្យករ ការរចនាសិល្បៈ និងភាគីពាក់ព័ន្ធ។ | MoCFA ដឹកនាំ MoC/MoT/MoInfo/ MoEYS/MoWA | រយៈពេលវែង |
| | | **សកម្មភាព២.៩** : អភិវឌ្ឍនិងកសាងសមត្ថភាពសាលាសិល្បៈភាពយន្ត។ | MoCFA ដឹកនាំ MoC/MoInfoMoEYS/MoT | រយៈពេលវែង |
| | | **សកម្មភាព២.១០** : សិក្សានិងរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់វិស័យភាពយន្តរបស់ព្រះរាជាណាចក្រកម្ពុជា។ | MoCFA/MoInfo ដឹកនាំ MoC/MoEYS/MoT | រយៈពេលខ្លី |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព២.១១** : បណ្តុះបណ្តាលភ្នាក់ងារសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ដើម្បីផ្តល់ការគាំទ្រនិងប្រឹក្សាយោបល់ជូនវិស័យឯកជននិងភាគីពាក់ព័ន្ធ អំពីការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីជំរុញការបង្កើតស្នាដៃ និងការការពារ អភិវឌ្ឍផលិតផលវប្បធម៌។ | MoCFA ដឹកនាំ MoC/MISTI/MAFF/ MoE/MoT/MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព២.១២** : បណ្តុះបណ្តាលគ្រូបង្គោលនិងពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មន្ត្រីនៃមន្ទីររាជធានី ខេត្តពាក់ព័ន្ធ ដើម្បីផ្តល់សេវានិងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា សម្រាប់ការអភិវឌ្ឍវិស័យវប្បធម៌។ | MoCFA ដឹកនាំ MoC/MISTI/MoEYS/ MAFF/MoE/MoT/ MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព២.១៣** : សិក្សានិងកំណត់ផលិតផលវប្បធម៌ ដែលមានសក្តានុពលនៅតាមតំបន់ ដូចជាចម្លាក់ សិល្បៈសូនរូប និងការរចនាសិល្បៈនានាដើម្បីរៀបចំចុះបញ្ជីជាម៉ាកសម្គាល់ភូមិសាស្ត្រ ទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ដើម្បីការពារ ថែរក្សាតម្លៃវប្បធម៌ អត្តសញ្ញាណ ចំណេះជំនាញ និងលើកកម្ពស់សេដ្ឋកិច្ចពាណិជ្ជកម្ម។ | MoCFA ដឹកនាំ MoC/MISTI/MAFF/ MoE/MoT/MoWA | រយៈពេលមធ្យម |
| | អភិវឌ្ឍសមត្ថភាពនិងហេដ្ឋារចនាសម្ព័ន្ធនៃនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងអង្គភាពគ្រប់គ្រងសិទ្ធិរួម។ | **សកម្មភាព២.១៤** : រៀបចំហេដ្ឋារចនាសម្ព័ន្ធនៃនាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល ដោយបង្កើនចំនួនមន្ត្រី និងពង្រីកកន្លែងធ្វើការឱ្យបានធំទូលាយ ។ | MoCFA ដឹកនាំ MoC/MISTI | រយៈពេលវែង |
| | | **សកម្មភាព២.១៥** : បង្កើតកម្មវិធីបណ្តុះបណ្តាលទៀងទាត់ និងកសាងសមត្ថភាពមន្ត្រីរបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។ | MoCFA ដឹកនាំ MoC/MISTI | រយៈពេលវែង |
| | | **សកម្មភាព២.១៦** : រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់គ្រប់គ្រងការចុះបញ្ជីស្នាដៃសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និង | MoCFA ដឹកនាំ MoC/MISTI/MoInfo | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | សម្រាប់កត់ត្រា តម្កល់ និងស្រាវជ្រាវស្នាដៃសិទ្ធិអ្នកនិពន្ធ។ | | |
| | | **សកម្មភាព២.១៧** : លើកកម្ពស់អភិបាលកិច្ចល្អ បង្កើតយន្តការត្រួតពិនិត្យដំណើរការងាររបស់អង្គភាពគ្រប់គ្រងសិទ្ធិរួម។ | MoCFA ដឹកនាំ MoC/MISTI | រយៈពេលមធ្យម |
| | | **សកម្មភាព២.១៨** : បង្កើតមជ្ឈមណ្ឌលផ្តល់អាជ្ញាបណ្ណ សមូហភាពសម្រាប់ស្នាដៃអ្នកនិពន្ធនិងផ្តល់ការគាំទ្រនិងប្រឹក្សាយោបល់ដល់ម្ចាស់ស្នាដៃ ក្រោមអង្គភាពគ្រប់គ្រងសិទ្ធិរួម ។ | MoCFA ដឹកនាំ MoC/MISTI | រយៈពេលមធ្យម |
| **អប់រំនិងការលើកកម្ពស់ចំណេះដឹងសាធារណៈ** | ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធក្នុងវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីបង្កើតវិធីសាស្ត្រសមស្របក្នុងការលើកកម្ពស់ការច្នៃប្រឌិតថ្មីនៅក្នុងវិស័យអប់រំ។ | **សកម្មភាព២.១៩** : សិក្សានិងអនុវត្តតាមរបៀបដែលប្រទេសដទៃទៀតបានប្រើប្រាស់ការអប់រំកម្មសិទ្ធិបញ្ញា ដើម្បីបណ្តុះគំនិតច្នៃប្រឌិតនៅក្នុងប្រព័ន្ធអប់រំ។ | MoEYS ដឹកនាំ MLVT/MoC/MISTI/MoCFA/MPTC | រយៈពេលមធ្យម |
| | | **សកម្មភាព២.២០** : បណ្តុះបណ្តាលគ្រូបង្គោលនិងពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រសួង មន្ទីររាជធានី ខេត្តពាក់ព័ន្ធ ដើម្បីផ្តល់សេវា និងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា សម្រាប់ការអភិវឌ្ឍវិស័យអប់រំនិងចំណេះដឹងសាធារណៈ។ | MoEYS ដឹកនាំ MLVT/MoC/MISTI/MoCFA | រយៈពេលវែង |
| | | **សកម្មភាព២.២១** : បណ្តុះបណ្តាលគ្រូបង្គោល និងរៀបចំនិងបញ្ចូលកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញាសម្រាប់វិទ្យាស្ថាននិងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត។ | MLVT/MoC ដឹកនាំ MISTI/MoCFA/MoEYS | រយៈពេលវែង |
| | | **សកម្មភាព២.២២** : រៀបចំការបណ្តុះបណ្តាលមុខវិជ្ជាកម្មសិទ្ធិបញ្ញាសម្រាប់បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា សាលាភូមិន្ទរដ្ឋបាល និងបណ្ឌិត្យសភានគរបាលកម្ពុជា។ | MoJ/MoI ដឹកនាំ MoC/MISTI/MoCFA | រយៈពេលវែង |
| | | **សកម្មភាព២.២៣** : រៀបចំវគ្គបណ្តុះបណ្តាលពីចម្ងាយស្តីពីសញ្ញាណទូទៅនៃកម្មសិទ្ធិបញ្ញា។ | MoEYS/MoC ដឹកនាំ MISTI/MoCFA/MLVT | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព២.២៤** : រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា វិធានការបច្ចេកវិទ្យា និងការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា។ | MoC/MISTI/<br>MoCFA ដឹកនាំ<br>MoI/MoJ | រយៈពេលវែង |
| | | **សកម្មភាព២.២៥** : រៀបចំកម្មវិធីសិក្សានិងឯកសារបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដែលរួមបញ្ចូលករណីសិក្សា និងលិខិតបទដ្ឋានគតិយុត្តនៃការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា សម្រាប់តុលាការ មន្ត្រីទទួលបន្ទុកអនុវត្តច្បាប់ និងភាគីពាក់ព័ន្ធ។ | MoJ/MoC ដឹកនាំ<br>MoI/MISTI/MoCFA/<br>MEYS/MLVT | រយៈពេលមធ្យម |
| | | **សកម្មភាព២.២៦** : រៀបចំនិងបញ្ចូលកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញាតាមជំនាញ ដូចជាច្បាប់ ធុរកិច្ចជាដើម សម្រាប់គ្រឹះស្ថាន អប់រំថ្នាក់ឧត្តមសិក្សានិងក្រោយឧត្តមសិក្សា និងវិក្រឹតការ។ | MoEYS/MoC ដឹកនាំ<br>MISTI/MoCFA/MLVT | រយៈពេលមធ្យម |
| | | **សកម្មភាព២.២៧** : រៀបចំនិងបញ្ចូលកម្មវិធីសិក្សាកម្មសិទ្ធិបញ្ញាសម្រាប់គ្រឹះស្ថានអប់រំកម្រិតមធ្យមសិក្សាចំណេះទូទៅ។ | MoEYS/MoC ដឹកនាំ<br>MISTI/MoCFA | រយៈពេលវែង |
| | | **សកម្មភាព២.២៨** : រៀបចំនិងបញ្ចូលកម្មវិធីសិក្សាមុខវិជ្ជាកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងគោលគំនិតបច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ វិទ្យាស្ថានពាក់ព័ន្ធបច្ចេកវិទ្យា វិទ្យាសាស្ត្រ សុខាភិបាល វិស្វកម្ម និងស្ថាប័នពាក់ព័ន្ធ។ | MISTI ដឹកនាំ<br>MoC/MoCFA/<br>MoEYS/MLVT/MPTC | រយៈពេលមធ្យម |
| | បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា។ | **សកម្មភាព២.២៩** : បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញារបស់ព្រះរាជាណាចក្រកម្ពុជា។ | MoC ដឹកនាំ<br>MISTI/MoCFA/MoEYS | រយៈពេលមធ្យម |
| | | **សកម្មភាព២.៣០** : បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញារបស់អាស៊ាន។ | MoC ដឹកនាំ<br>MISTI/MoCFA/<br>MoEYS | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព២.៣១** : រៀបចំប្រព័ន្ធអេឡិចត្រូនិកសម្រាប់ការបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញាពីចម្ងាយ លើមុខវិជ្ជាកម្មសិទ្ធិបញ្ញាកម្រិតបឋម មធ្យម និងកម្រិតខ្ពស់។ | MoC ដឹកនាំ MISTI/MoCFA/ MoEYS | រយៈពេលវែង |
| | | **សកម្មភាព២.៣២** : សិក្សានិងអនុវត្តការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា និងប្រើប្រាស់បច្ចេកវិទ្យាសម្រាប់បង្កើតវិធីសាស្ត្របណ្តុះបណ្តាល និងអភិវឌ្ឍការអប់រំកម្មសិទ្ធិបញ្ញានៅតាមបណ្តាគ្រឹះស្ថានអប់រំ និងស្ថាប័នពាក់ព័ន្ធ។ | MoEYS ដឹកនាំ MoC/MISTI/MoCFA | រយៈពេលមធ្យម |
| **សុខាភិបាល** | ពង្រឹងសមត្ថភាពមន្ត្រីក្រសួងសុខាភិបាល មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ អំពីសុខភាពសាធារណៈ និងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា។ | **សកម្មភាព២.៣៣** : បង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹង អង្គភាពកម្មសិទ្ធិបញ្ញាជាតិនិងអន្តរជាតិ មន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងម្ចាស់សិទ្ធិ ដើម្បីធ្វើការតាមដាន ពិនិត្យ និងចាត់វិធានការតឹងរ៉ឹង ដើម្បីទប់ស្កាត់និងលុបបំបាត់ការផលិតនិងចរាចរណ៍ផលិតផលឱសថក្លែងក្លាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ | MoH/MoI ដឹកនាំ MoC/MISTI | រយៈពេលមធ្យម |
| | | **សកម្មភាព២.៣៤** : ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងនៃក្រសួងសុខាភិបាល ដោយផ្តល់ការបណ្តុះបណ្តាលអំពីកម្មសិទ្ធិបញ្ញា។ | MoH ដឹកនាំ MoC/MISTI | រយៈពេលមធ្យម |
| | ទាញយកប្រយោជន៍ពីភាពអនុគ្រោះក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ដែលផ្តល់ការអនុគ្រោះដល់ប្រទេសអភិវឌ្ឍតិចតួចទាក់ទងនឹងផលិតផលឱសថក្រោមប្រកាសនីយបត្រតក្កកម្ម។ | **សកម្មភាព២.៣៥** : បង្កើតនូវបណ្តាញទំនាក់ទំនងជិតស្និទ្ធរវាងរដ្ឋាភិបាលនិងវិស័យឯកជន ដើម្បីទាញយកប្រយោជន៍អំពីមាតិកាអភិវឌ្ឍន៍ទីក្រុងដូហា និងភាពបត់បែននៃកិច្ចព្រមព្រៀងTRIPs ដែលផ្តល់សិទ្ធិឱ្យកម្ពុជា មិនការពារលើផលិតផលឱសថ ក្រោមប្រកាសនីយបត្រតក្កកម្ម និងការចេញអាជ្ញាបណ្ណបញ្ចាសម្រាប់សុខភាពសាធារណៈ។ | MoH ដឹកនាំ MoC/MISTI | រយៈពេលវែង |
| | | **សកម្មភាព២.៣៦** : ពិនិត្យនិងស្រាវជ្រាវព័ត៌មានទីផ្សារអំពីផលិតផលឱសថក្រោមប្រកាសនីយបត្រតក្កកម្ម និងឱសថទូទៅ ដទៃទៀត | MoH ដឹកនាំ MoC/MISTI/MFA.IC | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | ដែលព្រះរាជាណាចក្រកម្ពុជាមានតម្រូវការចាំបាច់ រួចធ្វើការផ្តល់យោបល់ឬលើកសំណើ ក្នុងករណីចាំបាច់ ត្រូវរៀបចំកែសម្រួលច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីអាចទទួលបានផលិតផលឱសថទាំងនេះក្នុងតម្លៃសមស្រប។ | | |
| **ពាណិជ្ជកម្មនិងឧស្សាហកម្ម** | កសាងសមត្ថភាពមន្ត្រីទទួលបន្ទុកកម្មសិទ្ធិបញ្ញា និងភ្នាក់ងារកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់ប្រឹក្សាយោបល់និងគាំទ្រសហគ្រាសធុនមីក្រូ តូច និងមធ្យម និងជំរុញការប្រើប្រាស់ប្រព័ន្ធទិន្នន័យកម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម។ | **សកម្មភាព២.៣៧** : រៀបចំវេទិកាគោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា ទិវាកម្មសិទ្ធិបញ្ញាពិភពលោក និងវេទិកាជជែកពិភាក្សាអំពីកម្មសិទ្ធិបញ្ញា និងព្រឹត្តិការណ៍កម្មសិទ្ធិបញ្ញាផ្សេងៗ។ | MoC/MISTI/ MoCFA ដឹកនាំ MoEYS/MPTC/MoH/ MLVT/MoInfo/MoJ | រយៈពេលវែង |
| | | **សកម្មភាព២.៣៨** : កសាងសមត្ថភាពដល់មន្ត្រីទទួលបន្ទុកកម្មសិទ្ធិបញ្ញា ភ្នាក់ងារកម្មសិទ្ធិបញ្ញា និងគ្រូបង្គោលនៃក្រសួងស្ថាប័ន មន្ទីរពាក់ព័ន្ធ ដើម្បីផ្តល់ការគាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីបង្កើនភាពប្រកួតប្រជែង ។ | MoC ដឹកនាំ MISTI/MoCFA/ MoEYS/MPTC/ MoH/MLVT/ MoInfo/MoJ/MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព២.៣៩** : រៀបចំវគ្គបណ្តុះបណ្តាលទៀងទាត់ស្តីពីនីតិវិធីនៃការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ការចុះបញ្ជីម៉ាក និងស្នាដៃសិទ្ធិអ្នកនិពន្ធ។ | MoC/MISTI/ MoCFA ដឹកនាំ | រយៈពេលមធ្យម |
| | | **សកម្មភាព២.៤០** : បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ក្នុងការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា ដើម្បីបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់ចំពោះផលិតផលនិងសេវាកម្មរបស់ព្រះរាជាណាចក្រកម្ពុជា។ | MoC/MoJ/MOI ដឹកនាំ MISTI/MoCFA/MoT/ MoInfo | រយៈពេលមធ្យម |
| | អភិវឌ្ឍសមត្ថភាពនិងស្ថាប័នរបស់អង្គភាពកម្មសិទ្ធិបញ្ញា និងស្ថាប័នអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការប្រើប្រាស់ | **សកម្មភាព២.៤១** : អភិវឌ្ឍភាពជាដៃគូជាមួយអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប.) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ | MoC/MoJ/MOI ដឹកនាំ MISTI/MoCFA/ MoT/MEF | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | ប្រព័ន្ធទិន្នន័យកម្មសិទ្ធិបញ្ញាអន្តរជាតិ អំពីព័ត៌មានប្រកាសនីយបត្រតក្កកម្ម និងព័ត៌មានបច្ចេកវិទ្យាដទៃទៀត។ | និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងតុលាការ ក្នុងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីទប់ស្កាត់ការនាំចេញ នាំចូល ការបាចរទំនិញក្លែងក្លាយនៅលើទីផ្សារ និងការថតចម្លងខុសច្បាប់។ | | |
| | | **សកម្មភាព១២.៤២** : លើកកម្ពស់ប្រព័ន្ធគ្រប់គ្រងរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសមត្ថភាពមន្ត្រីត្រួតពិនិត្យប្រកាសនីយបត្រតក្កកម្ម។ | MISTI ដឹកនាំ<br>MoC/MoCFA | រយៈពេលមធ្យម |
| | | **សកម្មភាព១២.៤៣** : ផ្តល់ការគាំទ្រដល់សហគ្រិន វិស្វករ អ្នកស្រាវជ្រាវ តក្កករ និងភាគីដែលពាក់ព័ន្ធ ក្នុងការកំណត់តក្កកម្មថ្មីសម្រាប់ធ្វើការចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម។ | MISTI ដឹកនាំ<br>MoC/MoCFA/MoEYS/<br>MPTC/MLVT/MoInfo | រយៈពេលវែង |
| | | **សកម្មភាព១២.៤៤** : កសាងសមត្ថភាពមន្ត្រីទទួលបន្ទុក និងជំរុញការប្រើប្រាស់មជ្ឈមណ្ឌលគាំទ្រព័ត៌មានវិទ្យាដែលបានបង្កើតនៅតាមបណ្តាសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។ | MoC/MISTI ដឹកនាំ<br>MoCFA/MoEYS/<br>MPTC/MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព១២.៤៥** : ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកកម្មសិទ្ធិបញ្ញា ដើម្បីជួយផ្តល់ការគាំទ្រសហគ្រិន វិស្វករ អ្នកស្រាវជ្រាវ តក្កករ និងភាគីពាក់ព័ន្ធអាចចូលទៅកាន់ព័ត៌មានប្រកាសនីយបត្រតក្កកម្ម ដើម្បីធ្វើវិស្វកម្មបំបែកនិងផ្គុំ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាស្របច្បាប់ដែលមានស្រាប់សម្រាប់អភិវឌ្ឍផលិតផលរបស់ពួកគេ។ | MISTI ដឹកនាំ<br>MoC/MoCFA/MoEYS/<br>MPTC/MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព១២.៤៦** : បង្កើតប្រព័ន្ធគ្រប់គ្រងសម្រាប់គាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម និងក្រុមហ៊ុនដែលទើបបង្កើតថ្មី និងតក្កករ ឬអ្នកច្នៃប្រឌិត ក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីភ្ញាស់គំនិតអាជីវកម្ម បង្កើនប្រវាក់តម្លៃ ប្រវាក់ផ្គត់ផ្គង់ ដើម្បីកាត់ | MISTI ដឹកនាំ<br>MoC/MoCFA/MoEYS/<br>MPTC/MLVT/MoInfo/<br>MoWA | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | បន្ថយថ្លៃដើមនិងចំណាយប្រតិបត្តិការ និងបង្កើនផលិតភាព ដើម្បីអាចធ្វើពាណិជ្ជកម្មបាន។ | | |
| | | **សកម្មភាព២.៤៧** : បង្កើតមជ្ឈមណ្ឌលផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា ដែលតភ្ជាប់ជាមួយប្រព័ន្ធ ទិន្នន័យកម្មសិទ្ធិបញ្ញាអន្តរជាតិ និងពង្រឹងសមត្ថភាពរបស់មន្ត្រីអង្គភាពកម្មសិទ្ធិបញ្ញាក្នុងការផ្តល់សេវា និងប្រឹក្សាយោបល់ ក្នុងការប្រើប្រាស់ព័ត៌មានកម្មសិទ្ធិបញ្ញាសម្រាប់ការអភិវឌ្ឍអាជីវកម្ម។ | MISTI/MoC ដឹកនាំ<br>MoCFA/MoEYS/<br>MPTC/MLVT/<br>MoInfo/MoWA | រយៈពេលមធ្យម |
| | ទាក់ទាញការវិនិយោគ និងបង្កើតនីតិវិធីគាំទ្រការផ្តល់ហិរញ្ញប្បទាន និងមូលនិធិសម្រាប់បង្កើតនិងធ្វើពាណិជ្ជកម្មផលិតផលកម្មសិទ្ធិបញ្ញា។ | **សកម្មភាព២.៤៨** : សម្របសម្រួលជាមួយធនាគារអភិវឌ្ឍន៍ជនបទ ធនាគារសហគ្រាសធុនមីក្រូ តូច និងមធ្យម ស្ថាប័នហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍនានា ក្នុងការផ្តល់ហិរញ្ញប្បទាននិងប្រាក់កម្ចីដែលមានការប្រាក់ទាប ដែលធានានូវហានិភ័យដល់ម្ចាស់កម្មសិទ្ធិបញ្ញា តក្កករ ឬអ្នកច្នៃប្រឌិត រួមទាំងកសិករ អ្នកតម្បាញ សិប្បករ សិប្បករ ចម្លាក់ សិប្បករសិល្បៈ ផលិតករ ប្រតិបត្តិករម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម និងលើកទឹកចិត្តដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ជាពិសេសក្រុមហ៊ុនដែលទើបបង្កើតថ្មី។ | MEF ដឹកនាំ<br>MoC/MISTI/<br>MoCFA/MoEYS/<br>MPTC/MLVT/<br>MoInfo/MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព២.៤៩** : ជំរុញការផ្តល់មូលនិធិសម្រាប់សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍ និងការរួមទុនជាមួយនឹងវិស័យឯកជនក្នុងការស្រាវជ្រាវនិងការអភិវឌ្ឍ។ | MEF/MISTI ដឹកនាំ<br>MoEYS/MLVT/<br>MoC /MFA.IC | រយៈពេលវែង |
| | | **សកម្មភាព២.៥០** : ជួយសម្របសម្រួលការវិនិយោគលើវិស័យកម្មសិទ្ធិបញ្ញា ក្នុងការជំរុញឧស្សាហកម្មនិងសេវាកម្ម តាមរយៈសំណើផ្តល់អាជ្ញាបណ្ណ និងការទិញយកបច្ចេកវិទ្យាកម្មសិទ្ធិបញ្ញារវាងម្ចាស់សិទ្ធិ និងអ្នកវិនិយោគ ភ្នាក់ងារផ្តល់មូលនិធិ និងអ្នកប្រើប្រាស់។ | MISTI/MoC ដឹកនាំ<br>MEF/MoEYS/<br>MLVT/MFA.IC | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព២.៥១** : សម្របសម្រួល រៀបចំនីតិវិធី និងមគ្គុទ្ទេសក៍សម្រាប់ជាជំនួយក្នុងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញារបស់ម្ចាស់សិទ្ធិ សម្រាប់ទ្រព្យតម្កល់ធានា ដើម្បីទទួលបានហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុនានា។ | MoC/MEF ដឹកនាំ MISTI/ MoCFA/MoEYS/ MLVT/MFA.IC | រយៈពេលវែង |
| **ទេសចរណ៍** | អភិវឌ្ឍនិងកសាងសមត្ថភាពមន្ត្រីទទួលបន្ទុក មន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា វិស័យឯកជនពាក់ព័ន្ធ និងជំរុញការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីធ្វើឱ្យប្រសើរឡើងដល់វិស័យទេសចរណ៍។ | **សកម្មភាព២.៥២** : បណ្តុះបណ្តាលភ្នាក់ងារកម្មសិទ្ធិបញ្ញានិងវិស័យឯកជន ពាក់ព័ន្ធលើប្រធានបទកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់ការគាំទ្រក្នុងការអភិវឌ្ឍនិងការអនុវត្តគោលដៅទេសចរណ៍។ | MoT/MoC/MISTI/ MoCFA ដឹកនាំ MoI/MoJ/MoEYS/ MLVT/MoInfo | រយៈពេលវែង |
| | | **សកម្មភាព២.៥៣** : បណ្តុះបណ្តាលគ្រូបង្គោល និងពង្រឹងសមត្ថភាពមន្ត្រីរបស់ក្រសួង មន្ទីររាជធានី ខេត្តគោលដៅ នគរបាលទេសចរណ៍ និងមន្ត្រីអនុវត្តច្បាប់លើមុខវិជ្ជាកម្មសិទ្ធិបញ្ញា ដើម្បីផ្តល់សេវាប្រឹក្សាយោបល់និងជំនួយបច្ចេកទេសពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍។ | MoT/MoC/MISTI/ MoCFA ដឹកនាំ MoI/MoJ/MoEYS/ MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព២.៥៤** : រៀបចំការបណ្តុះបណ្តាលស្តីពីបដិសណ្ឋារកិច្ចការផ្តល់សេវា និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដល់សមាគម និងភាគីពាក់ព័ន្ធ ដើម្បីប្រើប្រាស់ផលិតកម្មនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាព ឱ្យប្រែក្លាយជាគោលដៅទេសចរណ៍។ | MoC/MoT ដឹកនាំ MISTI/MoCFA/MoI/ MoJ/MoEYS/ MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព២.៥៥** : ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីពង្រឹងសមត្ថភាពរបស់ភ្នាក់ងារទេសចរណ៍ និងភាគីពាក់ព័ន្ធក្នុងការធ្វើឱ្យប្រសើរឡើងសេវាកម្មទេសចរណ៍។ | MoT/MoC ដឹកនាំ MISTI/MoCFA/ MoInfo/MoWA | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព២.៥៦** : រៀបចំយុទ្ធសាស្ត្រនិងជំរុញការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីបង្កើនទំនុកចិត្តរបស់អ្នកប្រើប្រាស់ ទៅលើគុណភាព ភាពជឿជាក់ ភាពត្រឹមត្រូវ និងយថាភាពនៃសេវាកម្ម និងផលិតផលទេសចរណ៍។ | MoC/MoT/MoI ដឹកនាំ MoCFA/MoJ/ MISTI/MoInfo | រយៈពេលមធ្យម |
| | រៀបចំយុទ្ធសាស្ត្រក្នុងការកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យក្លាយទៅជាគោលដៅទេសចរណ៍ រួមទាំងការការពារម៉ាកនេះនៅក្នុងទីផ្សារសំខាន់ៗ។ | **សកម្មភាព២.៥៧** : រៀបចំយុទ្ធនាការផ្សព្វផ្សាយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម និងកសាងកេរ្តិ៍ឈ្មោះផលិតផលខ្មែរ ឱ្យក្លាយជាគោលដៅទេសចរណ៍។ | MoT/MoC ដឹកនាំ MISTI/MoCFA/ MoEYS/MoInfo | រយៈពេលវែង |
| | | **សកម្មភាព២.៥៨** : ស្រាវជ្រាវការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និងម៉ាកសមូហភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍស្តង់ដាគុណភាពដោយឧស្សាហកម្មទេសចរណ៍។ | MoC/MoT ដឹកនាំ MISTI/MoCFA/ MoEYS/MoInfo | រយៈពេលមធ្យម |
| **វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា** | លើកកម្ពស់សមត្ថភាពរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងវិស័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ | **សកម្មភាព២.៥៩** : អនុវត្តតួនាទីសម្របសម្រួលផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ | MISTI ដឹកនាំ MoC/MoCFA/ MoEYS/MLVT/MPTC | រយៈពេលវែង |
| | | **សកម្មភាព២.៦០** : ជំរុញការបង្កើតផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកជំនាញ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍនៅតាមបណ្តាក្រុមហ៊ុនគោលដៅ។ | MoC/MISTI ដឹកនាំ MoCFA/MoEYS/ MLVT/MPTC | រយៈពេលវែង |
| | | **សកម្មភាព២.៦១** : ជំរុញការអប់រំកម្មសិទ្ធិបញ្ញា ការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញា និងដកស្រង់បទពិសោធពីឧត្តមានុវត្តន៍ របស់ប្រទេសអភិវឌ្ឍសម្រាប់អភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ ព័ត៌មានវិទ្យា សេដ្ឋកិច្ច សង្គមឌីជីថលកម្ពុជា។ | MoEYS/MISTI/ MPTC ដឹកនាំ MoC/MoCFA/MLVT | រយៈពេលវែង |
| | | **សកម្មភាព២.៦២** : ជំរុញកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យនិងវិស័យឯកជន ដើម្បីស្រាវជ្រាវនិងអភិវឌ្ឍរួមគ្នា និងជំរុញការ | MISTI/ MoEYS/ MLVT ដឹកនាំ | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | ប្រើប្រាស់តក្កកម្មបើកចំហ ដើម្បីបង្កើតផលិតផលថ្មី។ | MoC/MoCFA/ MPTC/MAFF | |
| | | **សកម្មភាព២.៦៣** : លើកកម្ពស់ទិន្នផលកម្មសិទ្ធិបញ្ញា នៅតាមមន្ទីរពិសោធន៍ សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យា។ | MISTI/MoEYS/MLVT ដឹកនាំ MoC/MoCFA/ MPTC/MAFF | រយៈពេលវែង |
| | | **សកម្មភាព២.៦៤** : ផ្តល់មគ្គុទេសក៍សម្រាប់ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍអំពីវិស័យអាទិភាពរបស់ជាតិ ដូចជាចំណីអាហារ កសិកម្ម សុខុមាលភាព ថាមពល ជីវបច្ចេកវិទ្យា បច្ចេកវិទ្យាណាណូ បច្ចេកវិទ្យាព័ត៌មានវិទ្យា។ | MISTI/MPTC/ MAFF ដឹកនាំ MoC/MoCFA/MoH/ MLVT/MoEYS | រយៈពេលខ្លី |
| | បង្កើតយន្តការរួមគ្នារវាងសាកលវិទ្យាល័យនិងវិស័យឯកជន ដើម្បីប្រើប្រាស់ ប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងការស្រាវជ្រាវ ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យា។ | **សកម្មភាព២.៦៥** : ជំរុញកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ និងវិស័យឯកជន ដើម្បីស្រាវជ្រាវនិងអភិវឌ្ឍផលិតផលបច្ចេកវិទ្យា។ | MISTI/MoEYS/ MLVT ដឹកនាំ MoC/MPTC/MAFF | រយៈពេលវែង |
| | | **សកម្មភាព២.៦៦** : បង្កើតកិច្ចសន្យាគំរូ ដែលមានខ្លឹមសារបញ្ជាក់អំពីគោលបំណង ស្តង់ដា យថាប្រភេទ ការបែងចែកផលប្រយោជន៍ ការទទួលខុសត្រូវ ដើម្បីផ្តល់ជាមគ្គុទ្ទេសក៍ និងជួយសម្រួលក្នុងដំណើរការនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ និងវិស័យឯកជន។ | MISTI/MoEYS/ MLVT ដឹកនាំ MoC/MoCFA/ MPTC/MAFF | រយៈពេលខ្លី |
| | | **សកម្មភាព២.៦៧** : បង្កើតការិយាល័យផ្ទេរបច្ចេកវិទ្យាជាតិ ដើម្បីគ្រប់គ្រងលទ្ធផលនៃការស្រាវជ្រាវរបស់គ្រឹះស្ថានអប់រំឧត្តមសិក្សា និងស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍពាក់ព័ន្ធ។ | MISTI/MoEYS/ MLVT ដឹកនាំ MoC/MoCFA/MPTC | រយៈពេលមធ្យម |

| គំនិតផ្តួចផ្តើមគន្លឹះ | | | |
|---|---|---|---|
| បង្កើតមជ្ឈមណ្ឌលច្នៃប្រឌិតនិងផ្តល់ព័ត៌មានកម្មសិទ្ធិបញ្ញា ដើម្បីជួយដល់ភាគីពាក់ព័ន្ធនិងអ្នកប្រើប្រាស់សក្តានុពលនៃប្រព័ន្ធកម្មសិទ្ធិបញ្ញា ក្នុងការទទួលបានសេវាប្រឹក្សាយោបល់កម្មសិទ្ធិបញ្ញា ការស្វែងរកប្រព័ន្ធទិន្នន័យកម្មសិទ្ធិបញ្ញា រួមទាំងបច្ចេកវិទ្យាបៃតង និងការទទួលបានឯកសារកម្មសិទ្ធិបញ្ញា។ | **សកម្មភាព២.៦៨** : រៀបចំមជ្ឈមណ្ឌលផ្តល់ព័ត៌មាននិងពិគ្រោះយោបល់កម្មសិទ្ធិបញ្ញា និងបន្តការគាំទ្រដល់វិស័យឯកជននិងសាធារណជន តាមរយៈការផ្តល់ការពិគ្រោះយោបល់នៅអង្គភាពកម្មសិទ្ធិបញ្ញា និងតាមប្រព័ន្ធអនឡាញ និងផ្តល់ការបណ្តុះបណ្តាលនានា។ | MoC/MISTI ដឹកនាំ MoCFA/MoEYS/ MLVT/MPTC/MoE | រយៈពេលមធ្យម |
| | **សកម្មភាព២.៦៩** : រៀបចំមជ្ឈមណ្ឌលគាំពារព័ត៌មានបច្ចេកវិទ្យា និងកន្លែងពិគ្រោះយោបល់កម្មសិទ្ធិបញ្ញា សម្រាប់ការគាំទ្របច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្រសួង ស្ថាប័ន សាកលវិទ្យាល័យ វិទ្យាស្ថានអភិវឌ្ឍន៍នានា និងនៅតាមបណ្តារាជធានី ខេត្តគោលដៅ។ | MoC/MISTI ដឹកនាំ MoCFA/MoEYS/ MLVT/MPTC | រយៈពេលមធ្យម |
| | **សកម្មភាព២.៧០** : រៀបចំសារមន្ទីរកម្មសិទ្ធិបញ្ញានិងសាលប្រារព្ធកម្មវិធីកម្មសិទ្ធិបញ្ញា សម្រាប់ផលិតផលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងផលិតផលកម្មសិទ្ធិបញ្ញាដទៃទៀត ។ | MEF/MoC/ MISTI ដឹកនាំ MoCFA/MoEYS/ MLVT/MPTC | រយៈពេលមធ្យម |
| ពង្រឹងសមត្ថភាពរបស់អង្គភាពទទួលបន្ទុកកម្មសិទ្ធិបញ្ញាក្នុងការកែលម្អប្រព័ន្ធរដ្ឋបាលនិងគ្រប់គ្រងនិងលើកកម្ពស់សមត្ថភាពមន្ត្រីក្នុងការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រកម្មសិទ្ធិបញ្ញាសម្រាប់លើកកម្ពស់វិទ្យាសាស្ត្រនិងនវានុវត្តន៍។ | **សកម្មភាព២.៧១** : ពង្រឹងសមត្ថភាពនិងលទ្ធភាពនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែលនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីកែលម្អដំណើរការនៃការដាក់ពាក្យស្នើសុំចុះបញ្ជីកម្មសិទ្ធិបញ្ញារួមទាំងបញ្ចូលជំនាញអភិវឌ្ឍន៍គោលនយោបាយក្នុងកម្មវិធីបណ្តុះបណ្តាល សម្រាប់មន្ត្រីនៃនាយកដ្ឋានទាំងបីនេះ។ | MoC/MISTI/MoCFA | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព២.៧២** : កសាងសមត្ថភាពមន្ត្រីត្រួតពិនិត្យប្រកាសនីយបត្រតក្កកម្ម ហើយគាំទ្រដល់សហគ្រិន វិស្វករ អ្នកស្រាវជ្រាវ តក្កករនិងភាគីដែលពាក់ព័ន្ធក្នុងការកំណត់តក្កកម្មដែលអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម ដើម្បីជួយឧស្សាហកម្មក្នុងស្រុក ក្នុងការកំណត់គំនិតច្នៃប្រឌិត តក្កកម្មថ្មី ដែលអាចចុះបញ្ជីប្រកាសនីយបត្រតក្កកម្មបាន។ | MISTI ដឹកនាំ MoC/MoEYS/ MLVT/MPTC | រយៈពេលមធ្យម |

**គោលដៅទី៣៖**

ការផ្សព្វផ្សាយនិងលើកកម្ពស់ចំណេះដឹងសាធារណៈ អំពីការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីជំរុញវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។

| វិស័យ | គំនិតផ្តួចផ្តើម | សកម្មភាពដែលបានស្នើឡើង | ក្រសួងអនុវត្តចម្បង/រួម | រយៈពេល |
|---|---|---|---|---|
| កសិកម្ម | ជំរុញការចុះបញ្ជីនិងការកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលកសិកម្ម វត្ថុប្រមាញ់ និងនេសាទ ដែលមានសក្តានុពលរបស់ព្រះរាជាណាចក្រកម្ពុជា។ | **សកម្មភាព៣.១** : សហការជាមួយនឹងកសិករ សហគមន៍កសិកម្ម និងក្រុមហ៊ុន ក្នុងការចុះបញ្ជីម៉ាកសម្រាប់ផលិតផលកសិកម្ម វត្ថុប្រមាញ់ និងនេសាទរបស់ពួកគេ ដើម្បីជំរុញផលិតផលទាំងនេះនៅលើទីផ្សារជាតិនិងអន្តរជាតិ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម។ | MAFF/MoC ដឹកនាំ MISTI/MoCFA/MoE/ MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.២** : សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមអ្នកផលិត ដើម្បីជ្រើសរើសផលិតផលកសិកម្ម វត្ថុប្រមាញ់ និងនេសាទដែលមានសក្តានុពល ដើម្បីអភិវឌ្ឍនិងកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលកសិកម្មរបស់ព្រះរាជាណាចក្រកម្ពុជានៅលើទីផ្សារជាតិនិងអន្តរជាតិ។ | MAFF/MoC ដឹកនាំ MISTI/MoCFA/MoE/ MoWA | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព៣.៣** : បណ្តុះបណ្តាលដល់កសិករ ផលិតករ តាមគោលដៅក្នុងវិស័យកសិកម្ម ដើម្បីបង្កើនចំណេះដឹងនិងជំនាញអំពីវិធីសាស្ត្រកសាងកេរ្តិ៍ឈ្មោះម៉ាក ការរចនាសម្បកវេចខ្ចប់ និងការបង្កើតម៉ាក ការគ្រប់គ្រងយុទ្ធសាស្ត្រទីផ្សារ ដែលនឹងផ្តល់អត្ថប្រយោជន៍ក្នុងការធ្វើពាណិជ្ជកម្ម។ | MoC/MAFF ដឹកនាំ MISTI/MoCFA/MoE/ MoWA/MoInfo/MEF | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៤** : បង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងផ្សព្វផ្សាយអំពីផលិតផលម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម និងម៉ាកសក្តានុពលផ្សេងទៀត ដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា។ | MoC/MAFF ដឹកនាំ MISTI/MoCFA/ MoE/MoWA/MoInfo | រយៈពេលវែង |
| | លើកកម្ពស់ចំណេះដឹងសាធារណៈនិងអភិវឌ្ឍសមត្ថភាពរបស់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញាក្នុងការអភិវឌ្ឍផលិតផលនិងការពារមិនឱ្យមានការរំលោភបំពានម៉ាក។ | **សកម្មភាព៣.៥** : រៀបចំវគ្គបណ្តុះបណ្តាលអំពីនីតិវិធីនៃការចុះបញ្ជីម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម និងលើកកម្ពស់ចំណេះដឹងសាធារណៈអំពីកម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍផលិតផលកសិកម្ម វត្ថុប្រមាញ់ និងនេសាទ។ | MoC/MAFF ដឹកនាំ MISTI/MoCFA/ MoEYS/MoE/MoWA/ MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៦** : បណ្តុះបណ្តាល ផ្សព្វផ្សាយ និងជំរុញការអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិនិងផលប្រយោជន៍របស់ម្ចាស់ម៉ាក និងបង្កើនជំនឿទុកចិត្តដល់អ្នកប្រើប្រាស់ ចំពោះម៉ាកនៃផលិតផលកសិកម្មរបស់ព្រះរាជាណាចក្រកម្ពុជា។ | MAFF/MoC ដឹកនាំ MoI/MoJ/MISTI/ MoCFA/MoEYS/MoE/ MoWA/MoT/MoInfo | រយៈពេលមធ្យម |
| | ជំរុញការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកវិញ្ញាតកម្ម ម៉ាកសមូហភាព សម្រាប់ផលិតផលកសិកម្ម វត្ថុប្រមាញ់ | **សកម្មភាព៣.៧** : សិក្សានិងជំរុញការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម សម្រាប់ផលិតផលកសិកម្ម វត្ថុប្រមាញ់ និងនេសាទ និងជំរុញការប្រើប្រាស់ម៉ាកទាំងនេះ។ | MoC/MAFF ដឹកនាំ MISTI/MoCFA/MoE/ MoWA/MoInfo | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | និងនេសាទ និងផ្តល់ការគាំទ្រក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម នៅក្នុងវិស័យកសិកម្ម ។ | **សកម្មភាព៣.៨** : អភិវឌ្ឍនិងជំរុញការកសាងកេរ្តិ៍ឈ្មោះ ស្រាសកម្ពុជា រួមមានស្រាសតាកែវ ស្វាយរៀង ត្បូងឃ្មុំ ស្រាពាងមណ្ឌលគិរី។ | MoC/MAFF ដឹកនាំ MISTI/MoCFA/MoE/ MoWA/MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.៩** : អភិវឌ្ឍនិងជំរុញការកសាងកេរ្តិ៍ឈ្មោះអង្ករកម្ពុជា រួមមានអង្ករស្មោច់ស្វាយរៀង អង្ករបាត់ដំបង អង្ករនាងអំ ខេត្តក្រចេះ ។ | MoC/MAFF ដឹកនាំ MISTI/MoCFA/MoE/ MoWA/MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.១០** : អភិវឌ្ឍនិងជំរុញការកសាងកេរ្តិ៍ឈ្មោះ ផលិតផលនេសាទកម្ពុជា រួមមានបង្កងតាកែវ ប្រហុកសៀមរាប សាច់ក្រកសៀមរាប ត្រីប៉ាស៊ីអ៊ីស្ទឹងត្រែង ទឹកត្រីកំពត ទឹកត្រីកោះកុង ក្តាមកំពត ក្តាមថ្មខេត្តកោះកុង និងផលិតផលដទៃទៀត។ | MoC/MAFF ដឹកនាំ MISTI/MoCFA/MoE/ MoWA/MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.១១** : អភិវឌ្ឍនិងជំរុញការកសាងកេរ្តិ៍ឈ្មោះ ផលិតផលនិងអនុផលព្រៃឈើកម្ពុជា រួមមានផលិតផលកេសរកូលជ័រទឹក ខ្លឹមចន្ទន៍ ក្រវាញពោធិ៍សាត់ កាហ្វេមណ្ឌលគិរី ម្នាស់ទឹកឃ្មុំស្ទឹងត្រែង ទុរេនកំពត ស្វាយកម្ពុជា ចេកពងមាន់ និងមៀនកោះក្របីខេត្តកណ្តាល។ល។ | MoC/MAFF/MoE ដឹកនាំ MISTI/MoCFA/ MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.១២** : អភិវឌ្ឍនិងជំរុញការកសាងកេរ្តិ៍ឈ្មោះ ផលិតផលសូត្រកម្ពុជា រួមមានសូត្រភ្នំស្រុក សូត្រខេត្តតាកែវ ផាមួងកោះដាច់ ហូលព្រែកចង្ក្រាន ។ល។ | MoC/MAFF ដឹកនាំ MISTI/MoCFA/MoE/ MoWA/MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.១៣** : ផ្តល់ការគាំទ្រនិងបន្តការកសាងកេរ្តិ៍ឈ្មោះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដូចជាម្រេចកំពត ស្ករត្នោតកំពង់ស្ពឺ ក្រូចថ្លុងកោះទ្រង់ និងទឹកឃ្មុំព្រៃមណ្ឌលគិរី ម៉ាកសមូហភាព ដូចជាគុយទាវភ្នំពេញ នំបញ្ចុកសៀមរាប អំបុក | MoC/MAFF ដឹកនាំ MISTI/MoCFA/ MoE/MoT/MoWA/ MoInfo | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | កំពង់ធំ អង្គរព្រះវិហារ ក្រូចពោធិ៍សាត់ ចម្លាក់ប្រាក់ស្តាន់ខេត្តកណ្តាល និងស្ទូនផ្តាំងខេត្តកំពង់ឆ្នាំង។ល។ | | |
| **វប្បធម៌** | ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍផលិតផលចំណេះដឹងជាប្រពៃណី និងផលិតផលវប្បធម៌ និងពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីការពារម្ចាស់សិទ្ធិ និងបង្កើនជំនឿទុកចិត្តដល់អ្នកប្រើប្រាស់។ | **សកម្មភាព៣.១៤** : បន្តរៀបចំសិក្ខាសាលា ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត កិច្ចព្រមព្រៀងអន្តរជាតិ សន្ធិសញ្ញា អនុសញ្ញាទាក់ទងនឹងសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល។ | MoCFA ដឹកនាំ<br>MoC/MISTI/<br>MoInfo/MPTC | រយៈពេលមធ្យម |
| | | **សកម្មភាព៣.១៥** : បន្តលើកកម្ពស់ចំណេះដឹងសាធារណៈ ការអភិរក្សនិង**ការ**អភិវឌ្ឍជំនាញ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ និងគុណតម្លៃនៃការបង្ហាញវប្បធម៌នៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម។ | MoC/MoCFA ដឹកនាំ<br>MISTI/MAFF/MoH/<br>MoE/MoInfo/MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.១៦** : បន្តផ្សព្វផ្សាយនិងលើកកម្ពស់ចំណេះដឹងសាធារណៈអំពីសារៈសំខាន់នៃកម្មសិទ្ធិបញ្ញាក្នុងការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ម៉ាកសមូហភាពនៃផលិតផលវប្បធម៌ ប្រពៃណី និងកិច្ចការពារម៉ាកនិងពាណិជ្ជនាម សម្រាប់អាជ្ញាបណ្ណលើវិស័យព័ត៌មាននិងសោតទស្សន៍។ | MoC/MoCFA ដឹកនាំ<br>MISTI/MAFF/MoH/<br>MoE/MoInfo/MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.១៧** : បន្តផ្សព្វផ្សាយនិងកសាងសមត្ថភាព និងផ្តល់ការគាំទ្រដល់មន្ត្រីអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និងភាគីពាក់ព័ន្ធ ដើម្បីការពារម្ចាស់កម្មសិទ្ធិបញ្ញា និងផ្តល់ទំនុកចិត្តដល់អ្នកប្រើប្រាស់ផលិតផលវប្បធម៌ ប្រពៃណី។ | MoC/MoCFA ដឹកនាំ<br>MISTI/MAFF/MoH/<br>MoE/MoInfo/MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.១៨** : រៀបចំកិច្ចប្រជុំពិគ្រោះយោបល់នៅតាមបណ្តារាជធានី ខេត្តពាក់ព័ន្ធជាមួយនឹងអាជីវករ កសិករ អ្នកប្រើប្រាស់ពូជដំណាំ សហគមន៍ដែលជាម្ចាស់ ចំណេះដឹងជាប្រពៃណី វិញ្ញត្តិវប្បធម៌ អ្នករចនា ជាងចម្លាក់ និងភាគីពាក់ព័ន្ធ ដើម្បីកំណត់អំពីតម្រូវការនិងបញ្ហាប្រឈម។ | MoC/MoCFA ដឹកនាំ<br>MISTI/MAFF/MoH/<br>MoE/MoInfo/MoWA | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព៣.១៩** : រៀបចំយុទ្ធសាស្ត្រនិងយន្តការត្រួតពិនិត្យ ដើម្បីបង្កើនជំនឿទុកចិត្តដល់អ្នកប្រើប្រាស់ ចំពោះយថាភាពនៃវិញ្ញត្តិវប្បធម៌ និងផលិតផលចំណេះដឹងជាប្រពៃណី។ | MoCFA ដឹកនាំ MoC/MISTI/MAFF/ MoH/MoE/MoInfo/ MoT/MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព៣.២០** : ត្រួតពិនិត្យការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកវិញ្ញាតកម្ម និងម៉ាកសមូហភាព ដើម្បីការពារអត្តសញ្ញាណវប្បធម៌ និងគុណតម្លៃទាក់ទងនឹងការសម្តែងវប្បធម៌ និងផលិតផលវប្បធម៌ប្រពៃណី។ | MoC/MoCFA ដឹកនាំ MISTI/MAFF/MoH/ MoE/MoT | រយៈពេលវែង |
| | រៀបចំយុទ្ធសាស្ត្រនិងប្រព័ន្ធត្រួតពិនិត្យដើម្បីលើកកម្ពស់កិច្ចការពារចំណេះដឹងជាប្រពៃណីនិងវិញ្ញត្តិវប្បធម៌។ ជំរុញការចូលទៅកាន់ប្រព័ន្ធទិន្នន័យសិទ្ធិអ្នកនិពន្ធ សម្រាប់ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល។ | **សកម្មភាព៣.២១** : ជំរុញការប្រើប្រាស់ដោយសេរីនូវកម្មវិធីប្រភពបើកចំហ ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ។ | MoCFA/MISTI/ MPTC ដឹកនាំ MoC/MAFF/MoH/ MoE/MoInfo/MoT/ MoEYS/MLVT | រយៈពេលមធ្យម |
| | | **សកម្មភាព៣.២២** : អភិវឌ្ឍនិងកសាងសមត្ថភាពក្នុងការចូលទៅកាន់ប្រព័ន្ធនិងបណ្តាញឌីជីថល ដើម្បីប្រើប្រាស់ទិន្នន័យសិទ្ធិអ្នកនិពន្ធផ្សេងៗ សម្រាប់អភិវឌ្ឍផលិតផលវៃឆ្លាតសិប្បនិម្មិត និងសហការលុបបំបាត់ការរំលោភបំពានស្នាដៃសិទ្ធិអ្នកនិពន្ធតាមប្រព័ន្ធអ៊ីនធឺណិត។ | MoCFA/MISTI/ MPTC ដឹកនាំ MoC/MoI/MoJ/ MoInfo/MoEYS | រយៈពេលវែង |
| **អប់រំនិងការលើកកម្ពស់ចំណេះដឹងសាធារណៈ** | លើកកម្ពស់សមត្ថភាពសាកលវិទ្យាល័យ និងវិស័យឯកជន ក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍផលិតផលបច្ចេកវិទ្យា។ | **សកម្មភាព៣.២៣** : ផ្តល់ការបណ្តុះបណ្តាលលើមុខវិជ្ជាវាយតម្លៃកម្មសិទ្ធិបញ្ញា ជូនដល់សាស្ត្រាចារ្យ គ្រូបង្រៀន សិស្សនិស្សិតនៅតាមគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សាសម្រាប់ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ និងទាញយកផលប្រយោជន៍សេដ្ឋកិច្ច។ | MoEYS/MISTI ដឹកនាំ MoC/MoCFA/MAFF MPTC/MLVT | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព៣.២៤** : ផ្តល់ការបណ្តុះបណ្តាលនិងអភិវឌ្ឍជំនាញជូនដល់សាស្ត្រាចារ្យ គ្រូបង្រៀន សិស្ស និស្សិត អ្នកស្រាវជ្រាវ និងការអភិវឌ្ឍនៅតាមបណ្តាគ្រឹះស្ថានអប់រំ និងស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងការប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ។ | MISTI/MoEYS ដឹកនាំ MoC/MoCFA/MAFF/ MPTC/MLVT | រយៈពេលវែង |
| | | **សកម្មភាព៣.២៥** : រៀបចំការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឧបករណ៍កម្មសិទ្ធិបញ្ញា ដើម្បីលើកកម្ពស់សហគ្រាសធុនមីក្រូ តូច និងមធ្យម។ | MoC/MISTI/ MoCFA ដឹកនាំ MoEYS/MAFF/MEF/ MLVT/MoInfo/MoWA | រយៈពេលមធ្យម |
| | | **សកម្មភាព៣.២៦** : ផ្សព្វផ្សាយឯកសារទាក់ទងនឹងកម្មសិទ្ធិបញ្ញា និងលើកកម្ពស់ចំណេះដឹងសាធារណៈ អំពីសារៈសំខាន់កម្មសិទ្ធិបញ្ញា ក្នុងគោលបំណងជំរុញការអភិវឌ្ឍវិទ្យាសាស្ត្របច្ចេកវិទ្យា។ | MISTI ដឹកនាំ MoC/MoCFA/MPTC/ MoEYS/MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.២៧** : រៀបចំផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញា និងបង្កើតគោលការណ៍ត្រួតពិនិត្យ និងគ្រប់គ្រងលទ្ធផលស្រាវជ្រាវរួមជាមួយវិស័យឯកជន និងកម្មវិធីសិក្ខាសាលាជាទៀងទាត់សម្រាប់និស្សិតវិស្វកម្មនិងវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវទាក់ទងកម្មសិទ្ធិបញ្ញា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា វិទ្យាស្ថានបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា វិទ្យាស្ថានជាតិពហុបច្ចេកទេសព្រះកុសមៈ និងវិទ្យាស្ថានពាក់ព័ន្ធ។ | MISTI/MoEYS/ MLVT ដឹកនាំ MoC/MPTC/MAFF | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | រៀបចំនិងផ្សព្វផ្សាយឯកសារកម្មសិទ្ធិបញ្ញា និងកសាងសមត្ថភាពភ្នាក់ងារកម្មសិទ្ធិបញ្ញា ក្នុងការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញា សម្រាប់ការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍ ផលិតផលបច្ចេកវិទ្យា។ | **សកម្មភាព៣.២៨** : បកប្រែជាភាសាខ្មែរនិងបោះពុម្ពកិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញា និងឯកសារកម្មសិទ្ធិបញ្ញាពាក់ព័ន្ធសម្រាប់ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ។ | MoC/MISTI/ MoCFA ដឹកនាំ MoEYS/MAFF/MPTC/ MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.២៩** : រៀបចំនិងផ្សព្វផ្សាយសៀវភៅមគ្គុទ្ទេសក៍រួមអាស៊ានសម្រាប់ការចុះបញ្ជីម៉ាក។ | MoC ដឹកនាំ MISTI/MoEYS/ MoCFA/MAFF/MPTC/ MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៣០** : រៀបចំនិងផ្សព្វផ្សាយសៀវភៅមគ្គុទ្ទេសក៍ស្តីពីការចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ។ | MoC ដឹកនាំ MISTI/MoEYS/ MoCFA/MAFF/ MPTC/MLVT/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៣១** : បន្តរៀបចំការបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។ | MoC | រយៈពេលវែង |
| | | **សកម្មភាព៣.៣២** : រៀបចំការបណ្តុះបណ្តាលភ្នាក់ងារតំណាងស្របច្បាប់នៃប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។ | MISTI | រយៈពេលវែង |
| | | **សកម្មភាព៣.៣៣** : លើកកម្ពស់សមត្ថភាព ជំនាញ និងពង្រឹងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា ភ្នាក់ងារកម្មសិទ្ធិបញ្ញា ក្នុងការសម្របសម្រួល និងដោះស្រាយវិវាទកម្មសិទ្ធិបញ្ញា។ | MoC ដឹកនាំ MISTI/MoCFA/ MoJ/MoI | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| **សុខាភិបាល** | ផ្សព្វផ្សាយច្បាប់ គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញា និងការអនុគ្រោះផ្សេងៗក្រោមកិច្ចព្រមព្រៀងអន្តរជាតិ។ | **សកម្មភាព៣.៣៤** ៖ ផ្សព្វផ្សាយច្បាប់ស្តីពីអាជ្ញាបណ្ណបញ្ញាសម្រាប់សុខភាពសាធារណៈ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងការអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ជូនដល់ភាគីពាក់ព័ន្ធ ដើម្បីអាចទាញយកប្រយោជន៍ពីផលិតផលឱសថក្រោមប្រកាសនីយបត្រតក្កកម្ម និងផលិតផលឱសថទូទៅដទៃទៀត។ | MoH/MISTI ដឹកនាំ<br>MoC/MoCAF/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៣៥** ៖ ពង្រឹងសមត្ថភាពរបស់គ្រឹះស្ថានផលិតឱសថក្នុងព្រះរាជាណាចក្រកម្ពុជា និងទាក់ទាញវិនិយោគផ្ទាល់ពីបរទេសក្នុងការផលិតឱសថសម្រាប់ព្យាបាលជំងឺ ដូចជា ជំងឺគ្រុនចាញ់ ជំងឺរបេង ជំងឺរ៉ាំរ៉ៃ ជំងឺឆ្លងជាដើម។ | MoH/MISTI ដឹកនាំ<br>MoC/MFA.IC/MEF | រយៈពេលវែង |
| | | **សកម្មភាព៣.៣៦** ៖ លើកកម្ពស់សមត្ថភាពសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សាលាបច្ចេកទេស សាកលវិទ្យាល័យ និងស្ថាប័នពាក់ព័ន្ធ អំពីការប្រើប្រាស់តាមប្រព័ន្ធទិន្នន័យប្រកាសនីយបត្រតក្កកម្មឱសថរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងប្រព័ន្ធទិន្នន័យបើកចំហសម្រាប់ការស្រាវជ្រាវផលិតផលឱសថនិងអភិវឌ្ឍវិទ្យាសាស្ត្រសុខាភិបាល។ | MoH/MoEYS ដឹកនាំ<br>MoC/MISTI/MoCFA/<br>MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.៣៧** ៖ ផ្សព្វផ្សាយនិងបង្កើនការយល់ដឹងអំពីកម្មសិទ្ធិបញ្ញា ដើម្បីគាំទ្រនវានុវត្តន៍ផ្នែកវេជ្ជសាស្ត្រ និងឱសថសាស្ត្រជូនដល់បុគ្គលិកសុខាភិបាលនិងភាគីពាក់ព័ន្ធ។ | MoH/MoEYS ដឹកនាំ<br>MoC/MISTI/MoCFA/<br>MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.៣៨** ៖ បង្កើតផ្នែកទទួលបន្ទុកកម្មសិទ្ធិបញ្ញា នៅតាមបណ្តាគ្រឹះស្ថានផលិតឱសថ ដើម្បីជំរុញការស្រាវជ្រាវនិងការអភិវឌ្ឍផលិតផលឱសថ។ | MoH/MISTI ដឹកនាំ<br>MoC/MoEYS/MoCFA | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព៣.៣៩** : គ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្មសម្រាប់ឱសថបុរាណ និងដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវនិងការផលិតឱសថដែលចម្រាញ់ចេញពីរុក្ខជាតិ។ | MoH/MoC ដឹកនាំ MISTI/MoCFA/ MoE/MAFF | រយៈពេលវែង |
| | | **សកម្មភាព៣.៤០** : បង្កើតនូវបណ្តាញរឹងមាំរវាងរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីទាញយកប្រយោជន៍អំពីមាតិកាអភិវឌ្ឍន៍ទីក្រុងដូហា ដែលផ្តល់សិទ្ធិឱ្យប្រទេសដែលមានការអភិវឌ្ឍតិចតួចមិនផ្តល់ការពារលើផលិតផលឱសថក្រោមប្រកាសនីយបត្រតក្កកម្ម និងទាញយកប្រយោជន៍ពីអាជ្ញាបណ្ណបញ្ចាសម្រាប់សុខភាពសាធារណៈ។ | MoH ដឹកនាំ MoC/MISTI/MoCFA | រយៈពេលមធ្យម |
| **ពាណិជ្ជកម្មនិងឧស្សាហកម្ម** | លើកកម្ពស់សមត្ថភាពវិស័យឯកជនក្នុងការវាយតម្លៃនិងធ្វើពាណិជ្ជកម្មទ្រព្យកម្មសិទ្ធិបញ្ញា និងបង្កើតកម្មវិធីពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដើម្បីអភិវឌ្ឍសហគ្រាសធុនមីក្រូតូច និងមធ្យម។ | **សកម្មភាព៣.៤១** : បន្តរៀបចំសិក្ខាសាលាស្តីពី "នវានុវត្តន៍ និងការច្នៃប្រឌិតសម្រាប់ការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម"។ | MISTI ដឹកនាំ MoC/MoCFA/MEF/ MoWA/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៤២** : បន្តរៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃកម្មសិទ្ធិបញ្ញានិងការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា នៅភ្នំពេញ សៀមរាប ក្រុងព្រះសីហនុ និងបណ្តាខេត្តគោលដៅ។ | MoC ដឹកនាំ MISTI/MoCFA/MEF/ MoWA/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៤៣** : បន្តរៀបចំសិក្ខាសាលាស្តីពី "ការកសាងកេរ្តិ៍ឈ្មោះម៉ាក" នៅតាមបណ្តារាជធានី ខេត្តគោលដៅ។ | MoC ដឹកនាំ MISTI/MoCFA/MEF/ MoWA/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៤៤**: បង្កើតកម្មវិធីបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា និងការគាំទ្រផ្សេងៗតាមតម្រូវការដាក់លាក់សម្រាប់សហគ្រាស | MoC/MISTI ដឹកនាំ MoCFA/MEF/MoWA/ MPTC//MoInfo | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | ធុនមីក្រូ តូច និងមធ្យម អាជីវកម្មដែលទើបចាប់ផ្ដើម សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវនិងអភិវឌ្ឍ។ | | |
| | | **សកម្មភាព៣.៤៥** : កសាងសមត្ថភាពនិងជំនាញកម្មសិទ្ធិបញ្ញាជូនដល់សមាជិកសមាគមសហគ្រាសធុនមីក្រូ តូច និងមធ្យម សមាគមសហគ្រិនវ័យក្មេងកម្ពុជា សមាគមសហគ្រិនស្ត្រីកម្ពុជា តក្កករ និងអ្នកច្នៃប្រឌិត និងស្ថាប័នពាក់ព័ន្ធកម្មសិទ្ធិបញ្ញា។ | MoC/MISTI ដឹកនាំ MoCFA/MEF/MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.៤៦** : ផ្ដល់ការគាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការធ្វើការវាយតម្លៃអំពីបណ្ដុំទ្រព្យកម្មសិទ្ធិបញ្ញា និងទ្រព្យអរូបី។ | MISTI ដឹកនាំ MoC/MoCFA/ MEF/MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.៤៧** : ជំរុញសហគ្រាសធុនមីក្រូ តូច និងមធ្យមក្នុងការបង្កើតទ្រព្យកម្មសិទ្ធិបញ្ញា ដូចជាម៉ាក ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គំនូរឧស្សាហកម្ម និងផ្ដល់មគ្គុទ្ទេសក៍ និងការគាំទ្រក្នុងការប្រើប្រាស់ទីផ្សារពាណិជ្ជកម្មតាម ប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងពាណិជ្ជកម្មដែលមានឈ្មោះថា ខេមបូឌាត្រេដ និងថ្នាលចល័តដទៃទៀត។ | MoC/MISTI ដឹកនាំ MoCFA/MEF/MoWA/ MPTC//MoInfo | រយៈពេលវែង |
| | | **សកម្មភាព៣.៤៨** : ជំរុញសហគ្រាសកម្រិតមធ្យមក្នុងការលើកទឹកចិត្តបុគ្គលិករបស់ខ្លួនឱ្យប្រើប្រាស់កម្មសិទ្ធិបញ្ញាសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍ។ | MISTI ដឹកនាំ MoC/MoCFA/ MEF/MoWA/MPTC | រយៈពេលវែង |
| | | **សកម្មភាព៣.៤៩** : សិក្សានិងយកមកអនុវត្តអំពីបទពិសោធន៍និងឧត្តមានុវត្តនៃការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា។ | MoC/MISTI ដឹកនាំ MoCFA/MEF/MoWA | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព៣.៥០** : ជំរុញការផ្ទេរបច្ចេកវិទ្យានិងការផ្តល់អាជ្ញាបណ្ណព្រមទាំងផ្តល់មគ្គុទ្ទេសក៍ក្នុងការរៀបចំកិច្ចសន្យាអាជ្ញាបណ្ណ ដើម្បីអាចធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា។ | MISTI ដឹកនាំ MoC/MoCFA/MEF/ MoWA | រយៈពេលវែង |
| | | **សកម្មភាព៣.៥១** : ផ្តល់ការគាំទ្រនិងលើកទឹកចិត្តដល់សហគ្រាសធុនមីក្រូ តូចនិងមធ្យមតក្កកនិងអ្នកច្នៃប្រឌិតក្នុងការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញាក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។ | MISTI ដឹកនាំ MoC/MoCFA/ MEF/MoWA | រយៈពេលវែង |
| | បង្កើតបណ្តាញផ្តល់ព័ត៌មានសម្រាប់គាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម | **សកម្មភាព៣.៥២** : បង្កើតកន្លែងពិគ្រោះយោបល់កម្មសិទ្ធិបញ្ញាសម្រាប់គាំទ្រដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម នៅសភាពាណិជ្ជកម្មរាជធានី ខេត្តគោលដៅ។ | MoC/MISTI ដឹកនាំ MoCFA/MEF | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៥៣** : បង្កើតគេហទំព័ររបស់នាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល និងគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងធ្វើបច្ចុប្បន្នកម្មគេហទំព័ររបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញានៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា សម្រាប់ជាមធ្យោបាយក្នុងការផ្សព្វផ្សាយព័ត៌មាននិងលើកកម្ពស់ចំណេះដឹងសាធារណៈអំពីកម្មសិទ្ធិបញ្ញា។ | MoC/MISTI | រយៈពេលមធ្យម |
| ទេសចរណ៍ | រៀបចំយុទ្ធសាស្ត្រក្នុងការកសាងកេរ្តិ៍ឈ្មោះម៉ាកនៃផលិតផលរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យក្លាយទៅជាគោលដៅ | **សកម្មភាព៣.៥៤** : រៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង និងកសាងកេរ្តិ៍ឈ្មោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម្រេចកំពតស្ករត្នោតកំពង់ស្ពឺ ក្រូចថ្លុងកោះទ្រង់ ទឹកឃ្មុំព្រៃមណ្ឌលគិរី ម៉ាកសមូហភាពគុយទាវភ្នំពេញ អំបុកកំពង់ធំ សម្រាប់ជាគោលដៅទេសចរណ៍។ | MoT/MoC ដឹកនាំ MISTI/MoCFA/MEF/ MoWA/MoInfo | រយៈពេលវែង |

| | | | | |
|---|---|---|---|---|
| | ទេសចរណ៍ រួមទាំងការការពារម៉ាកនេះនៅក្នុងទីផ្សារសំខាន់ៗ។ | **សកម្មភាព៣.៥៥** : អភិវឌ្ឍនិងជំរុញការកសាងកេរ្តិ៍ឈ្មោះផលិតផលម្ហូបកម្ពុជា រួមមានអាម៉ុកកម្ពុជា ក្រឡានខេត្តក្រចេះ ណែមខេត្តបាត់ដំបង ពងទាកូនខេត្តតាកែវ ឡុកឡាក់ សម្លកកូរ និងមុខម្ហូបប្រចាំតំបន់នីមួយៗ។ | MoC/MoT ដឹកនាំ MISTI/MoCFA/ MoWA/MoInfo | រយៈពេលមធ្យម |
| | ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីពង្រឹងសមត្ថភាពរបស់ភ្នាក់ងារទេសចរណ៍ និងភាគីពាក់ព័ន្ធក្នុងការធ្វើឱ្យប្រសើរឡើងសេវាកម្មទេសចរណ៍។ | **សកម្មភាព៣.៥៦** : ជំរុញការប្រើប្រាស់កម្មសិទ្ធិបញ្ញា និងកសាងកេរ្តិ៍ឈ្មោះម៉ាកសមូហភាព ចម្លាក់ប្រាក់ ស្ពាន់ខេត្តកណ្តាល សិប្បកម្មចម្លាក់ និងផលិតផលវប្បធម៌ដទៃទៀតសម្រាប់ជាគោលដៅទេសចរណ៍។ | MoC/MoT ដឹកនាំ MISTI/MoCFA/ MoWA/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៥៧** : រៀបចំផ្សព្វផ្សាយនិងកសាងសមត្ថភាពដល់សហគ្រិនវិស័យសេវាកម្មទេសចរណ៍ អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់កម្មសិទ្ធិបញ្ញា ការកសាងកេរ្តិ៍ឈ្មោះម៉ាក និងវិញ្ញាបនបត្របញ្ជាក់គុណភាព។ | MoC/MoT ដឹកនាំ MISTI/MoCFA/ MoWA/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៥៨** : សហការជាមួយសមាគមទេសចរណ៍ និងភាគីពាក់ព័ន្ធដើម្បីពិនិត្យនិងវាយតម្លៃលើការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និងម៉ាកសមូហភាព ដើម្បីគាំទ្រដល់ការរៀបចំបទប្បញ្ញត្តិនៃការប្រើប្រាស់ ដើម្បីលើកកម្ពស់គុណភាពឧស្សាហកម្មទេសចរណ៍។ | MoC/MoT ដឹកនាំ MoCFA/MoInfo | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៥៩** : ត្រួតពិនិត្យលើការប្រើប្រាស់ម៉ាកវិញ្ញាតកម្មដើម្បីកែលម្អ រក្សាស្តង់ដាសម្រាប់អ្នកផ្គត់ផ្គង់សេវាកម្មនិងផលិតផលទេសចរណ៍ ដើម្បីបង្កើនជំនឿទុកចិត្តពីអតិថិជន និងជំរុញឧស្សាហកម្មទេសចរណ៍។ | MoT ដឹកនាំ MoC/MISTI/MoCFA/ MoInfo/MoI | រយៈពេលមធ្យម |

| | | | | |
|---|---|---|---|---|
| | | **សកម្មភាព៣.៦០** : សហការជាមួយនឹងវិទ្យាស្ថានបណ្តុះបណ្តាលម្ហូបអាហារកម្ពុជា និងសមាគមចុងភៅកម្ពុជា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលអំពីបទបញ្ញារួមនៃការប្រើប្រាស់ម៉ាកសមូហភាព គុយទាវភ្នំពេញ និងម៉ាកសមូហភាពផ្សេងទៀតដល់ភោជនីយដ្ឋាននានា និងភាគីពាក់ព័ន្ធ។ | MoT ដឹកនាំ<br>MoC/MISTI/MoCFA/<br>MoInfo | រយៈពេលមធ្យម |
| **វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា** | លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការប្រើប្រាស់ប្រព័ន្ធកម្មសិទ្ធិបញ្ញាក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ | **សកម្មភាព៣.៦១** : ផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានអប់រំ ឬស្ថាប័នសិក្សានិងស្រាវជ្រាវមានលទ្ធភាពទទួលបានព័ត៌មានបច្ចេកវិទ្យា នវានុវត្តន៍ ស្នាដៃអក្សរសាស្ត្រ និងទិន្នន័យវិទ្យាសាស្ត្រ ដោយមិនគិតថ្លៃ ឬមានតម្លៃសមរម្យ។ | MISTI/MoCFA/<br>MoEYS ដឹកនាំ<br>MoC/MLVT/MPTC | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៦២** : ជំរុញក្រសួង ស្ថាប័ន វិស័យឯកជនផ្នែកសិក្សានិងស្រាវជ្រាវ ក្នុងការប្រើប្រាស់ប្រព័ន្ធទិន្នន័យរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក និងប្រព័ន្ធទិន្នន័យផ្សេងទៀត ដើម្បីទទួលបានព័ត៌មានប្រកាសនីយបត្រតក្កកម្មឯកទេស សម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍ និងការច្នៃប្រឌិត។ | MISTI/MoEYS ដឹកនាំ<br>MoC/MoCFA/<br>MLVT/MPTC | រយៈពេលមធ្យម |
| | | **សកម្មភាព៣.៦៣** : រៀបចំការតាំងពិព័រណ៍ផលិតផលវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងផលិតផលកម្មសិទ្ធិបញ្ញាផ្សេងទៀត។ | MISTI ដឹកនាំ<br>MoC/MoCFA/MPTC | រយៈពេលវែង |
| | | **សកម្មភាព៣.៦៤** : បង្កើតយុទ្ធសាស្ត្រទំនាក់ទំនងនិងផ្សព្វផ្សាយអំពីតក្កកម្ម បច្ចេកវិទ្យា គំនិតច្នៃប្រឌិត នវានុវត្តន៍ ដោយសហគ្រិនរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់បច្ចេកវិទ្យា ផលិតផលរបស់កម្ពុជា និងលើកកម្ពស់ការស្រាវជ្រាវនិងការអភិវឌ្ឍ។ | MISTI ដឹកនាំ<br>MoC/MoCFA/MPTC/<br>MoEYS/MLVT | រយៈពេលមធ្យម |

| | | | |
|---|---|---|---|
| **គំនិតផ្តួចផ្តើមគន្លឹះ:** | | | |
| រៀបចំព្រឹត្តិការណ៍ជំរុញគំនិតច្នៃប្រឌិត និងការបង្កើតផលិតផលកម្មសិទ្ធិបញ្ញា តាមរយៈការប្រកួតប្រជែងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាតិ។ | **សកម្មភាព៣.៦៥** : បង្កើតគណៈកម្មការជំរុញនិងរៀបចំការប្រកួតប្រជែងលើកកម្ពស់កម្មសិទ្ធិបញ្ញា តាមរយៈវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា កសិកម្ម វប្បធម៌ ពាណិជ្ជកម្ម ឧស្សាហកម្ម និងសម្រេចលើប្រធានបទ លក្ខណៈវិនិច្ឆ័យ និងរង្វាន់ ដើម្បីលើកកម្ពស់សារៈសំខាន់នៃកម្មសិទ្ធិបញ្ញា ក្នុងការបង្កើតគំនិតនិងដំណោះស្រាយថ្មីៗ។ | MISTI/MoC/ MPTC ដឹកនាំ MoCFA/MoEYS/ MAFF/MLVT/ MoH/MoInfo | រយៈពេលវែង |
| | **សកម្មភាព៣.៦៦** : សហការជាមួយសាកលវិទ្យាល័យ ស្ថាប័នសិក្សា ស្រាវជ្រាវ សហគ្រាសធំៗ ក្នុងការរៀបចំកម្មវិធីប្រកួតប្រជែងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។ | MISTI/MoEYS ដឹកនាំ MoC/MoCFA/MPTC/ MLVT/MoH | រយៈពេលវែង |

១- រយៈពេលខ្លី ឆ្នាំ២០២៣-២០២៤

២- រយៈពេលមធ្យម ឆ្នាំ២០២៣-២០២៦

៣- រយៈពេលវែង ឆ្នាំ២០២៣-២០២៨